 តារា អ៊ិនសួរិន ម.ក
明 星 保 險 公 司
DARA INSURANCE PLC.

# របាយការណ៍ ប្រចាំឆ្នាំ ២០២៥

Most
Trusted Partner

# មាតិកា


## I. ព័ត៌មានសង្ខេបអំពីអាជីវកម្ម

- សាររបស់ប្រធានក្រុមប្រឹក្សាភិបាល
- សាររបស់អគ្គនាយិកា
- ព័ត៌មានហិរញ្ញវត្ថុសង្ខេប

## II. ព័ត៌មានអាជីវកម្ម

- អំពីក្រុមហ៊ុន
- ផលិតផលធានារ៉ាប់រងរបស់ក្រុមហ៊ុន
- ការចាប់ដៃគូ និងប្រព័ន្ធចែកចាយ
- អតិថិជន

## III. ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម

- រចនាសម្ព័ន្ធក្រុមហ៊ុន
- គណៈកម្មាធិការ
- របាយការណ៍អភិបាលកិច្ចសាជីវកម្ម

## IV. ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការអាជីវកម្ម

- ការគ្រប់គ្រងដើមទុន និងកម្រិតសាធនភាព
- ការគ្រប់គ្រងការវិនិយោគ
- ការគ្រប់គ្រងប្រាក់បម្រុងបច្ចេកទេសធានារ៉ាប់រង
- លទ្ធផលអំពីប្រតិបត្តិការអាជីវកម្ម
- ការធានារ៉ាប់រងបន្ត
- ការគ្រប់គ្រងហានិភ័យ
- ព័ត៌មានអំពីចីរភាព

## V. របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ

# I.

# ព័ត៌មានសង្ខេប
# អំពីអាជីវកម្ម

- សាររបស់ប្រធានក្រុមប្រឹក្សាភិបាល
- សាររបស់អគ្គនាយិកា
- ព័ត៌មានហិរញ្ញវត្ថុសង្ខេប



**ឧកញ៉ា លឹម លីណា**

ប្រធានក្រុមប្រឹក្សាភិបាល

# សាររបស់
## ប្រធានក្រុមប្រឹក្សាភិបាល

តាងនាមឲ្យក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន នាងខ្ញុំមានសេចក្ដីសោមនស្សរីករាយក្នុងការចែករំលែករបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទបញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥។

គួរឱ្យកត់សម្គាល់ សម្រាប់ឆ្នាំ២០២៥ ជាឆ្នាំដែលមានទាំងឱកាស និងបញ្ហាប្រឈមសម្រាប់វិស័យធានារ៉ាប់រងទូទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ កំណើនសេដ្ឋកិច្ចជាបន្តបន្ទាប់ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការយល់ដឹងកាន់តែខ្ពស់អំពីការការពារហានិភ័យបានរួមចំណែកជំរុញការរីកចម្រើននៃទីផ្សារធានារ៉ាប់រងទូទៅនៅកម្ពុជា ខណៈពេលដែលការប្រកួតប្រជែងកាន់តែខ្លាំង តម្រូវការពាក់ព័ន្ធនឹងអនុលោមភាពបទប្បញ្ញត្តិកាន់តែរឹតបន្តឹង និងភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ចសកលតម្រូវឲ្យមានការត្រួតពិនិត្យយ៉ាងប្រយ័ត្នប្រយែងនិងមានអភិបាលកិច្ចប្រកបដោយវិន័យ។ នៅក្នុងបរិបទនេះ ក្រុមប្រឹក្សាភិបាលនៅតែផ្ដោតលើការធានានិរន្តរភាពរយៈពេលវែងរបស់ក្រុមហ៊ុន ភាពធន់ផ្នែកហិរញ្ញវត្ថុ និងការលូតលាស់រីកចម្រើនប្រកបដោយការទទួលខុសត្រូវ។

ក្នុងរយៈពេលពេញមួយឆ្នាំនេះ ក្រុមប្រឹក្សាភិបាលបានបំពេញតួនាទីត្រួតពិនិត្យ និងផ្តល់ការណែនាំជាយុទ្ធសាស្រ្តប្រកបដោយការទទួលខុសត្រូវ និងឯករាជ្យភាព ដោយធ្វើការយ៉ាងជិតស្និទ្ធជាមួយគណៈគ្រប់គ្រងដើម្បីពង្រឹងអភិបាលកិច្ចសាជីវកម្ម ការគ្រប់គ្រងហានិភ័យ និងក្របខណ្ឌត្រួតពិនិត្យផ្ទៃក្នុង។ យើងសង្កត់ធ្ងន់ជាពិសេសលើការវិនិច្ឆ័យនៃការវាយតម្លៃនិងទទួលយកហានិភ័យធានារ៉ាប់រង ប្រសិទ្ធិភាពគ្រប់គ្រងក្នុងការដោះស្រាយសំណងធានារ៉ាប់រងភាពគ្រប់គ្រាន់នៃដើមទុននិងអនុលោមភាពតាមស្តង់ដារបទប្បញ្ញត្តិដែលបានអនុម័តដោយនិយ័តករធានារ៉ាប់រងកម្ពុជា។ យើងផ្តោតលើវិធានការដែលអាចការពារទាំងផលប្រយោជន៍របស់ម្ចាស់បណ្ណសន្យារ៉ាប់រង និងរក្សាទំនុកចិត្តពីភាគីពាក់ព័ន្ធ។

ក្រុមហ៊ុនបានរាយការណ៍ពីប្រាក់ចំណេញសុទ្ធចំនួន២៥៨.៨៨៦ ដុល្លារអាមេរិក (ប្រហែល១,០៣៨ពាន់លានរៀល) និងមិនមានការប្រកាស ឬស្នើផ្តល់ភាគលាភសម្រាប់ការិយបរិច្ឆេទនេះទេ។ ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនសូមបញ្ជាក់ថា មិនមានការផ្លាស់ប្តូរនូវដើមទុន និងមិនមានចលនាផ្លាស់ប្តូរជាសារវន្តសំខាន់ៗពាក់ព័ន្ធនឹងទុនបម្រុង និងសំវិធានធនអំឡុងការិយបរិច្ឆេទនេះ ហើយមិនមានលក្ខណៈមិនប្រក្រតីនៃខ្ទង់គណនី ឬប្រតិបត្តិការណាមួយនោះទេ។

យើងខ្ញុំ បានមានសេចក្តីសោមនស្សចំពោះលទ្ធផលរបស់ក្រុមហ៊ុនក្នុងឆ្នាំ២០២៥ ដោយបានបង្ហាញពីការប្តេជ្ញាចិត្តរបស់គណៈគ្រប់គ្រងដើម្បីអភិវឌ្ឍន៍ប្រកបដោយតុល្យភាពការកែលម្អប្រតិបត្តិការអាជីវកម្មប្រកបដោយប្រសិទ្ធិភាពនិងការផ្តល់ជូនសេវាកម្មប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ចំពោះអតិថិជន។ ក្រុមហ៊ុនបានបន្តធ្វើឲ្យកាន់តែប្រសើរឡើងនៅក្នុងការផ្តល់ជូននូវផលិតផលធានារ៉ាប់រងរបស់ខ្លួន ពង្រឹងការចាប់ដៃគូចែកចាយ និងវិនិយោគនៅក្នុងប្រព័ន្ធព័ត៌មានវិទ្យានិងធនធានមនុស្សដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅក្នុងបរិយាកាសទីផ្សារដែលមានភាពប្រែប្រួល។

នាពេលអនាគត ក្រុមប្រឹក្សាភិបាលនៅតែមានសុទិដ្ឋិនិយមប្រកបដោយការយកចិត្តទុកដាក់ខ្ពស់លើទស្សនៈវិស័យចំពោះធានារ៉ាប់រងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ខណៈពេលដែលភាពមិនប្រាកដប្រជានៅតែមាន យើងខ្ញុំជឿជាក់ថាក្រុមហ៊ុនស្ថិតនៅក្នុងស្ថានភាពល្អ ក្នុងការទប់ទល់នឹងហានិភ័យដែលកំពុងតែកើតឡើង និងការចាប់យកផលប្រយោជន៍ពីការកើនឡើងនូវឱកាស តាមរយៈអភិបាលកិច្ចល្អ ការគ្រប់គ្រងហានិភ័យប្រកបដោយភាពរឹងមាំ និងភាពបត់បែនជាយុទ្ធសាស្ត្រ។



# សាររបស់ អគ្គនាយិកា

**លោកស្រី ហង្ស ចន្ធូ**

អគ្គនាយិកា

តាងនាមឲ្យគណៈគ្រប់គ្រងក្រុមហ៊ុន នាងខ្ញុំមានសេចក្តីសោមនស្សរីករាយក្នុងការចែករំលែករបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទបញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥។

នៅក្នុងឆ្នាំ២០២៥ ក្រុមហ៊ុន តារា អ៊ិនស្ទូរិន ម.ក បានបន្តឆ្លងកាត់ទីផ្សារក្នុងស្ថានភាពលំបាកមួយ ខណៈពេលដែលរក្សាបាននូវវិធីសាស្ត្រការវាយតម្លៃ និងទទួលយកហានិភ័យធានារ៉ាប់រងប្រកបដោយការប្រុងប្រយ័ត្ន។ ក្រុមហ៊ុនបានកត់ត្រាប្រាក់ចំណូលបុព្វលាភធានារ៉ាប់រងដុលសរុបបានកើនឡើងដល់ ៦,៦២លានដុល្លារអាមេរិក ឬ ៦៤% ជាមួយនឹងប្រាក់ចំណូលបុព្វលាភធានារ៉ាប់រងសុទ្ធដែលទទួលបានចំនួន ០,៨១លានដុល្លារអាមេរិក ដែលឆ្លុះបញ្ចាំងពីកំណើននៃសកម្មភាពអាជីវកម្ម។ ប្រាក់ចំណូលប្រតិបត្តិការសរុបបានឈានដល់២,២០លានដុល្លារអាមេរិកដែលបានគាំទ្រដោយកម្រៃជើងសារធានារ៉ាប់រងបន្ត និងប្រាក់ចំណូលពីការវិនិយោគ។ ការដោះស្រាយសំណងធានារ៉ាប់រងសុទ្ធត្រូវបានគ្រប់គ្រងប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ដែលមានចំនួន០,១៦លានដុល្លារអាមេរិក និងចំណាយលើការវាយតម្លៃហានិភ័យធានារ៉ាប់រង និងប្រតិបត្តិការសរុបមានចំនួន១,៧៤ លានដុល្លារអាមេរិក ។ ជាលទ្ធផលក្រុមហ៊ុនសម្រេចបានប្រាក់ចំណេញមុនបង់ពន្ធលើប្រាក់ចំណូលចំនួន០,៣០លានដុល្លារអាមេរិក និងប្រាក់ចំណេញសុទ្ធក្រោយបង់ពន្ធលើប្រាក់ចំណូលចំនួន ០,២៦លានដុល្លារអាមេរិកដែលជាប្រាក់ចំណូលរួមសរុបប្រចាំការិយបរិច្ឆេទផងដែរ។

ទំនុកចិត្តរបស់អតិថិជន ត្រូវបានចាត់ទុកជាមូលដ្ឋានគ្រឹះនៃយុទ្ធសាស្ត្រ និងការអភិវឌ្ឍអាជីវកម្មរបស់ក្រុមហ៊ុន។ នៅក្នុងឆ្នាំ២០២៥ យើងខ្ញុំបានវិនិយោគនៅក្នុងគុណភាពសេវាកម្ម គំនិតផ្តួចផ្តើមឌីជីថល និងដំណើរការដើម្បីធានាបាននូវភាពងាយស្រួល តម្លាភាព និងសេវាកម្មឆ្លើយតបបានទាន់ពេលវេលា។

យើងខ្ញុំជឿជាក់ថាឧត្តមភាពសេវាកម្មជាប្រចាំគឺជាគន្លឹះក្នុងការកសាងទំនាក់ទំនងរយៈពេលវែង និងរក្សាក្រុមហ៊ុនឱ្យស្ថិតនៅក្នុងស្ថានភាពល្អក្នុងការប្រកួតប្រជែងក្នុងទីផ្សារ។

ការគ្រប់គ្រងហានិភ័យ និងអភិបាលកិច្ចសាជីវកម្មល្អគឺនៅតែជាគន្លឹះអាទិភាពខ្ពស់របស់យើងខ្ញុំ។ ក្រុមហ៊ុនរក្សាក្របខណ្ឌគ្រប់គ្រងហានិភ័យដ៏រឹងមាំស្របតាមតម្រូវការបទប្បញ្ញត្តិ និងការអនុវត្តល្អប្រសើរបំផុតនៅក្នុងវិស័យ។ ការធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមប្រឹក្សាភិបាល យើងខ្ញុំធានាបាននូវការត្រួតពិនិត្យប្រកបដោយប្រសិទ្ធិភាព ភាពរឹងមាំក្នុងការគ្រប់គ្រងផ្ទៃក្នុង និងអនុលោមភាពពេញលេញជាមួយនឹងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ វិធានការទាំងនេះបានគាំទ្រដល់ស្ថិរភាពក្រុមហ៊ុនរយៈពេលវែង និងការពារផលប្រយោជន៍របស់ភាគីពាក់ព័ន្ធទាំងអស់។

ឆ្ពោះទៅកាន់អនាគត ក្រុមហ៊ុននៅតែប្តេជ្ញាចិត្តក្នុងការគ្រប់គ្រងហានិភ័យប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ ការរីកចម្រើនប្រកបដោយនិរន្តភាព និងស្ថិរភាពលទ្ធផលហិរញ្ញវត្ថុនៅក្នុងទីផ្សាប្រកួតប្រជែង។

ក្រុមហ៊ុនយើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះក្រុមប្រឹក្សាភិបាល ដៃគូអាជីវកម្មរបស់យើងខ្ញុំ អតិថិជន និងសមាជិកទាំងអស់នៃក្រុមការងាររបស់យើងខ្ញុំ ដែលបន្តការគាំទ្រ និងការសហការយ៉ាងល្អប្រសើរ។

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

របាយការណ៍ហិរញ្ញវត្ថុសង្ខេបនៃក្រុមហ៊ុន **តារា អ៊ិនស្វរិន ម.ក** ដែលបង្ហាញពីលទ្ធផល និងស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននៅក្នុងឆ្នាំ២០២៣ ឆ្នាំ២០២៤ និងឆ្នាំ២០២៥ ដោយផ្អែកលើរបាយការណ៍សវនកម្ម ដែលបានរៀបចំស្របតាមស្តង់ដារជាធរមាន។ ប្រាក់ចំណូលបុព្វលាភធានារ៉ាប់រងដុល និងចំណូលបុព្វលាភធានារ៉ាប់រងសុទ្ធ ដែលទទួលបាន ឆ្លុះបញ្ចាំងពីសកម្មភាពនៃការវាយតម្លៃនិងទទួលយកហានិភ័យធានារ៉ាប់រង ខណៈពេលដែលការដោះស្រាយសំណងធានារ៉ាប់រងដែលបានកើតឡើង បង្ហាញពីលទ្ធផលនៃប្រតិបត្តិការធានារ៉ាប់រង។ ប្រាក់ចំណេញសុទ្ធតំណាងឱ្យលទ្ធផលហិរញ្ញវត្ថុរួមបន្ទាប់ពីប្រាក់ចំណូលនិងការចំណាយទាំងអស់។

ទ្រព្យសកម្មសរុប បំណុល និងដើមទុន បង្ហាញពីទំហំនៃប្រតិបត្តិការ កាតព្វកិច្ចហិរញ្ញវត្ថុ និងភាពរឹងមាំនៃមូលធន ខណៈដែលអនុបាតសំខាន់ៗដូចជា អនុបាតសំណងធានារ៉ាប់រង អនុបាតចំណាយ អនុបាតរួម និងអនុបាតសាធនភាព ផ្តល់នូវការយល់ដឹងអំពីការវាយតម្លៃ និងទទួលយកហានិភ័យធានារ៉ាប់រង ប្រសិទ្ធភាពប្រតិបត្តិការ និងការអនុលោមតាមបទប្បញ្ញត្តិ។

លទ្ធផល និងស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំ**២០២៣** ឆ្នាំ**២០២៤** និង ឆ្នាំ**២០២៥** ត្រូវបានសង្ខេបដូចខាងក្រោម៖

## របាយការណ៍ចំណេញ ឬខាត សម្រាប់ឆ្នាំ ២០២៣-២០២៥ (គិតជា ដុល្លារអាមេរិក)

| **បរិយាយ** | **២០២៣** | **២០២៤** | **២០២៥** |
|---|---|---|---|
| ចំណូលបុព្វលាភធានារ៉ាប់រងដុល | ៤.៣៥៧.៧៩២ | ៤.០៣៥.៩៣១ | ៦.៦១៨.៦០១ |
| ចំណូលបុព្វលាភធានារ៉ាប់រងសុទ្ធដែលបានទទួលស្គាល់ | ៧៤៤.០៨០ | ៧៥១.៥៧៣ | ៨១២.៣២៦ |
| សំណងធានារ៉ាប់រងដែលបានកើតឡើង | ៥២៤.៣០៨ | ៥៨៤.៩៨៨ | ១.៥៨៣.៨២៦ |
| **ប្រាក់ចំណេញ / (ខាត) សុទ្ធ** | **៣២១.៧៥២** | **៤១៥.៣៧១** | **២៥៨.៨៨៦** |

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ សម្រាប់ឆ្នាំ ២០២៣-២០២៥
(គិតជា ដុល្លារអាមេរិក)




## សូចនាករហិរញ្ញវត្ថុសំខាន់ៗ សម្រាប់ឆ្នាំ ២០២៣-២០២៥
(គិតជា %)




## និន្នាការទីផ្សារធានារ៉ាប់រងទូទៅ

ផ្អែកតាមទិន្នន័យដែលបានចេញផ្សាយចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៦ ដោយសមាគមធានារ៉ាប់រងកម្ពុជា "សធក" ស្តីពីស្ថិតិទីផ្សារធានារ៉ាប់រងទូទៅនៅក្នុងឆ្នាំ២០២៥ ទីផ្សារបានកើនឡើងដោយ២,៥០ភាគរយ ពីមួយឆ្នាំទៅមួយឆ្នាំ ដែលយឺតជាងបើប្រៀបធៀបទៅនឹងកំណើន៣,៤០ភាគរយ ដែលបានកត់ត្រានៅក្នុងឆ្នាំ២០២៤។ កំណើននេះត្រូវបានជំរុញជាចម្បងដោយធានារ៉ាប់រងសុខភាព **(១៣,៥០ភាគរយ)** ធានារ៉ាប់រងយានយន្ត **(៩,៥០ភាគរយ)** និងធានារ៉ាប់រងគ្រោះថ្នាក់បុគ្គល និងធានារ៉ាប់រងការដឹកជញ្ជូនតាមសមុទ្រ ធានារ៉ាប់រងអាកាសចរណ៍ និងការដឹកជញ្ជូន **(១៦,៩០ភាគរយ)**។

ព័ត៌មានលម្អិតទីផ្សារស្តីពីបុព្វលាភធានារ៉ាប់រងដុល និងការដោះស្រាយសំណងធានារ៉ាប់រងតាមប្រភេទអាជីវកម្មមានដូចខាងក្រោម៖

| | ចំណូលបុព្វលាភធានារ៉ាប់រងដុល | | សំណងធានារ៉ាប់រងដុល | |
|---|---|---|---|---|
| | (គិតជាដុល្លារអាមេរិក) | (%) | (គិតជាដុល្លារអាមេរិក) | (%) |
| **ប្រភេទអាជីវកម្ម** | | | | |
| ធានារ៉ាប់រងយានយន្ត | ២៦.៣៩៨.៣២១ | ១៧% | ១៣.៥៦២.៩២៥ | ៥១,៤០% |
| ធានារ៉ាប់រងទ្រព្យសម្បត្តិ | ៤៩.២៥៩.៩៣២ | ៣២% | ១២.១៦៥.៤២៩ | ២៤,៧០% |
| ធានារ៉ាប់រងដឹកជញ្ជូននិង អាកាសចរណ៍ | ៧.៩១៤.៧៥៧ | ៥% | ២.២១៣.១៦២ | ២៨,០០% |
| ធានារ៉ាប់រងវិស្វកម្ម | ៧.៦២៤.៧៩៦ | ៥% | (៤៧០.៩៣៣) | (៦,១៨%) |
| ធានារ៉ាប់រងគ្រោះថ្នាក់បុគ្គល | ៨.៦៧៩.៦៩៣ | ៦% | ២.៤២០.០១៩ | ២៧,៩០% |
| ធានារ៉ាប់រងសុខភាព | ៣៧.៨៩៧,៦២៦ | ២៥% | ២១.៧៨៣.២៨៧ | ៥៧,៥០% |
| ធានារ៉ាប់រងផ្សេងៗ | ១៣.៩០៤.៦០៧ | ៩% | ៤.២០១.៦៨៥ | ៣០,២០% |
| **សរុប** | **១៥១.៦៧៩.៧៣៤** | **១០០%** | **៥៦.២៤៣.២៦៥** | **៣៧,០០%** |

ទីផ្សារប្រកួតប្រជែងតាមប្រភេទក្រុមហ៊ុន៖



# II.

# ព័ត៌មានអាជីវកម្ម


. អំពីក្រុមហ៊ុន

. ផលិតផលធានារ៉ាប់រងរបស់ក្រុមហ៊ុន

. ការចាប់ដៃគូ និងប្រព័ន្ធចែកចាយ

. អតិថិជន

# អំពី
# ក្រុមហ៊ុន

ក្រុមហ៊ុន **តារា អ៊ិនស្វរិន ម.ក** បានទទួលអាជ្ញាបណ្ណជាគោលការណ៍ជាក្រុមហ៊ុនធានារ៉ាប់រងទូទៅពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៨ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨ អនុលោមភាពស្របតាមច្បាប់ធានារ៉ាប់រងនៃព្រះរាជាណាចក្រកម្ពុជាអនុម័តចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០០។

ក្រុមហ៊ុន **តារា អ៊ិនស្វរិន ម.ក** គឺជាផ្នែកមួយនៃក្រុមហ៊ុន កាណាឌីយ៉ា អ៊ិនវេសមិន ហូលឌីង  ដែលជាក្រុមហ៊ុនធំបំផុត និង រឹងមាំបំផុតមួយនៅកម្ពុជា។

ក្រុមហ៊ុន កាណាឌីយ៉ា អ៊ិនវេសមិន ហូលឌីង បានពង្រីកអាជីវកម្មរបស់ខ្លួនអស់រយៈពេល៣៥ឆ្នាំ នៅពហុ ចម្រុះឧស្សាហកម្មផ្សេងៗ រួមមានមូលបត្រហិរញ្ញវត្ថុ ធនាគារ មីក្រូហិរញ្ញវត្ថុ ធានារ៉ាប់រង សំណង់ និងការអភិវឌ្ឍន៍អចលនទ្រព្យ ហេដ្ឋារចនាសម្ព័ន្ធក្រុង សួនឧស្សាហកម្ម ការគ្រប់គ្រងអចលនទ្រព្យ ឧស្សាហកម្មពិព័រណ៍ ផ្សារទំនើប និងសណ្ឋាគារ-លក់រាយ ទេសចរណ៍ ការអប់រំ ការថែទាំសុខភាព ប្រព័ន្ធផ្សព្វផ្សាយ និងការបោះពុម្ព និងកសិកម្ម។ គម្រោងសំខាន់មួយដែលបានបញ្ចប់នាពេលថ្មីៗ នេះគឺអាកាសយានដ្ឋានអន្តរជាតិតេជោ។

យុទ្ធសាស្ត្ររបស់ក្រុមហ៊ុន គឺការអភិវឌ្ឍសំពៀតវិនិយោគដែលមានផលចំណេញ ដោយផ្តោតលើប្រភេទធានារ៉ាប់រងលើទ្រព្យសម្បត្តិ វិស្វកម្ម ធានារ៉ាប់រងផ្សេងៗ និងការដឹកជញ្ជូនតាមផ្លូវសមុទ្រ ព្រមទាំងមានការគាំទ្រដោយការវាយតម្លៃ និងទទួលយកហានិភ័យធានារ៉ាប់រងប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ និងការពង្រឹងសេវាកម្មផ្នែកលក់ និងការដោះស្រាយសំណងធានារ៉ាប់រងសម្រាប់អតិថិជនពីគ្រប់មណ្ឌលដ្ឋាន ។

## ចក្ខុវិស័យ និងបេសកកម្មរបស់ ក្រុមហ៊ុន តារា អ៊ិនស្សួរិន ម.ក

# ចក្ខុវិស័យ

ដើម្បីក្លាយជាក្រុមហ៊ុនធានារ៉ាប់រង ឈានមុខគេដែលគួរឱ្យទុកចិត្តបំផុត។

# បេសកកម្ម

ដើម្បីផ្តល់ជូននូវដំណោះស្រាយធានារ៉ាប់រង ប្រកបដោយភាពច្នៃប្រឌិត តាមរយៈវិជ្ជាជីវៈ និងសេវាកម្មដែលផ្តោតលើអតិថិជនដ៏ល្អឥត ខ្ចោះ បង្កើតទំនុកចិត្ត សន្តិភាពផ្លូវចិត្ត និងតម្លៃ យូរអង្វែងសម្រាប់ភាគីពាក់ព័ន្ធរបស់យើងខ្ញុំ។

# គុណតម្លៃស្នូលរបស់

## ក្រុមហ៊ុន តារា អ៊ិនស្សួរិន ម.ក




តាមសន្យារបស់យើងប្រកប ដោយសុចរិតភាព។

ទទួលយកឧត្តមនានុវត្តសម្រាប់ អភិបាលកិច្ចសាជីវកម្មល្អ។

ការចូលរួមចំណែកកសាងសង្គម និងបរិស្ថានរបស់យើង ប្រកបដោយ ទំនួលខុសត្រូវ។

រាល់សកម្មភាពដែលយើងកំពុង ធ្វើ យើងមានបំណងបន្តភាពល្អ ឥតខ្ចោះជានិច្ច។

# ទីស្នាក់ការ ការិយាល័យ

ចុះបញ្ជីរបស់យើងខ្ញុំ មានទីតាំងស្ថិតនៅ

**ធនាគារប្រៃសណីយ៍កម្ពុជា**

ជាន់ទី៧-៨ អគារលេខ២៦៣ ផ្លូវ១១០(ព្រះអង្គឌួង) កែងផ្លូវ៦១(បាសាក់) សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

សកម្មភាពចម្បងរបស់ក្រុមហ៊ុន **តារា អ៊ិនស្វរិន ម.ក** រួមមានការវាយតម្លៃ និងទទួលយកហានិភ័យធានារ៉ាប់រង នៃធានារ៉ាប់រងទូទៅសម្រាប់អតិថិជនទាំងនីតិបុគ្គល និង រូបវន្តបុគ្គលនៅក្នុងប្រទេសកម្ពុជាស្របតាមច្បាប់ បទប្បញ្ញត្តិនិងលក្ខខណ្ឌអាជ្ញាបណ្ណដែលពាក់ព័ន្ធ។



# ផលិតផលធានារ៉ាប់រងរបស់ក្រុមហ៊ុន

គិតត្រឹមខែធ្នូ ឆ្នាំ២០២៥ ក្រុមហ៊ុនទទួលបានការអនុម័តផលិតផលធានារ៉ាប់រងចំនួន**៤០ផលិតផល**ពីនិយ័តករធានារ៉ាប់រងកម្ពុជា។

## ផលិតផលទាំងនេះ

គឺបែកចែកចំណាត់ថ្នាក់ជាប្រភេទសំខាន់ៗ ដូចខាងក្រោម៖

### អាកាសចរណ៍

- ធានារ៉ាប់រងយន្តហោះ
- ធានារ៉ាប់រងភារៈទទួលខុសត្រូវអាកាសយានដ្ឋាន

### យានយន្ត

- ធានារ៉ាប់រងយានយន្តឯកជន
- ធានារ៉ាប់រងយានយន្តអាជីវកម្ម
- ធានារ៉ាប់រងទោចក្រយានយន្ត ឬត្រីចក្រយានយន្ត

### ដឹកជញ្ជូនតាមសមុទ្រ

- ធានារ៉ាប់រងលើការដឹកជញ្ជូនទំនិញ

### ភារៈទទួលខុសត្រូវ

- ធានារ៉ាប់រងភារៈទទួលខុសត្រូវជាសាធារណៈ
- ធានារ៉ាប់រងភារៈទទួលខុសត្រូវលើផលិតផល
- ធានារ៉ាប់រងសំណងវិជ្ជាជីវៈ
- ធានារ៉ាប់រងភារៈទទួលខុសត្រូវទូទៅលើតតិយជន
- ធានារ៉ាប់រងការព្យាបាលខុសបច្ចេកទេស
- ធានារ៉ាប់រងភារៈទទួលខុសត្រូវរបស់នាយកនិងមន្ត្រីគ្រប់គ្រង
- ធានារ៉ាប់រងភារៈទទួលខុសត្រូវតាមច្បាប់លើការបំពុល

### ទ្រព្យសម្បត្តិ

- ធានារ៉ាប់រងអគ្គិភ័យ
- ធានារ៉ាប់រងលើការខាតបង់ហិរញ្ញវត្ថុក្រោមបណ្ណសន្យារ៉ាប់រងអគ្គិភ័យ
- ធានារ៉ាប់រងហានិភ័យលើទ្រព្យសម្បត្តិ
- ធានារ៉ាប់រងអគ្គិភ័យលើដើមកៅស៊ូ

### គ្រោះថ្នាក់បុគ្គល

- ធានារ៉ាប់រងគ្រោះថ្នាក់បុគ្គលជាក្រុម
- ធានារ៉ាប់រងគ្រោះថ្នាក់បុគ្គល
- ធានារ៉ាប់រងគ្រោះថ្នាក់បុគ្គលលើការធ្វើដំណើរជាក្រុម
- ធានារ៉ាប់រងគ្រោះថ្នាក់បុគ្គលលើការធ្វើដំណើរ

### វិស្វកម្ម

- ធានារ៉ាប់រងហានិភ័យការដ្ឋានសំណង់
- ធានារ៉ាប់រងលើការតម្លើងឧបករណ៍វិស្វកម្ម
- ធានារ៉ាប់រងឡចំហាយ និង ម៉ាស៊ីនដែលប្រើសម្ពាធ
- ធានារ៉ាប់រងលើឧបករណ៍អេឡិចត្រូនិច
- ធានារ៉ាប់រងការខូចម៉ាស៊ីន
- ធានារ៉ាប់រងការខាតបង់ហិរញ្ញវត្ថុក្រោមបណ្ណសន្យារ៉ាប់រងពេលខូចម៉ាស៊ីន

### សុខភាព

- ធានារ៉ាប់រងជាក្រុមលើការសម្រាកព្យាបាលនិងការវះកាត់
- ធានារ៉ាប់រងតារា ឃែរ ធ្លីស
- សុខភាពគ្រួសារ សេហ្វធីណេត
- សុខភាពសាជីវកម្ម សេហ្វធីណេត
- សុខភាពបុគ្គល សេហ្វធីណេត
- សេហ្វធីណេត ឌីណាម៉ិចឃែរ

### ផ្សេងៗ

- ធានារ៉ាប់រងហានិភ័យទូទៅ
- ធានារ៉ាប់រងលើចោរកម្ម
- ធានារ៉ាប់រងរូបិយវត្ថុ
- ធានារ៉ាប់រងគ្រឿងចក្រនិងគ្រឿងម៉ាស៊ីនក្នុងការដ្ឋានសំណង់
- ធានារ៉ាប់រងលើទំនុកចិត្តចំពោះនិយោជិត
- ធានារ៉ាប់រងផ្លាំងកញ្ចក់
- ធានារ៉ាប់រងហានិភ័យលើអាជីវកម្មធនាគារ

**ភាគច្រើននៃផលិតផលទាំងនេះក៏មាននៅក្នុងទីផ្សារកម្ពុជាផងដែរ។**

# ការចាប់ដៃគូ និងប្រព័ន្ធចែកចាយ

ការលក់របស់ក្រុមហ៊ុនត្រូវបានចែកចាយតាមរយៈបណ្តាញដៃគូជាច្រើនរួមមាន ការលក់ដោយផ្ទាល់ ជើងសារធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង ដៃគូធានារ៉ាប់រងបើងកាសួរេន កិច្ចសហការជាមួយស្ថាប័នហិរញ្ញវត្ថុ និងបណ្តាញដៃគូផ្សេងទៀតដូចជា កិច្ចព្រមព្រៀងសហធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងផ្សេងៗជាដើម។ វិធីសាស្រ្តពហុបណ្តាញនេះអាចឱ្យក្រុមហ៊ុនឈានទៅដល់អតិថិជនដែលជានីតិបុគ្គល និងរូបវន្តបុគ្គលប្រកបដោយប្រសិទ្ធភាព ខណៈពេលដែលបង្កើនការជ្រៀតចូលទីផ្សារ និងលទ្ធភាពទទួលបានសេវាកម្ម។

ក្រុមហ៊ុនទាញយកផលប្រយោជន៍ពីបើងកាសួរេន តាមរយៈធនាគារ កាណាឌីយ៉ា នៅទូទាំងបណ្តាញសាខារបស់ធនាគារ។ បន្ថែមពីលើអាជីវកម្មបើងកាសួរេន តាមធនាគារដែលបង្កើតតាមរយៈធនាគារ កាណាឌីយ៉ា ក្រុមហ៊ុនក៏ចាប់យកអាជីវកម្មពីបណ្តាញដៃគូផ្ទៃក្នុងរបស់ខ្លួន និងប្រព័ន្ធបណ្តាញកាណាឌីយ៉ា គ្រុប ផងដែរ។ លើសពីនេះ ក្រុមហ៊ុនបន្តពង្រឹងកិច្ចសហការរបស់ខ្លួនជាមួយជើងសារធានារ៉ាប់រង និងភ្នាក់ងារធានារ៉ាប់រង ដើម្បីពង្រីកវិសាលភាពនៃបណ្តាញដៃគូរបស់ខ្លួន។

ចំណូលបុព្វលាភធានារ៉ាប់រងដុលប្រចាំឆ្នាំ**២០២៥** គឺ

## ៦.៦១៨.៦០១ ដុល្លារអាមេរិក



# អតិថិជន



- ក្រុមហ៊ុនប្តេជ្ញាចិត្ត ក្នុងការផ្តល់សេវាកម្មជូនអតិថិជនប្រកបដោយមានគុណភាពខ្ពស់ និងធានាការការពារអតិថិជនយ៉ាងរឹងមាំចំពោះអាជីវកម្មរបស់ខ្លួន។

- យើងខ្ញុំរក្សាបាននូវធនធានមនុស្សដែលមានចំនួនគ្រប់គ្រាន់និងបានទទួលការបណ្តុះបណ្តាលយ៉ាងល្អនៅទូទាំងបណ្តាញដៃគូលក់ទាំងអស់ អនុលោមតាមតម្រូវការបទប្បញ្ញត្តិជាធរមាន។

- យើងខ្ញុំប្រកាន់យកវិធីសាស្រ្តយកចិត្តទុកដាក់ផ្តោតសំខាន់លើអតិថិជនតាមរយៈបណ្តាញសេវាកម្មដែលអាចចូលដំណើរការបាន និងការដោះស្រាយសំណងធានារ៉ាប់រងប្រកបដោយប្រសិទ្ធភាព ស្របពេលធានាបានអនុលោមតាមច្បាប់តម្លាភាព និងយុត្តិធម៌។

- ក្រុមហ៊ុនមានគោលបំណងផ្តល់ជូនសេវាកម្មការដោះស្រាយសំណងធានារ៉ាប់រង២៤ម៉ោង ដើម្បីធានាភាពងាយស្រួល និងជំនួយទាន់ពេលវេលាសម្រាប់អតិថិជនរបស់យើងខ្ញុំ។

- នីតិវិធីទទួលនិងដោះស្រាយសំណងធានារ៉ាប់រងរបស់អតិថិជន និងអនុលោមតាមច្បាប់ជាធរមានក៏មានផងដែរ ដើម្បីដោះស្រាយទាន់ពេលវេលា និងការកែលម្អជាបន្តបន្ទាប់នៃសេវាកម្មយើងខ្ញុំ។

# *III.*

# ព័ត៌មានអំពី អភិបាលកិច្ចសាជីវកម្ម

. រចនាសម្ព័ន្ធក្រុមហ៊ុន

. គណៈកម្មាធិការ

. របាយការណ៍អភិបាលកិច្ចសាជីវកម្ម

# រចនាសម្ព័ន្ធក្រុមហ៊ុន

ក្រុមហ៊ុនប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការលើកកម្ពស់ស្តង់ដារខ្ពស់បំផុតនៃអភិបាលកិច្ចសាជីវកម្ម ដោយធានាបាននូវតម្លាភាព គណនេយ្យភាព និងសុចរិតភាពនៅគ្រប់កម្រិតនៃប្រតិបត្តិការរបស់ខ្លួន។ ក្របខណ្ឌអភិបាលកិច្ចសាជីវកម្ម មានរចនាសម្ព័ន្ធល្អ ដោយរួមមាន ភាគហ៊ុនិក ក្រុមប្រឹក្សាភិបាល គណៈកម្មាធិការសវនកម្ម គណៈកម្មាធិការវិនិយោគ និងគណៈគ្រប់គ្រង។

## ក្រុមប្រឹក្សាភិបាល

តួនាទី និងការទទួលខុសត្រូវច្បាស់លាស់ត្រូវបានបង្កើតឡើងសម្រាប់អង្គភាពនីមួយៗ ដើម្បីធានាបាននូវការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងដំណើរការសម្រេចចិត្តដ៏រឹងមាំ។ ក្រុមប្រឹក្សាភិបាល ផ្តល់ទិសដៅយុទ្ធសាស្រ្ត និងអភិបាលកិច្ចត្រួតពិនិត្យ ខណៈដែលគណៈកម្មាធិការសវនកម្ម និងគណៈកម្មាធិការវិនិយោគគាំទ្រផ្នែកឯកទេសនៃការត្រួតពិនិត្យ និងការគ្រប់គ្រងហានិភ័យ។ គណៈគ្រប់គ្រង ទទួលខុសត្រូវចំពោះប្រតិបត្តិការប្រចាំថ្ងៃ និងការអនុវត្តគោលដៅយុទ្ធសាស្រ្តរបស់ក្រុមហ៊ុន។

ក្របខណ្ឌអភិបាលកិច្ចដែលមានរចនាសម្ព័ន្ធនេះអនុញ្ញាតឱ្យក្រុមហ៊ុនរក្សាការគ្រប់គ្រងផ្ទៃក្នុងរឹងមាំ លើកកម្ពស់ការសម្រេចចិត្តត្រឹមត្រូវ និងធានាបាននូវអនុលោមតាមច្បាប់បានពេញលេញ និងតម្រូវការតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ដើម្បីការពារផលប្រយោជន៍ភាគីពាក់ព័ន្ធ និងគាំទ្រកំណើនអាជីវកម្មប្រកបដោយនិរន្តរភាព។

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ក្រុមប្រឹក្សាភិបាលមានសមាជិកចំនួន ៩ រូប ដូចខាងក្រោម៖

# សមាជិកនៃក្រុមប្រឹក្សាភិបាល



**ឧកញ៉ា លឹម លីណា**

ប្រធានក្រុមប្រឹក្សាភិបាល

### គុណវុឌ្ឍិការសិក្សា

- **សញ្ញាបត្រ** DES ពី Collège Ste-Marcelline, Pierrefonds, Quebec Canada
- **សញ្ញាបត្រ**-Pure and Applied Sciences, Vanier College, Ville St-Laurent, Quebec, Canada
- **សញ្ញាបត្រវេជ្ជបណ្ឌិត** (MD) ពី Université Laval
- **សញ្ញាបត្រឯកទេសផ្នែកវេជ្ជសាស្រ្តគ្រួសារ**ពី Université de Montréal

### បទពិសោធន៍

- អគ្គនាយិកាគ្រប់គ្រងផ្នែកក្រុមមន្ទីរពេទ្យ
- អនុប្រធានក្រុមប្រឹក្សាភិបាលនៃ អូរើស៊ី ខេមបូឌាន អ៊ិនវេសមេន ខបភើរេសិន
- សមាជិកក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន សុវណ្ណភូមិ ឡាយហ្វ៍ អឹស្សួរិនស៍ ភីអិលស៊ី ក្រុមហ៊ុន ខេមបូឌា អ៊ែរផត អ៊ិនវេសមិន ឯ.ក និង សាកលវិទ្យាល័យ បច្ចេកវិទ្យា និងវិទ្យាសាស្រ្តកម្ពុជា
- ប្រធានក្រុមប្រឹក្សាភិបាលនៃ តារា អ៊ិនស្ទីន ម.ក Canadian International School និង École Française Internationale de Phnom Penh
- អគ្គនាយិកា នៃមន្ទីរពេទ្យអ៊ិនធ័រឃែរ និង InterCare Health



## លោក អ៊ូ សុផាណារិទ្ធ

អភិបាលមិនប្រតិបត្តិ

### គុណវុឌ្ឍិការសិក្សា

- **សមាជិកជាន់ខ្ពស់FCCAនិងសមាជិកACCA** នៃចក្រភពអង់គ្លេស
- **សមាជិកនៃវិទ្យាស្ថានគណនេយ្យករជំនាញ** និងសវនករកម្ពុជា (KICPAA)
- **បរិញ្ញាបត្រគណនេយ្យ និងហិរញ្ញវត្ថុ** ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង(NUM)

### បទពិសោធន៍

- Executive Vice-President (EVP) និងនាយកគ្រប់គ្រងហិរញ្ញវត្ថុ នៃធនាគារ កាណាឌីយ៉ា ក.អ
- អភិបាលប្រតិបត្តិនៃធនាគារ កាណាឌីយ៉ា ក.អ នៃប្រទេសឡាវ
- អភិបាលប្រតិបត្តិនៃក្រុមហ៊ុន មូលបត្រកាណាឌីយ៉ា ឯ.ក.
- អភិបាលប្រតិបត្តិនៃក្រុមហ៊ុន សុវណ្ណភូមិ ឡាយហ្វ៍ អឺស្សួរិនស៍ ភីអិលស៊ី
- អភិបាលមិនប្រតិបត្តិនៃក្រុមហ៊ុន តារា អ៊ិនស្សួរិន ម.ក



## លោកស្រី ហង្ស ចន្ទ

អគ្គនាយិកា/អភិបាលប្រតិបត្តិ

### គុណវុឌ្ឍិការសិក្សា

- **CIP Associate , ANZIIF** ពីវិទ្យាស្ថានធានារ៉ាប់រង និងហិរញ្ញវត្ថុអូស្ត្រាលី និងនូវែលសេឡង់
- **បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងពាណិជ្ជកម្ម (MBA) ផ្នែកទីផ្សារហិរញ្ញវត្ថុ និងទីផ្សារមូលធន** ពីសាកលវិទ្យាល័យ Gloucestershire ចក្រភពអង់គ្លេស
- **បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងពាណិជ្ជកម្ម (MBA) ផ្នែកធុរកិច្ចអន្តរជាតិ** ពីសាកលវិទ្យាល័យ បញ្ញាសាស្ត្រកម្ពុជា
- **បរិញ្ញាបត្រផ្នែកហិរញ្ញវត្ថុ និងធនាគារ** ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង(NUM)

### បទពិសោធន៍

- អគ្គនាយិកានៃតារា អ៊ិនស្សួរិន ម.ក។
- អតីតអគ្គនាយិការងនៃក្រុមហ៊ុនធានារ៉ាប់រង កម្ពុជា-វៀតណាម អ៊ិនស្សួរិន ភីអិលស៊ី
- អតីតជំនួយការនាយកគ្រប់គ្រងហិរញ្ញវត្ថុ នៃ ធនាគារកាណាឌីយ៉ា ក.អ
- អតីតជំនួយការអភិបាលប្រតិបត្តិ នៃ ធនាគារកាណាឌីយ៉ា ក.អ



## លោក Yee Con Long

អភិបាលមិនប្រតិបត្តិ

### គុណវុឌ្ឍិការសិក្សា

- **បរិញ្ញាបត្រជាន់ខ្ពស់ (ហិរញ្ញវត្ថុ)** មកពីសាកលវិទ្យាល័យ Charles Sturt ប្រទេសអូស្ត្រាលី
- **សមាជិកជាន់ខ្ពស់ACCA** នៃចក្រភពអង់គ្លេស
- **សមាជិកជាន់ខ្ពស់ MICPA** និង**MIA** នៃប្រទេសម៉ាឡេស៊ី

### បទពិសោធន៍

- អគ្គនាយករង និងអភិបាល ក្រុមហ៊ុន ខេមបូឌា អ៊ែរផត អិនវេសមិន ឯ.ក
- អភិបាលឯករាជ្យមិនប្រតិបត្តិ នៃ ធនាគារកាណាឌីយ៉ា ក.អ
- អតីតប្រធានគ្រប់គ្រងផ្នែកហិរញ្ញវត្ថុEVPនិងជាអភិបាលប្រតិបត្តិនៅធនាគារកាណាឌីយ៉ាក.អ
- ធ្លាប់កាន់តំណែងផ្សេងៗក្នុងផ្នែកហិរញ្ញវត្ថុ និងសវនកម្មនៅ Shell Malaysia និងសវនករនៅ KPMG Malaysia និងកម្ពុជា



**លោក Tanat Jakrawatana**
អភិបាលមិនប្រតិបត្តិ

## គុណវុឌ្ឍិការសិក្សា

- **បរិញ្ញាបត្រសេដ្ឋកិច្ច**ពីសាកលវិទ្យាល័យ Chiang Mai ប្រទេសថៃ
- **បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងពាណិជ្ជកម្ម (MBA)** ពី Queensland University of Technology
- FLMI (LOMA) / CFA Level 1 (certified Financial Analyst)

## បទពិសោធន៍

- EVP ផ្នែកធុរកិច្ចអន្តរជាតិនៃ Muang Thai Life Assurance Plc.
- សមាជិកក្រុមប្រឹក្សាភិបាល នៃ Aigen Co., Ltd.
- អតីតអគ្គនាយកគ្រប់គ្រង និងសមាជិកក្រុមប្រឹក្សាភិបាលនៃ Muangthai Broker Co., Ltd.
- ធ្លាប់កាន់តំណែងសំខាន់ៗនៅក្នុងស្រាវជ្រាវវិនិយោគ និងហិរញ្ញវត្ថុសាជីវកម្ម និង ការធ្វើផែនការយុទ្ធសាស្ត្រនៅ Muang Thai Life Assurance Plc.



**លោក Leow Ming Fong**
អភិបាលឯករាជ្យ

## គុណវុឌ្ឍិការសិក្សា

- សមាជិកជាន់ខ្ពស់(Fellow Member) នៃ Institute of Chartered Accountants នៃប្រទេស អង់គ្លេស និង វែល
- សមាជិកនៃMalaysian Institute of Certified Public Accountants & Malaysian Institute of Accountants

## បទពិសោធន៍

- អភិបាលឯករាជ្យមិនប្រតិបត្តិនៃធនាគារកាណាឌីយ៉ា ក.អ និងធនាគារប្រៃសណីយ៍កម្ពុជា ក.អ ក្រុមហ៊ុនសុវណ្ណភូមិ ឡាយហ្វ៍ អឹស្ហួរិនស៍ ភីអិលស៊ី និង Singapore listed Jawala Corp និង តារា អ៊ិនស្វរិន ម.ក
- អតីតអភិបាលឯករាជ្យមិនប្រតិបត្តិនៃ Hap Seng Consolidated Berhad
- អតីតអភិបាលឯករាជ្យមិនប្រតិបត្តិ Focus Point Berhad និង KSK Group



**លោក Chow Wey Ming**
អភិបាលឯករាជ្យ

## គុណវុឌ្ឍិការសិក្សា

- **Bachelor of Arts-Economics (Industrial Organization)** នៃ សកលវិទ្យាល័យ Lethbridge ប្រទេស កាណាដា

## បទពិសោធន៍

- Marketing Development Office Strategy នៅTokio Marine Insurance (Malaysia) Berhad (TMIM)
- អតីតនាយកផ្នែកគណនេយ្យ TMIM
- អតីត President Director នៃ Kurnia Insurance Indonesia
- អតីតប្រធានទីភ្នាក់ងារធានារ៉ាប់រងនៃក្រុមហ៊ុន Kurnia Insurance Indonesia
- អតីតប្រធានទីភ្នាក់ងារធានារ៉ាប់រងនៃក្រុមហ៊ុន Kurnia Insurance (M) Berhad



**លោកស្រី Jirayong Anuman- Rajadhon**
អភិបាលឯករាជ្យ

## គុណវុឌ្ឍិការសិក្សា

- **បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម (ផ្នែកហិរញ្ញវត្ថុ)** ពីសាកលវិទ្យាល័យ Thammasat ប្រទេសថៃ
- **បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងពាណិជ្ជកម្ម (ផ្នែកហិរញ្ញវត្ថុ)**ពីសាកលវិទ្យាល័យ Thammasat ប្រទេសថៃ
- **សញ្ញាបត្រក្រោយឧត្តមសិក្សាផ្នែកគ្រប់គ្រងពាណិជ្ជកម្ម (វិស័យម៉ូដ)** ពី London College of Fashion នៃ University of the Arts London

## បទពិសោធន៍

- អភិបាល និងសមាជិកគណ:កម្មាធិការសវនកម្មនៃ Eastern Technical Engineering PCL
- អភិបាល និងសមាជិកគណ:កម្មាធិការសវនកម្មនៃ Phatra Leasing PCL
- អភិបាលនៃ CPanel PCL



**លោក Chan Lek Wei**
អភិបាលឯករាជ្យ

## គុណវុឌ្ឍិការសិក្សា

- Chartered Insurer ពី Chartered Insurance Institute - CII) ទីក្រុងឡុងដ៍ ចក្រភពអង់គ្លេស
- មានគុណវុឌ្ឍិវិជ្ជាជីវៈ ACII, Chartered Insurance Institute, ទីក្រុងឡុងដ៍

## បទពិសោធន៍

- អតីតអគ្គនាយក នៃក្រុមហ៊ុន ប្រូស្វរ អ៊ិនស្ចូរេន ម.ក.
- អតីតអគ្គនាយក នៃក្រុមហ៊ុន តារា អ៊ិនស្ចូរិន ម.ក
- អតីតអ្នកគ្រប់គ្រងទូទៅនៃក្រុមហ៊ុន ធានារ៉ាប់រង កម្ពុឡុនប៉ាក
- អតីតអគ្គនាយក នៃក្រុមហ៊ុនTokojaya Lao Assurance Co., Ltd

# គណៈគ្រប់គ្រង



**លោកស្រី ហង្ស ចន្ទ**

អគ្គនាយិកា

**លោកស្រី ហង្ស ចន្ទ** ជា CIP Associate , ANZIIF ពីវិទ្យាស្ថានធានារ៉ាប់រងនិងហិរញ្ញវត្ថុអូស្ត្រាលី និងនូវែលសេឡង់ និងបានបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែករដ្ឋបាលពាណិជ្ជកម្មឯកទេសហិរញ្ញវត្ថុ និងទីផ្សារមូលធន ពីសាកលវិទ្យាល័យ Gloucestershire នៃចក្រភពអង់គ្លេស និង អនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្មអន្តរជាតិពីសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងបរិញ្ញាបត្រគ្រប់គ្រងធុរកិច្ចឯកទេសហិរញ្ញវត្ថុនិងធនាគារពីសាកលវិទ្យាល័យជាតិគ្រប់គ្រងនៅរាជធានីភ្នំពេញ។

**លោកស្រី ហង្ស ចន្ទ** គឺជាអគ្គនាយិកា របស់ក្រុមហ៊ុនដែលមានបទពិសោធន៍យ៉ាងច្រើនក្នុងវិស័យធានារ៉ាប់រងទូទៅ។ លោកស្រី ដឹកនាំក្រុមហ៊ុនដោយយកចិត្តទុកដាក់ខ្លាំងផ្តោតលើការរីកចម្រើនលូតលាស់ ការគ្រប់គ្រងហានិភ័យ ភាពជាអ្នកដឹកនាំប្រកបដោយយុទ្ធសាស្ត្រ និងការផ្តល់គុណតម្លៃដល់អតិថិជន និងភាគីពាក់ព័ន្ធទាំងអស់។

ក្រោមការដឹកនាំរបស់ **លោកស្រី ហង្ស ចន្ទ** ក្រុមហ៊ុនបន្តពង្រឹងជំហរស្ថានភាពទីផ្សាររបស់ខ្លួនខណៈពេលដែលរក្សាវិធីសាស្ត្រដែលមានវិន័យចំពោះការគ្រប់គ្រងហានិភ័យ និងអនុលោមតាមបទប្បញ្ញត្តិ។

លោកស្រី ទទួលខុសត្រូវក្នុងការផ្តល់ភាពជាអ្នកដឹកនាំប្រកបដោយយុទ្ធសាស្ត្រនិងការគ្រប់គ្រងសាជីវកម្ម ការត្រួតពិនិត្យ ការរៀបចំផែនការនិងប្រតិបត្តិការស្ថាប័ន និងការធានាអភិបាលកិច្ចសាជីវកម្មរឹងមាំ និងការគ្រប់គ្រង ភាគីពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព។



**លោកស្រី ទូច ភារិន**

អគ្គនាយិការង

**លោកស្រី ទូច ភារិន** បានបញ្ចប់ថ្នាក់បរិញ្ញាបត្រចំនួនពីរគឺ មួយផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដោយទទួលបានអាហារូបករណ៍ពេញលេញពីរាជរដ្ឋាភិបាល និងមួយទៀតបញ្ចប់បរិញ្ញាបត្រជំនាញអក្សរសាស្ត្រអង់គ្លេសពីវិទ្យាស្ថានភាសាបរទេសនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

**លោកស្រី ទូច ភារិន** គឺជាអ្នកជំនាញធានារ៉ាប់រង ដែលមានបទពិសោធន៍ដ៏រឹងមាំនៅក្នុងការគ្រប់គ្រងប្រតិបត្តិការទាំងនៅក្នុងក្រុមហ៊ុនធានារ៉ាប់រងអន្តរជាតិ និងនៅក្នុងស្រុក។ លោកស្រីមានជំនាញផ្នែកការវាយតម្លៃ និងទទួលយកហានិភ័យធានារ៉ាប់រង ផ្នែកលក់ និងទីផ្សារ និងការដោះស្រាយសំណងធានារ៉ាប់រងហើយត្រូវបានទទួលស្គាល់សម្រាប់ការជំរុញឲ្យមានប្រសិទ្ធភាពធានាបាននូវការអនុលោមតាមច្បាប់ និងផ្តល់នូវស្តង់ដារខ្ពស់នៃសេវាកម្មជូនអតិថិជន។

លោកស្រី ទទួលខុសត្រូវពិនិត្យលើផ្នែកការវាយតម្លៃ និងទទួលយកហានិភ័យធានារ៉ាប់រង ការដោះស្រាយសំណងធានារ៉ាប់រង ការគ្រប់គ្រងធានារ៉ាប់រងបន្ត និងប្រតិបត្តិការបច្ចេកទេសធានារ៉ាប់រងទូទៅ ដើម្បីធានាបាននូវដំណើរការអាជីវកម្មប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។



**លោកស្រី**
**ណយ សុវណ្ណារី**

នាយកគ្រប់គ្រងការិយាល័យហិរញ្ញវត្ថុ និងរដ្ឋបាល

**លោកស្រី ណយ សុវណ្ណារី** គឺនាយកគ្រប់គ្រងការិយាល័យហិរញ្ញវត្ថុដែលមានទំនួលខុសត្រូវរួមលើការគ្រប់គ្រងហិរញ្ញវត្ថុ ការអនុលោមតាមបទប្បញ្ញត្តិ និងរបាយការណ៍ហិរញ្ញវត្ថុ។ លោកស្រីមានបទពិសោធន៍ជាង១៣ឆ្នាំក្នុងវិស័យហិរញ្ញវត្ថុ គណនេយ្យ សវនកម្ម និង អភិបាលកិច្ចសាជីវកម្ម ហើយបានអភិវឌ្ឍជំនាញយ៉ាងខ្លាំងក្នុងរបាយការណ៍ហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យ និងប្រសិទ្ធភាពប្រតិបត្តិការ។ តាមរយៈអាជីពរបស់លោកស្រី លោកស្រី បានរួមចំណែកយ៉ាងខ្ជាប់ខ្ជួនក្នុងការជំរុញកំណើនអាជីវកម្ម និងការពង្រឹងស្ថិរភាពហិរញ្ញវត្ថុ។

លោកស្រីបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រចំនួនពីរគឺ បរិញ្ញាបត្រគណនេយ្យពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដោយទទួលបានអាហារូបករណ៍ពេញលេញពីរាជរដ្ឋាភិបាល និងបរិញ្ញាបត្រទំនាក់ទំនងភាសាអង់គ្លេសពីសាកលវិទ្យាល័យន័រតុន។ បច្ចុប្បន្នលោកស្រីកំពុងបន្តការសិក្សាលើ Association of Chartered Certified Accountants ដើម្បីពង្រឹងជំនាញវិជ្ជាជីវៈរបស់ខ្លួនបន្ថែមទៀត។

លោកស្រីទទួលខុសត្រូវលើការត្រួតពិនិត្យការគ្រប់គ្រងហិរញ្ញវត្ថុ ការរៀបចំថវិការបាយការណ៍ និងប្រតិបត្តិការរដ្ឋបាល ដើម្បីធានាបាននូវការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធផល និងការគាំទ្រប្រកបដោយប្រសិទ្ធភាពនៃសកម្មភាពអាជីវកម្ម។

# គណៈកម្មាធិការ

ក្រុមហ៊ុនបានបង្កើតគណៈកម្មាធិការសវនកម្ម និងគណៈកម្មាធិការវិនិយោគ ដោយអនុលោមតាមលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិ ដើម្បីពង្រឹងអភិបាលកិច្ចសាជីវកម្ម និងធានាបាននូវការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពលើរបាយការណ៍ហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យ និងសកម្មភាពវិនិយោគ។

## គណៈកម្មាធិការសវនកម្ម

គណៈកម្មាធិការសវនកម្ម ត្រូវបានតែងតាំងដោយក្រុមប្រឹក្សាភិបាល។ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ គណៈកម្មាធិការសវនកម្មមានសមាជិកចំនួន ៣ រូប រួមមាន៖

| ឈ្មោះ | មុខតំណែង |
|---|---|
| លោក Leow Ming Fong | ប្រធានគណៈកម្មាធិការសវនកម្ម (អភិបាលឯករាជ្យ) |
| លោក Chow Wey Ming | សមាជិក (អភិបាលឯករាជ្យ) |
| លោក អ៊ូ សុផាណារិទ្ធ | សមាជិក (អភិបាលមិនប្រតិបត្តិ) |

គណៈកម្មាធិការសវនកម្ម ទទួលខុសត្រូវក្នុងការផ្តល់ការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុ ការត្រួតពិនិត្យផ្ទៃក្នុង និងមុខងារសវនកម្ម។ គណៈកម្មាធិការសវនកម្ម ត្រួតពិនិត្យឡើងវិញនូវវិសាលភាព និងប្រសិទ្ធភាពនៃសវនកម្មផ្ទៃក្នុង និងសវនកម្មឯករាជ្យ ធ្វើការវាយតម្លៃការអនុវត្តរបស់សវនករ និងផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលលើការតែងតាំង ប្រាក់បៀវត្ស និងបញ្ឈប់ក្រុមហ៊ុនផ្តល់សេវាកម្មសវនកម្មឯករាជ្យ ។ គណៈកម្មាធិការសវនកម្ម ក៏ពិនិត្យ និងអនុម័តលើផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ វាយតម្លៃភាពគ្រប់គ្រាន់នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងការគ្រប់គ្រងហានិភ័យ និងចូលរួមជាមួយសវនករផ្ទៃក្នុង សវនករឯករាជ្យ និងគណៈគ្រប់គ្រងតាមការចាំបាច់។ តាមរយៈទំនួលខុសត្រូវទាំងនេះគណៈកម្មាធិការសវនកម្ម ពង្រឹងអភិបាលកិច្ចសាជីវកម្ម បង្កើនគុណភាពសវនកម្ម និងធានាបាននូវការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព។

## គណៈកម្មាធិការវិនិយោគ

គណៈកម្មាធិការវិនិយោគ ត្រូវបានតែងតាំងដោយក្រុមប្រឹក្សាភិបាល និងមានសមាជិកយ៉ាងតិច ៥ រូប ដែលរួមមាន អភិបាលមិនប្រតិបត្តិ១រូប អភិបាលឯករាជ្យ ១ រូប អគ្គនាយកឬនាយកហិរញ្ញវត្ថុ១រូប អ្នកជំនាញគណនាបុព្វលាភធានារ៉ាប់រង១រូប និងបុគ្គលិកទទួលបន្ទុកការវិនិយោគមកពីក្រុមការងារហិរញ្ញវត្ថុ១រូប ។

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ គណៈកម្មាធិការវិនិយោគ មានសមាជិកចំនួន ៥ រូប រួមមាន៖

| ឈ្មោះ | មុខតំណែង |
|---|---|
| លោកស្រី Jirayong Anuman- Rajadhon | ប្រធានគណៈកម្មាធិការវិនិយោគ (អភិបាលឯករាជ្យ) |
| លោក Chan Lek Wei | សមាជិក (អភិបាលឯករាជ្យ) |
| លោកស្រី ហង្ស ចន្ទ | សមាជិក (អគ្គនាយិកា/អភិបាលប្រតិបត្តិ) |
| លោកស្រី Yavittha Kunchonmanee | សមាជិក (អ្នកជំនាញគណនាបុព្វលាភធានារ៉ាប់រង) |
| លោកស្រី ណយ សុវណ្ណារី | សមាជិក (នាយកគ្រប់គ្រងការិយាល័យហិរញ្ញវត្ថុ និងរដ្ឋបាល) |

គណៈកម្មាធិការវិនិយោគ ទទួលខុសត្រូវក្នុងការត្រួតពិនិត្យសកម្មភាពវិនិយោគ ដោយបង្កើតគោលនយោបាយវិនិយោគ និងធ្វើការត្រួតពិនិត្យជាប្រចាំឆ្នាំ ដើម្បីធានាថាលទ្ធផលទាំងនោះស្របតាមគោលបំណង និងគោលដៅហិរញ្ញវត្ថុជារួមរបស់ក្រុមហ៊ុន។

# របាយការណ៍អភិបាលកិច្ចសាជីវកម្ម

ក្រុមហ៊ុននៅតែអនុលោមតាមតម្រូវការអភិបាលកិច្ចសាជីវកម្មក្រោមប្រកាស ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤ ដោយបង្ហាញពីការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាភិបាលប្រកបដោយប្រសិទ្ធភាព និងការអនុវត្តការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ **ក្រុមប្រឹក្សាភិបាលមានអភិបាលចំនួនប្រាំបួន (៩) រូប** ដែល រួមមានអភិបាលឯករាជ្យចំនួន ៤ រូប ដែលបំពេញតាមតម្រូវការបទប្បញ្ញត្តិទាំងអស់ស្តីពីសមាសភាព និងឯករាជ្យភាព។ អភិបាលទាំងអស់បានបំពេញនូវគុណវុឌ្ឍិដែលបានកំណត់ និងលក្ខណៈវិនិច្ឆ័យសមស្រប និងត្រឹមត្រូវ ហើយមិនមានការផ្លាស់ប្តូរចំពោះក្រុមប្រឹក្សាភិបាល ឬមុខតំណែងគ្រប់គ្រងសំខាន់ៗក្នុងការិយបរិច្ឆេទនេះទេ។ ក្រុមហ៊ុនក៏បានរក្សាការអនុលោមតាមផ្នែកអភិបាលកិច្ចសំខាន់ៗ រួមទាំងការរឹតបន្តឹងប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ ការដាក់ជូនកំណត់ហេតុកិច្ចប្រជុំក្រុមប្រឹក្សាភិបាលទាន់ពេលវេលា ជាមួយការតែងតាំងតួនាទីសំខាន់ៗដែលត្រូវការ។

ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការរបស់ខ្លួនបានបន្តប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពតាមរយៈកិច្ចប្រជុំទៀងទាត់ និងការត្រួតពិនិត្យរចនាសម្ព័ន្ធយ៉ាងខ្ជាប់ខ្ជួន។ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលប្រចាំត្រីមាសត្រូវបានធ្វើឡើង ដោយមានកំណត់ហេតុកិច្ចប្រជុំដាក់ជូននិយតករធានារ៉ាប់រងកម្ពុជា តាមការតម្រូវ។ គណៈកម្មាធិការសវនកម្ម ដែលមានអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិ បានពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ សកម្មភាពសវនកម្មផ្ទៃក្នុង និងគុណភាពសវនកម្មជាប្រចាំ ហើយផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាល។ ក្របខណ្ឌអភិបាលកិច្ចរបស់ក្រុមហ៊ុននៅតែរឹងមាំ គាំទ្រតម្លាភាព គណនេយ្យភាព និងប្រតិបត្តិការអាជីវកម្មប្រកបដោយនិរន្តរភាព។

# IV.

# ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការអាជីវកម្ម

- ការគ្រប់គ្រងដើមទុន និងកម្រិតសាធនភាព
- ការគ្រប់គ្រងការវិនិយោគ
- ការគ្រប់គ្រងប្រាក់បម្រុងបច្ចេកទេសធានារ៉ាប់រង
- លទ្ធផលអំពីប្រតិបត្តិការអាជីវកម្ម
- ការធានារ៉ាប់រងបន្ត
- ការគ្រប់គ្រងហានិភ័យ
- ព័ត៌មានអំពីចីរភាព

# ការគ្រប់គ្រងដើមទុន និងកម្រិតសាធនភាព

ក្រុមហ៊ុននៅតែបន្តរក្សាជំហរដើមទុនរឹងមាំ និងមានភាពធន់ ដែលបានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះស្ថិរភាពហិរញ្ញវត្ថុ និងនិរន្តរភាពរយៈពេលវែង។ ពេញមួយឆ្នាំ ក្រុមហ៊ុននៅតែអនុលោមតាមលក្ខខណ្ឌតម្រូវដើមទុន និងការតម្រូវកម្រិតសាធនភាពទាំងអស់ដែលកំណត់ដោយនិយ័តករធានារ៉ាប់រងកម្ពុជា។

ក្រុមហ៊ុនស្ថិតនៅក្នុងស្ថានភាពល្អដើម្បីអនុវត្តគោរពកាតព្វកិច្ចរបស់ខ្លួនចំពោះម្ចាស់បណ្ណសន្យារ៉ាប់រង ការគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាព និងគាំទ្រគំនិតផ្តួចផ្តើមកំណើននាពេលអនាគត ជាមួយនឹងភាពរឹងមាំនៃដើមទុនដែលមានលើសពីកាតព្វកិច្ចរក្សាកម្រិតសាធនភាពតម្រូវ ។ ការត្រួតពិនិត្យមូលធនដែលជាបន្តបន្ទាប់ និងការធ្វើតេស្តភាពតានតឹងបន្ថែមទៀត បានពង្រឹងសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការស្វែងរកការផ្លាស់ប្តូរស្ថានភាពទីផ្សារប្រកបដោយទំនុកចិត្ត។

**នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥**

ក្រុមហ៊ុនបានរក្សាបានអនុបាតសាធនភាពក្នុងកម្រិត

**១៩៥%**

ទល់នឹងការតម្រូវ

និយ័តករធានារ៉ាប់រងកម្ពុជាដែលតម្រូវឲ្យរក្សាកម្រិតសាធនភាពមិនឲ្យតិចជាង

**១២០%**

យោងតាមគោលការណ៍ណែនាំបទប្បញ្ញត្តិស្តីពីការគណនាកម្រិតសាធនភាព ។

# ការគ្រប់គ្រងការវិនិយោគ

យុទ្ធសាស្ត្រវិនិយោគរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើងដើម្បីគាំទ្រកាតព្វកិច្ចចំពោះម្ចាស់បណ្ណសន្យារ៉ាប់រង រក្សាដើមទុន និងបង្កើតប្រាក់ចំណេញប្រកបដោយស្ថិរភាព និងនិរន្តរភាពក្នុងរយៈពេលវែង។ ការវិនិយោគត្រូវបានគ្រប់គ្រងស្របតាមការទទួលយកហានិភ័យរបស់ក្រុមហ៊ុន តម្រូវការសន្ទនីយភាព និងគោលការណ៍ណែនាំនៃបទប្បញ្ញត្តិ។

**គោលដៅចម្បងនៃយុទ្ធសាស្ត្រវិនិយោគគឺ៖**

- ធានាបាននូវសន្ទនីយភាពគ្រប់គ្រាន់ដើម្បីបំពេញការដោះស្រាយសំណងធានារ៉ាប់រងនិងតម្រូវការប្រតិបត្តិការ។
- រក្សាដើមទុន និងរក្សាស្ថិរភាពហិរញ្ញវត្ថុ
- សម្រេចបាននូវប្រាក់ចំណូលទទួលបានដោយនិយ័តកម្មហានិភ័យជាប់លាប់ និង
- គាំទ្រដល់កំណើនអាជីវកម្មរយៈពេលវែង។

សំពៀតវិនិយោគត្រូវបានធ្វើពិពិធកម្មទៅលើប្រភេទទ្រព្យសកម្មដែលបានអនុម័ត ដោយផ្តោតសំខាន់លើគុណភាព និងការគ្រប់គ្រងហានិភ័យ។ ហានិភ័យវិនិយោគសំខាន់ៗត្រូវបានគ្រប់គ្រងយ៉ាងសកម្មតាមរយៈការបែងចែកទ្រព្យសកម្មដោយប្រុងប្រយ័ត្នដែលអនុលោមតាមតាមដែនកំណត់នៃបទប្បញ្ញត្តិ និងការត្រួតពិនិត្យសំពៀតជាបន្តបន្ទាប់។

**ហានិភ័យនៃការវិនិយោគសំខាន់ៗរួមមាន៖**

- ហានិភ័យទីផ្សារដែលកើតចេញពីការប្រែប្រួលអត្រាការប្រាក់ និងស្ថានភាពទីផ្សារ។
- ហានិភ័យឥណទានដែលទាក់ទងនឹងភាគីប្រតិបត្តិ និងអ្នកចេញមូលបត្រ។
- ហានិភ័យសន្ទនីយភាពទាក់ទងនឹងសមត្ថភាពបំពេញកាតព្វកិច្ចនៅពេលដល់កាលកំណត់។
- ហានិភ័យប្រមូលផ្តុំពីការប៉ះពាល់នឹងប្រភេទទ្រព្យសកម្មជាក់លាក់ឬសមភាគី។

## ក្នុងរយៈពេលបីឆ្នាំខាងមុខ

ក្រុមហ៊ុនគ្រោងនឹងបន្តពង្រឹងសំពៀតវិនិយោគរបស់ខ្លួន តាមរយៈវិធីសាស្ត្រដ៏ប្រុងប្រយ័ត្ន និងមានវិន័យ។ ចំណុចផ្តោតសំខាន់ៗរួមមាន៖

- ការរក្សាការបែងចែកប្រភេទទ្រព្យសកម្មដែលបានអនុម័តឱ្យស្របតាមប្រភេទបំណុល។
- បង្កើនប្រាក់ចំណេញវិនិយោគជាបណ្តើរៗក្នុងកម្រិតហានិភ័យដែលអាចទទួលយកបាន។
- ការបង្កើនការធ្វើពិពិធកម្មដើម្បីកែលម្អភាពធន់នៃសំពៀតវិនិយោគ។
- ការបន្សាំយុទ្ធសាស្ត្រវិនិយោគដើម្បីឆ្លើយតបទៅ នឹងការវិវឌ្ឍនៃទីផ្សារ និងការផ្លាស់ប្តូរបទប្បញ្ញត្តិ។

ផែនការវិនិយោគរយៈពេលបីឆ្នាំត្រូវបានពិនិត្យឡើងវិញជាទៀងទាត់ ដើម្បីធានាថាផែនការនេះនៅតែស្របតាមស្ថានភាពហិរញ្ញវត្ថុ និងគោលបំណងយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន។

ក្រុមហ៊ុនបន្តវាយតម្លៃឱកាសវិនិយោគ ដើម្បីបង្កើនប្រសិទ្ធភាពសំពៀតវិនិយោគ ខណៈពេលដែលរក្សាទម្រង់គ្រប់គ្រងហានិភ័យដ៏រឹងមាំ។ ឱកាសវិនិយោគនីមួយៗ គឺអាស្រ័យលើការវិភាគយ៉ាងហ្មត់ចត់ រួមទាំងការវាយតម្លៃនៃប្រាក់ចំណេញដែលរំពឹងទុក ការប្រឈមនឹងហានិភ័យផលប៉ះពាល់សន្ទនីយភាព និងការអនុលោមតាមបទប្បញ្ញត្តិ។

មានតែឱកាសវិនិយោគដែលបំពេញតាមគោលបំណងយុទ្ធសាស្ត្ររបស់ក្រុមហ៊ុនការទទួលយកហានិភ័យ និងស្តង់ដារអភិបាលកិច្ចប៉ុណ្ណោះដែលត្រូវបានពិចារណា។ វិធីសាស្រ្តដែលមានវិន័យនេះធានាថា ការសម្រេចចិត្តវិនិយោគចូលរួមចំណែកជាផលវិជ្ជមានដល់ភាពរឹងមាំ និងនិរន្តរភាពហិរញ្ញវត្ថុរយៈពេលវែង។

# ការគ្រប់គ្រងប្រាក់បម្រុងបច្ចេកទេសធានារ៉ាប់រង

ក្រុមហ៊ុនបង្កើត និងរក្សាប្រាក់បម្រុងបច្ចេកទេស ដើម្បីធានាថាមានប្រាក់បម្រុងគ្រប់គ្រាន់សម្រាប់បំពេញកាតព្វកិច្ចដល់ ម្ចាស់បណ្ណសន្យារ៉ាប់រងទាំងអស់ដែលកើតឡើងពីកិច្ចសន្យាធានារ៉ាប់រង។ ប្រាក់បម្រុងបច្ចេកទេសត្រូវបានកំណត់ដោយអនុលោមតាមតម្រូវការបទប្បញ្ញត្តិ និងគោលការណ៍គណនាបុព្វលាភធានារ៉ាប់រងយ៉ាងត្រឹមត្រូវ ដោយពិចារណាលើចរិតលក្ខណៈ រយៈពេល និងហានិភ័យនៃប្រភេទធានារ៉ាប់រង។

ប្រាក់បម្រុងបច្ចេកទេសរបស់ក្រុមហ៊ុន រួមមានប្រាក់បម្រុងបុព្វលាភធានារ៉ាប់រងមិនទាន់ចាត់ទុកជាចំណូល ប្រាក់បម្រុងសំណងធានារ៉ាប់រង និងប្រាក់បម្រុងគណិតវិទ្យា។

ប្រាក់បម្រុងបច្ចេកទេសរបស់ក្រុមហ៊ុនបានកើនឡើង/ថយចុះក្នុងអំឡុងការិយបរិច្ឆេទនេះ អាស្រ័យលើកំណើនអាជីវកម្ម ការប្រែប្រួលបទពិសោធន៍នៃសំណងធានារ៉ាប់រង និងការអភិវឌ្ឍន៍នៃប្រភេទផលិតផលធានារ៉ាប់រង។

| | ២០២៥ | ២០២៤ |
|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| សរុបប្រាក់បម្រុងបច្ចេកទេសដុល | ៤.៣២៤.០៤៥ | ២.៧២២.៧៦០ |
| **ការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ** | **១.៦០១.២៨៥** | |

ប្រាក់បម្រុងបច្ចេកទេសរបស់ក្រុមហ៊ុន ត្រូវបានវាយតម្លៃដោយឯករាជ្យពីអ្នកជំនាញគណនាបុព្វលាភធានារ៉ាប់រង។ អ្នកជំនាញគណនាបុព្វលាភធានារ៉ាប់រងដែលបានតែងតាំង បានវាយតម្លៃភាពគ្រប់គ្រាន់នៃប្រាក់បម្រុង ដោយប្រើវិធីសាស្រ្ត និងការសន្មតដែលសមស្របនឹងអាជីវកម្មធានារ៉ាប់រងរបស់ក្រុមហ៊ុន។

ដោយផ្អែកលើការវាយតម្លៃរបស់អ្នកជំនាញគណនាបុព្វលាភធានារ៉ាប់រង បានបញ្ជាក់ថា ប្រាក់បម្រុងបច្ចេកទេសដែលកាន់កាប់ដោយក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ គឺគ្រប់គ្រាន់ និងសមស្រប ដើម្បីបំពេញកាតព្វកិច្ចបំណុលរបស់ម្ចាស់បណ្ណសន្យារ៉ាប់រងនាពេលអនាគត។

# លទ្ធផលអំពីប្រតិបត្តិការអាជីវកម្ម

ក្រុមហ៊ុន មានដំណើរការអាជីវកម្មប្រកបដោយស្ថិរភាពក្នុងការិយបរិច្ឆេទ ដែលគាំទ្រដោយកំណើនបុព្វលាភធានារ៉ាប់រងប្រកបដោយវិន័យ ការគ្រប់គ្រងថ្លៃដើមប្រកបដោយប្រសិទ្ធភាព និងការគ្រប់គ្រងការដោះស្រាយសំណងធានារ៉ាប់រងប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ ។ ការយកចិត្តទុកដាក់ខ្ពស់លើការវាយតម្លៃនិងទទួលយកហានិភ័យធានារ៉ាប់រង ប្រសិទ្ធភាពប្រតិបត្តិការ និងការដោះស្រាយសំណងធានារ៉ាប់រងទាន់ពេលវេលា បានបន្តពង្រឹងប្រាក់ចំណេញ និងបានផ្តល់ទំនុកចិត្តជូនម្ចាស់បណ្ណសន្យារ៉ាប់រង។

# ការធានារ៉ាប់រងបន្ត

ក្រុមហ៊ុនបានបង្កើតយុទ្ធសាស្រ្តធានារ៉ាប់រងបន្តប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ ដើម្បីគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាព និងការពារមូលដ្ឋានមូលធនរបស់ខ្លួន ដោយធានាបាននូវនិរន្តរភាពអាជីវកម្ម។ យើងមានកម្មវិធីធានារ៉ាប់រងបន្តដែលមានរចនាសម្ព័ន្ធល្អ ដែលរួមមានការរៀបចំកិច្ចព្រមព្រៀងតាមសមាមាត្រនិងមិនតាមសមាមាត្រ ក៏ដូចជាការធានារ៉ាប់រងបន្តក្រៅកិច្ចព្រមព្រៀងគោលសម្រាប់ហានិភ័យជាក់លាក់ឬហានិភ័យខ្ពស់។រចនាសម្ព័ន្ធនេះអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើពិពិធកម្មហានិភ័យរក្សាស្ថិរភាពលទ្ធផលការវាយតម្លៃ និងទទួលយកហានិភ័យធានារ៉ាប់រង និងកម្រិតការខាតបង់ដែលអាចកើតមាន។ លើសពីនេះ យើងបានអនុវត្ត "គោលការណ៍ណែនាំធានារ៉ាប់រងបន្ត" ដោយអនុលោមតាមតម្រូវការបទប្បញ្ញត្តិ ធានានូវតម្លាភាព សង្គតិភាព និងការអនុវត្តការគ្រប់គ្រងហានិភ័យត្រឹមត្រូវ។

លក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសធានារ៉ាប់រងបន្តរួមមាន ភាពរឹងមាំផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនធានារ៉ាប់រងបន្ត កំណត់ត្រាតាមដានការទូទាត់សំណងធានារ៉ាប់រង និងចំណាត់ថ្នាក់ឥណទានដោយអនុលោមតាមសេចក្តីណែនាំរបស់និយ័តករធានារ៉ាប់រងកម្ពុជាស្តីពីពិពិធកម្មនៃការធានារ៉ាប់រងបន្តចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៤។

# ការគ្រប់គ្រងហានិភ័យ

ក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុនកំណត់ទិសដៅគ្រប់គ្រងហានិភ័យរួមរបស់ក្រុមហ៊ុន ខណៈពេលដែលគណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយនិងនីតិវិធីពាក់ព័ន្ធ រួមទាំងការកំណត់អត្តសញ្ញាណ ការវាយតម្លៃ ការត្រួតពិនិត្យ និងការគ្រប់គ្រងហានិភ័យ។ ក្រុមហ៊ុនប្រឈមមុខនឹងហានិភ័យសំខាន់ៗជាច្រើន ដូចជា ហានិភ័យប្រតិបត្តិការ ហានិភ័យឥណទាន ហានិភ័យសន្ទនីយភាព ហានិភ័យទីផ្សារ និងហានិភ័យធានារ៉ាប់រង។

### ហានិភ័យប្រតិបត្តិការ៖

ក្រុមហ៊ុនគ្រប់គ្រងហានិភ័យតាមរយៈការត្រួតពិនិត្យផ្ទៃក្នុងដ៏រឹងមាំ ដែនកំណត់សិទ្ធិអំណាចដែលបានកំណត់យ៉ាងច្បាស់នៅតាមនាយកដ្ឋាននីមួយៗ និងការត្រួតពិនិត្យជាបន្តបន្ទាប់ ធានាបាននូវប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព និងការប្រកាន់ខ្ជាប់នូវគោលនយោបាយ និងនីតិវិធីផ្ទៃក្នុង។

### ហានិភ័យឥណទាន៖

ហានិភ័យនេះភាគច្រើនកើតមានលើគណនីធានារ៉ាប់រងដែលត្រូវទទួល និងប្រាក់បញ្ញើដែលបានដាក់ជាមួយស្ថាប័នហិរញ្ញវត្ថុ។ ក្រុមហ៊ុនគ្រប់គ្រងដោយការវាយតម្លៃសមត្ថភាពឥណទានរបស់ខ្លួននិងស្ថិរភាពហិរញ្ញវត្ថុរបស់អតិថិជននិងសមភាគីអនុវត្តវិធានការត្រួតពិនិត្យឥណទាន និងត្រួតពិនិត្យជាប្រចាំនូវចំនួនទឹកប្រាក់ ដែលមិនទាន់ទូទាត់។ ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានលុបចោលនៅពេលដែលការទារត្រឡប់មកវិញត្រូវបានចាត់ទុកថាមិនអាចទៅរួច។

### ហានិភ័យសន្ទនីយភាព៖

សំដៅដល់ហានិភ័យនៃការមិនមានសាច់ប្រាក់គ្រប់គ្រាន់ដើម្បីបំពេញកាតព្វកិច្ចនៅពេលដល់កំណត់។ ក្រុមហ៊ុនគ្រប់គ្រងហានិភ័សន្ទនីយភាពតាមរយៈការត្រួតពិនិត្យជាប្រចាំលើរំហូរសាច់ប្រាក់ និងតាមរយៈការរក្សាសាច់ប្រាក់ឱ្យបានគ្រប់គ្រាន់ និងសមមូលសាច់ប្រាក់ដើម្បីគាំទ្រដល់តម្រូវការប្រតិបត្តិការ ការវិនិយោគ និងតម្រូវការហិរញ្ញប្បទានរបស់ខ្លួន។

### ហានិភ័យទីផ្សារ៖

ក្រុមហ៊ុនកាត់បន្ថយផលប៉ះពាល់ពីហានិភ័យនេះ តាមរយៈយុទ្ធសាស្រ្តវិនិយោគប្រកបដោយការយកចិត្តទុកខ្ពស់ ដោយដាក់មូលនិធិនៅក្នុងឧបករណ៍ហិរញ្ញវត្ថុដែលទទួលបានការអនុញ្ញាតនិងមានហានិភ័យទាបដើម្បីការពារដើមទុនខណៈពេលដែលរក្សាបាននូវផលចំណេញប្រកបដោយសង្គតិភាពនិងស្ថិរភាព។

### ហានិភ័យធានារ៉ាប់រង៖

ហានិភ័យចម្បងនៅក្នុងធានារ៉ាប់រងជាទូទៅរួមមានហានិភ័យនៃការវាយតម្លៃនិងទទួលយកហានិភ័យធានារ៉ាប់រង និងហានិភ័យនៃធានារ៉ាប់រងបន្ត។ ហានិភ័យនៃការវាយតម្លៃ និងទទួលយកហានិភ័យធានារ៉ាប់រងកើតឡើងពីភាពមិនច្បាស់លាស់នៅក្នុងស្ថានភាពនៃសំណងធានារ៉ាប់រង ដែលរួមមានថាតើសំណងធានារ៉ាប់រងកើតឡើងញឹកញាប់ប៉ុណ្ណានិងថាតើទំហំទឹកប្រាក់នៃសំណងធានារ៉ាប់រងមានទំហំធំកម្រិតណា ក៏ដូចជាការផ្លាស់ប្តូរលក្ខខណ្ឌខាងក្រៅ ដូចជា សេដ្ឋកិច្ច ច្បាប់ ឬបរិយាកាសទីផ្សារ។ ក្រុមហ៊ុនគ្រប់គ្រងបញ្ហានេះ តាមរយៈការអនុវត្តស្តង់ដារនៃការវាយតម្លៃ និងទទួលយកហានិភ័យធានារ៉ាប់រងដោយប្រុងប្រយ័ត្ន និងការបែងចែកហានិភ័យធានារ៉ាប់រងតាមប្រភេទអាជីវកម្មខុសៗគ្នា ការកំណត់កម្រិតនៃការទទួលយកហានិភ័យធានារ៉ាប់រងច្បាស់លាស់ និងការវាយតម្លៃឡើងវិញនូវប្រាក់បម្រុងសំណងធានារ៉ាប់រងជាប្រចាំ។

ហានិភ័យធានារ៉ាប់រងបន្តទាក់ទងនឹងលទ្ធភាពដែលដៃគូធានារ៉ាប់រងបន្តដែលប្រហែលជាមិនអាចបំពេញកាតព្វកិច្ចរបស់ពួកគេបាន។ ដើម្បីគ្រប់គ្រងផលប៉ះពាល់នេះ ក្រុមហ៊ុនធ្វើការជាមួយក្រុមហ៊ុនធានារ៉ាប់រងបន្តដែលរឹងមាំ បែងចែកកម្រិតហានិភ័យតាមរយៈការចែកចាយដល់ដៃគូជាច្រើនហើយបន្តតាមដានភាពរឹងមាំហិរញ្ញវត្ថុរបស់ក្រុមហ៊ុនធានារ៉ាប់រងបន្ត និងសមត្ថភាពឥណទានរបស់ក្រុមហ៊ុនធានារ៉ាប់រងបន្ត។

### វិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន៖

ក្រុមហ៊ុនបន្តអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន អន្តរការី និងដៃគូធានារ៉ាប់រងបន្ត ជាបន្តបន្ទាប់ ដោយវាយតម្លៃពីភាពរឹងមាំផ្នែកហិរញ្ញវត្ថុ វាយតម្លៃចំណាត់ថ្នាក់ឥណទាន និងការអនុវត្តប្រតិបត្តិការរបស់ពួកគេ ដោយរក្សាទុកទំនាក់ទំនងតែជាមួយដៃគូណា ដែលមានភាពជឿជាក់ និងមានស្ថិរភាពផ្នែកហិរញ្ញវត្ថុប៉ុណ្ណោះ។

នៅក្នុងអំឡុងការិយបរិច្ឆេទ មិនមានការផ្លាស់ប្តូរជាសារវន្តណាមួយចំពោះគោលនយោបាយនិងនីតិវិធីគ្រប់គ្រងហានិភ័យរបស់ក្រុមហ៊ុនទេ។

# ព័ត៌មានអំពីចីរភាព

## អភិបាលកិច្ចសាជីវកម្មប្រកបដោយចីរភាព

ក្រុមហ៊ុន រក្សាបាននូវអភិបាលកិច្ចសាជីវកម្មដ៏រឹងមាំស្របតាមលក្ខខណ្ឌតម្រូវដែលកំណត់ដោយនិយ័តករជានាវ៉ាប់រងកម្ពុជា។ សមាជិកក្រុមប្រឹក្សាភិបាលចំនួនប្រាំបួន (៩)រូប របស់ខ្លួនរួមមាន អភិបាលឯករាជ្យចំនួនបួន(៤)រូប ដែលគាំទ្រដល់ការសម្រេចចិត្តប្រកបដោយតម្លាភាព និងការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព ជាមួយនឹងការតែងតាំងក្រុមប្រឹក្សាភិបាលទាំងអស់ដែលត្រូវបានអនុម័តដោយនិយ័តករជានាវ៉ាប់រងកម្ពុជា។ គណៈកម្មាធិការសវនកម្ម ត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ សវនកម្មផ្ទៃក្នុង និងអនុលោមតាមបទប្បញ្ញត្តិ ខណៈពេលដែលកិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការត្រូវបានធ្វើយ៉ាងទៀងទាត់ដើម្បីធានាបាននូវអភិបាលកិច្ចប្រកបដោយភាពត្រឹមត្រូវនិងរបាយការណ៍ស្របតាមបទប្បញ្ញត្តិទាន់ពេលវេលា។

## ផលប៉ះពាល់ចំពោះសង្គម

ក្រុមហ៊ុន រក្សាបាននូវស្តង់ដារខ្ពស់នៃសុចរិតភាព គណនេយ្យភាព និងអនុលោមតាមបទប្បញ្ញត្តិ នៅក្នុងប្រតិបត្តិការ និងដំណើរការសម្រេចចិត្តរបស់ខ្លួន។ តាមរយៈអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព និងការត្រួតពិនិត្យផ្ទៃក្នុង ក្រុមហ៊ុនការពារផលប្រយោជន៍របស់ម្ចាស់បណ្ណសន្យារ៉ាប់រងនិងរក្សាទំនាក់ទំនងរឹងមាំជាមួយភាគីពាក់ព័ន្ធ។

ដើម្បីគាំទ្រដល់ការរីកលូតលាស់ប្រកបដោយចីរភាព ក្រុមហ៊ុនយកចិត្តទុកដាក់លើការតែងតាំងសមាជិកអភិបាលទាំងអស់ និងគណៈគ្រប់គ្រងដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់និងមានកេរ្តិ៍ឈ្មោះល្អ ដែលជំរុញឱ្យមានភាពជាអ្នកដឹកនាំប្រកបដោយការទំនួលខុសត្រូវនិងការអភិវឌ្ឍវិជ្ជាជីវៈជាបន្តបន្ទាប់នៅក្នុងស្ថាប័ន ។

## ផលប៉ះពាល់ចំពោះបរិស្ថាន

ទោះបីជាប្រតិបត្តិការរបស់ក្រុមហ៊ុនមានផលប៉ះពាល់ដោយផ្ទាល់តិចតួចបំផុតលើបរិស្ថានក៏ដោយ ក៏ក្រុមហ៊ុននៅតែប្តេជ្ញាចិត្តក្នុងការអនុវត្តអាជីវកម្មប្រកបដោយចីរភាព និងការទទួលខុសត្រូវតាមរយៈអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព ការអនុលោមតាមច្បាប់ និងការគ្រប់គ្រងហានិភ័យ។ ទិដ្ឋភាពបរិស្ថានត្រូវបានពិចារណាដោយប្រយោលតាមរយៈការវាយតម្លៃ និងទទួលយកហានិភ័យធានារ៉ាប់រងប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ និងប្រតិបត្តិការប្រកបដោយចីរភាពរយៈពេលវែង។

ក្នុងអំឡុងការិយបរិច្ឆេទ មិនមានការផ្លាស់ប្តូរជាសារវន្តណាមួយត្រូវបានធ្វើឡើងចំពោះរចនាសម្ព័ន្ធអភិបាលកិច្ចសាជីវកម្មទេ ហើយក្រុមហ៊ុននៅតែបន្តលើកកម្ពស់ក្របខណ្ឌអភិបាលកិច្ចរបស់ខ្លួន ដើម្បីគាំទ្រដល់ការលូតលាស់ និងស្ថិរភាពអាជីវកម្មប្រកបដោយចីរភាព។

## ការទទួលខុសត្រូវចំពោះសង្គមរបស់សាជីវកម្ម

ក្នុងអំឡុងការិយបរិច្ឆេទ ក្រុមហ៊ុនបានចូលរួមសកម្មភាពពាក់ព័ន្ធនឹងការទទួលខុសត្រូវចំពោះសង្គមរបស់សាជីវកម្ម ផ្សេងៗ ដើម្បីផ្តល់ជូនត្រឡប់ទៅសហគមន៍វិញ។

### ក. ការគាំទ្រការថែទាំសុខភាព




ក្រុមហ៊ុន **តារា អ៊ិនស្សួរិន ម.ក** បានប្តេជ្ញាចិត្តយ៉ាងជ្រាលជ្រៅក្នុងការផ្តល់ការគាំទ្រសុខុមាលភាពដល់កុមារ តាមរយៈការបរិច្ចាគប្រចាំឆ្នាំរបស់ខ្លួនដល់ **"មន្ទីរពេទ្យគន្ធបុប្ផា"** ដែលជាផ្នែកមួយនៃព្រឹត្តិការណ៍ទិវាធានារ៉ាប់រងកម្ពុជាឆ្នាំ២០២៥។

### ខ. ជំនួយមនុស្សធម៌





ក្នុងអំឡុងពេល**ជម្លោះព្រំដែនរវាងប្រទេសកម្ពុជា-ថៃ** ក្រុមហ៊ុនបានផ្តល់ជំនួយហិរញ្ញវត្ថុនិងសម្ភារៈចាំបាច់តាមរយៈ **"និយ័តករធានារ៉ាប់រងនៅកម្ពុជា"** ដើម្បីជួយដល់បងប្អូនជនភៀសសឹក ។ ការរួមចំណែកនេះបានជួយសម្រួលលក្ខខណ្ឌរស់នៅរបស់បងប្អូនជនភៀសសឹក ពេលនៅឆ្ងាយពីផ្ទះ និងផ្តល់ការសង្គ្រោះក្នុងអំឡុងពេលលំបាក។

## គ. ការអប់រំ និងការយល់ដឹងពីបរិស្ថាន








យើងខ្ញុំបានចូលរួមក្នុង**កម្មវិធីការដាំដើមឈើ "Green Oasis"** ដើម្បីគាំទ្រគំនិតផ្តួចផ្តើមដាំដើមឈើ និងរួមចំណែកបរិស្ថានបៃតង និងនិរន្តរភាពសម្រាប់អនាគត។

# V.

# របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ

របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរបស់ក្រុមហ៊ុនសម្រាប់
កាលបរិច្ឆេទចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ មានភ្ជាប់មកជាមួយខាងក្រោមនេះ។

**តារា អ៊ិនស្ទូរិន ម.ក**

**របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥**

**តារា អ៊ិនស្ទូរិន ម.ក**

**របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥**

| **មាតិកា** | **ទំព័រ** |
|---|---|
| ព័ត៌មានអំពីក្រុមហ៊ុន | ១ |
| របាយការណ៍ក្រុមប្រឹក្សាភិបាល | ២ - ៥ |
| សេចក្តីបញ្ជាក់របស់ក្រុមប្រឹក្សាភិបាល | ៦ |
| របាយការណ៍សវនករឯករាជ្យ | ៧ - ១១ |
| របាយការណ៍ហិរញ្ញវត្ថុ៖ | |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ១២ |
| របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ | ១៣ |
| របាយការណ៍បម្រែបម្រួលមូលធន | ១៤ |
| របាយការណ៍លំហូរសាច់ប្រាក់ | ១៥ |
| កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ | ១៦ - ៦៧ |

# ព័ត៌មានអំពីក្រុមហ៊ុន

| | | |
|---|---|---|
| **នាមករណ៍ក្រុមហ៊ុន** | តារា អ៊ិនស្ទួរិន ម.ក | |
| **អត្តលេខចុះបញ្ជី** | ០០០៣៤៦៨៦ | |
| **ការិយាល័យចុះបញ្ជី** | ជាន់ទី៧ ជាន់ទី៨ ផ្ទះលេខ ២៦៣ ផ្លូវលេខ ១១០ (ផ្លូវព្រះអង្គឌួង) កែងនឹងផ្លូវលេខ ៦១ (បាសាក់) សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ | |
| **ភាគទុនិក** | លោកស្រី លឹម លីណា | |
| | លោកស្រី លឹម សុផានី | |
| | Muang Thai Life Assurance Public Company Limited | |
| | លោកស្រី ហង្ស ចន្ធូ | |
| | លោក អ៊ូ សុផាណារិទ្ធ | |
| **ក្រុមប្រឹក្សាភិបាល** | លោកស្រី លឹម លីណា | ប្រធានក្រុមប្រឹក្សាភិបាល |
| | លោក អ៊ូ សុផាណារិទ្ធ | អភិបាល |
| | លោកស្រី ហង្ស ចន្ធូ | អភិបាល |
| | លោក Yee Con Long | អភិបាល |
| | លោក Tanat Jakrawatana | អភិបាល |
| | លោក Chow Wey Ming | អភិបាលឯករាជ្យ |
| | លោក Leow Ming Fong | អភិបាលឯករាជ្យ |
| | លោកស្រី Jirayong Anuman-Rajadhon | អភិបាលឯករាជ្យ |
| | លោក Chan Lek Wei | អភិបាលឯករាជ្យ |
| **ក្រុមគណៈគ្រប់គ្រង** | លោកស្រី ហង្ស ចន្ធូ | អគ្គនាយិកា |
| | លោកស្រី ទូច ភារិន | អគ្គនាយិការង |
| **ធនាគារគោល** | ធនាគារកាណាឌីយ៉ា ក.អ | |
| | ធនាគារ ប្រៃសណីយ៍ កម្ពុជា ក.អ | |
| | ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក | |
| | ធនាគារ តៃវ៉ាន់ ខូអបភើរេធីវ សាខាភ្នំពេញ | |
| | ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក | |
| | ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក | |
| | ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី | |
| | ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃ កម្ពុជា | |
| | ធនាគារ វីង (ខេមបូឌា) ម.ក | |
| | ធនាគារ អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ម.ក | |
| | សាខាធនាគារ កសិកន ផាប់ប្លិក ខមភេនី លីមីធីត (ភ្នំពេញ) | |
| | ធនាគារ កាថេយូណៃធីត (ខេមបូឌា) ម.ក | |
| **សវនករ** | ក្រុមហ៊ុន ប្រាយវ៉តធ័រហោវខូភើស៍ (ខេមបូឌា) | |

**របាយការណ៍ក្រុមប្រឹក្សាភិបាល**

ក្រុមប្រឹក្សាភិបាលសូមបង្ហាញរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល និងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ តារា អ៊ិនស្ទួរិន ម.ក (ហៅកាត់ថា ក្រុមហ៊ុន) សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥។

**សកម្មភាពអាជីវកម្មចម្បង**

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺធ្វើប្រតិបត្តិការអាជីវកម្មធានារ៉ាប់រងទូទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**លទ្ធផលហិរញ្ញវត្ថុ**

| | ២០២៥ | | ២០២៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណេញមុនពន្ធលើប្រាក់ចំណូល | ៣០១.៧៦៤ | ១.២១០.៣៧៦ | ៤៦៦.១៥៩ | ១.៨៩៧.៧៣៣ |
| ចំណាយពន្ធលើប្រាក់ចំណូល | (៤២.៨៧៨) | (១៧១.៩៨៤) | (៥០.៧៨៨) | (២០៦.៧៥៨) |
| ចំណេញសុទ្ធក្នុងឆ្នាំ | ២៥៨.៨៨៦ | ១.០៣៨.៣៩២ | ៤១៥.៣៧១ | ១.៦៩០.៩៧៥ |

**ភាគលាភ**

ក្នុងអំឡុងការិយបរិច្ឆេទ មិនមានការប្រកាសភាគលាភ ឬ ទូទាត់ភាគលាភទេ ហើយក្រុមប្រឹក្សាភិបាលមិនបានផ្តល់អនុសាសន៍ឱ្យមានការទូទាត់ភាគលាភ ក្នុងការិយបរិច្ឆេទនេះទេ។

**ដើមទុន**

ក្នុងអំឡុងការិយបរិច្ឆេទហិរញ្ញវត្ថុមិនមានការផ្លាស់ប្តូរចំពោះដើមទុនចុះបញ្ជី និងដើមទុនបានបោះផ្សាយរបស់ក្រុមហ៊ុនទេ។

**ទុនបម្រុង និងសំវិធានធន**

ក្នុងអំឡុងការិយបរិច្ឆេទហិរញ្ញវត្ថុ រាល់បម្រែបម្រួលជាសារវន្តទាំងអស់ ចូលឬចេញពីគណនីទុនបម្រុង និងសំវិធានធន ត្រូវបានលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

**ប្រតិបត្តិការមិនប្រក្រតី**

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលប្រតិបត្តិការរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនបានទទួលរងនូវផលប៉ះពាល់ជាសារវន្តដោយ ខ្ទង់គណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍មិនប្រក្រតីណាមួយទេ។

## ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ដែលបានបំពេញតួនាទីក្នុងអំឡុងការិយបរិច្ឆេទ រហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ មានរាយនាមដូចខាងក្រោម ៖

- លោកស្រី លឹម លីណា — ប្រធានក្រុមប្រឹក្សាភិបាល
- លោក អ៊ូ សុផាណារិទ្ធ — អភិបាល
- លោកស្រី ហង្ស ចន្ធូ — អភិបាល
- លោក Yee Con Long — អភិបាល
- លោក Tanat Jakrawatana — អភិបាល
- លោក Chow Wey Ming — អភិបាលឯករាជ្យ
- លោក Leow Ming Fong — អភិបាលឯករាជ្យ
- លោកស្រី Jirayong Anuman-Rajadhon — អភិបាលឯករាជ្យ
- លោក Chan Lek Wei — អភិបាលឯករាជ្យ

## ចំណែកហ៊ុនរបស់អភិបាល

អភិបាលដែលបានបំពេញតួនាទីក្នុងក្រុមហ៊ុន នាចុងការិយបរិច្ឆេទហិរញ្ញវត្ថុ និងចំណែកភាគហ៊ុនរបស់ពួកគាត់នៅក្នុងក្រុមហ៊ុន មានដូចខាងក្រោម៖

| | ២០២៥ | | ២០២៤ | |
|---|---|---|---|---|
| | ចំនួនទឹកប្រាក់ ដុល្លារអាមេរិក | ភាគកាន់កាប់ ភាគហ៊ុន % | ចំនួនទឹកប្រាក់ ដុល្លារអាមេរិក | ភាគកាន់កាប់ ភាគហ៊ុន % |
| លោកស្រី លឹម លីណា | ៣.២០០.០០០ | ៤០ | ៣.២០០.០០០ | ៤០ |
| លោកស្រី ហង្ស ចន្ធូ | ២៤០.០០០ | ៣ | ២៤០.០០០ | ៣ |
| លោក អ៊ូ សុផាណារិទ្ធ | ១៦០.០០០ | ២ | ១៦០.០០០ | ២ |
| | ៣.៦០០.០០០ | ៤៥ | ៣.៦០០.០០០ | ៤៥ |

## អត្ថប្រយោជន៍របស់អភិបាល

ក្នុងអំឡុង និងនាចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានកិច្ចព្រមព្រៀងណាមួយដែលក្រុមហ៊ុនជាភាគី ហើយដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះ ផ្តល់លទ្ធភាពដល់អភិបាលរបស់ក្រុមហ៊ុន ឱ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ក្រុមហ៊ុន ឬសាជីវកម្មដទៃទៀតទេ។

លើកលែងតែអ្វីដែលបានលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ពុំមានអភិបាលណាម្នាក់របស់ក្រុមហ៊ុនបានទទួល ឬ មានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដូចបានលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យា ដែលធ្វើឡើងដោយក្រុមហ៊ុន ឬដោយសាជីវកម្មពាក់ព័ន្ធណាមួយជាមួយនឹងក្រុមហ៊ុនណាមួយ ដែលអភិបាលរូបនោះជាសមាជិកនៃក្រុមហ៊ុន ឬក្រុមហ៊ុនដែលអភិបាលរូបនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុជាសារវន្តនោះទេ។

# ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង និងបានបង្ហាញនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ៖

(i) អនុវត្តគោលការណ៍គណនេយ្យសមស្រប ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ស្មានដែលសមហេតុផល និងប្រុងប្រយ័ត្ន ហើយបន្ទាប់មកត្រូវអនុវត្តគោលការណ៍ទាំងនេះឱ្យមានសង្គតិភាព។

(ii) អនុលោមតាម ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ដែលដាក់ឱ្យប្រើប្រាស់ដោយនិយ័តករគណនេយ្យ និងសវនកម្ម (ACAR) សម្រាប់ក្រុមហ៊ុនធានារ៉ាប់រងក្នុងព្រះរាជាណាចក្រកម្ពុជា ឬប្រសិនបើមានការប្រាសចាកណាមួយក្នុងការបង្ហាញភាពពិត និងត្រឹមត្រូវ វាត្រូវលាតត្រដាង ពន្យល់ និងកំណត់ចំនួនទឹកប្រាក់ ឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

(iii) ធានាថាក្រុមហ៊ុនមានវិធានការត្រឹមត្រូវទាក់ទងនឹងការជម្រះបំណុលអាក្រក់ចេញពីបញ្ជី និងកត់ត្រាសំវិធានធនសម្រាប់ការខាតបង់ឥណទាន ហើយបានយល់ស្របថា រាល់បំណុលអាក្រក់ទាំងអស់ដែលបានដឹង ត្រូវបានជម្រះចេញពីបញ្ជី និងបានកត់ត្រាសំវិធានធនគ្រប់គ្រាន់សម្រាប់ការខាតបង់ឥណទាន។

(iv) ធានាថាទ្រព្យសកម្មរយៈពេលខ្លី ក្រៅពីបំណុល ដែលទំនងជាមិនអាចទទួលបានពីសកម្មភាពអាជីវកម្មធម្មតាតាមតម្លៃដូចបានកត់ត្រាក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ត្រូវបានកត់ត្រាបន្ថយតម្លៃឱ្យនៅស្មើនឹងតម្លៃដែលរំពឹងថាអាចប្រមូលបាន។

(v) វាយតម្លៃអំពីលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ការលាតត្រដាងព័ត៌មានដែលពាក់ព័ន្ធ ក៏ដូចជាបញ្ហាផ្សេងៗដែលទាក់ទិនទៅនឹងនិរន្តរភាពអាជីវកម្ម ដោយប្រើមូលដ្ឋានគណនេយ្យសម្រាប់និរន្តរភាពអាជីវកម្ម លើកលែងតែគណៈគ្រប់គ្រងមានគម្រោងបិទអាជីវកម្មរបស់ក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬដោយមិនមានជម្រើសណាផ្សេងប្រកបដោយភាពប្រាកដប្រជាណាមួយ និង

(vi) ត្រួតពិនិត្យលើដំណើរការនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរក្សាទុកកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ៖

(i) ដែលអាចធ្វើឱ្យចំនួនទឹកប្រាក់ដែលជម្រះចេញពីបញ្ជីសម្រាប់បំណុលអាក្រក់ ឬចំនួនសំវិធានធនសម្រាប់ការខាតបង់ឥណទាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានចំនួនមិនគ្រប់គ្រាន់ជាសារវន្តនោះទេ។

(ii) ដែលអាចធ្វើឱ្យតម្លៃទ្រព្យសកម្មរយៈពេលខ្លីនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មិនត្រឹមត្រូវនោះទេ។

(iii) ដែលបានកើតឡើង ហើយអាចធ្វើឱ្យវិធីសាស្ត្រវាយតម្លៃទ្រព្យសកម្មនិងបំណុលដែលមានស្រាប់ របស់ក្រុមហ៊ុនមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗរបស់ក្រុមហ៊ុនដែលត្រូវបានទាមទារឱ្យសង ឬអាចនឹងត្រូវបានទាមទារឱ្យសងក្នុងរយៈពេល១២ខែ បន្ទាប់ពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុ ដែលនឹង ឬអាចនឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅថ្ងៃដល់ពេលកំណត់សងនោះទេ។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ មិនមាន៖

ក. បន្ទុកណាមួយលើទ្រព្យសកម្មរបស់ក្រុមហ៊ុន ដែលបានកើតឡើងដោយសារការដាក់បញ្ចាំសម្រាប់ធានាបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុមក ឬ

ខ. បំណុលយថាហេតុណាមួយរបស់ក្រុមហ៊ុន ដែលបានកើតឡើងចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុមក ក្រៅពីបំណុលផ្សេងៗនៅក្នុងដំណើរការអាជីវកម្មធម្មតានោះទេ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលមិនបានដឹងពីកាលៈទេសៈណាមួយដែលមិនបានរែកញែកនៅក្នុងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលអាចបណ្តាលឱ្យចំនួនទឹកប្រាក់ដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានភាពមិនត្រឹមត្រូវនោះទេ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ៖

ក. លទ្ធផលប្រតិបត្តិការរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទនេះ មិនបានទទួលរងនូវផលប៉ះពាល់ជាសារវន្តដោយខ្ទង់គណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍មិនប្រក្រតីណាមួយទេ។

ខ. នៅចន្លោះពេលរវាងចុងការិយបរិច្ឆេទហិរញ្ញវត្ថុ រហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ មិនមាន ខ្ទង់គណនីប្រតិបត្តិការ ឬព្រឹត្តិការណ៍មិនប្រក្រតីណាមួយ ដែលអាចជះឥទ្ធិពលជាសារវន្តដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

*ចុះហត្ថលេខាដោយអនុលោមទៅតាមការអនុម័តរបស់ក្រុមប្រឹក្សាភិបាល៖*

ក្រុមហ៊ុន តារា អ៊ិនស្វូរិន ម.ក
DARA INSURANCE PLC.
KINGDOM OF CAMBODIA

**លោកស្រី ហាន់ ចន្ទ**
**អគ្គនាយិកា**

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៦

## សេចក្តីបញ្ជាក់របស់ក្រុមប្រឹក្សាភិបាល

យើងជាហត្ថលេខី តាងនាមឱ្យក្រុមប្រឹក្សាភិបាលរបស់ តារា អ៊ិនស្វូរិន ម.ក(ហៅកាត់ថា ក្រុមហ៊ុន) សូមបញ្ជាក់ថា តាមមតិយោបល់របស់យើង របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ រួមមាន របាយការណ៍ស្ថានភាពហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ របាយការណ៍បម្រែបម្រួល មូលធន របាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ ព្រមទាំងកំណត់សម្គាល់ រួមមាន ព័ត៌មាន គោលការណ៍គណនេយ្យជាសារវន្ត និងព័ត៌មានពន្យល់ផ្សេងៗទៀត បានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS) ដែលត្រូវបានដាក់ឱ្យអនុវត្តដោយនិយ័តករគណនេយ្យ និងសវនកម្ម (ACAR) សម្រាប់ក្រុមហ៊ុនធានារ៉ាប់រងនៅព្រះរាជាណាចក្រកម្ពុជា។

*ចុះហត្ថលេខាដោយអនុលោមទៅតាមការអនុម័តរបស់ក្រុមប្រឹក្សាភិបាល៖*

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន តារា អ៊ិនស្វូរិន ម.ក
DARA INSURANCE PLC.
KINGDOM OF CAMBODIA

លោកស្រី ឃាង ចន្ទ
អគ្គនាយិកា

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៦


+855 23 901 353
www.darainsurance.com.kh
enquiries@darainsurance.com.kh
Cambodia Post Bank Building
7th-8th Floor of Building No.263,
Corner of Street 110 (Preah Ang Doung) and Street 61 (Basac)
Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Cambodia.

**របាយការណ៍សវនករឯករាជ្យ**

ជូនភាគទុនិក តារា អ៊ិនស្វរិន ម.ក

**មតិយោបល់របស់យើងខ្ញុំ**

តាមមតិយោបល់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃ ស្ថានភាពហិរញ្ញវត្ថុរបស់ តារា អ៊ិនស្វរិន ម.ក (ហៅកាត់ថា ក្រុមហ៊ុន) គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ និងលទ្ធផល ហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃ កម្ពុជា (ហៅកាត់ថា CIFRS)។

របាយការណ៍ដែលយើងខ្ញុំបានធ្វើសវនកម្ម

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន រួមមាន៖

- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥
- របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗសម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍បម្រែបម្រួលមូលធនសម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍លំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ និង
- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ រួមទាំងព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត និងព័ត៌មានពន្យល់ផ្សេងៗទៀត។

**មូលដ្ឋាននៃមតិយោបល់របស់យើងខ្ញុំ**

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាម ស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា (ហៅកាត់ថា ស្តង់ដាសវនកម្ម)។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលអនុលោមទៅតាមស្តង់ដាទាំងនោះ ត្រូវបានពណ៌នាបន្ថែមទៀតនៅក្នុងកថាខណ្ឌ *ការទទួលខុសត្រូវរបស់សវនករក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ* នៅក្នុងរបាយការណ៍សវនកររបស់យើងខ្ញុំ។

យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំបានទទួល មានភាពគ្រប់គ្រាន់ និងសមហេតុផល ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

PricewaterhouseCoopers (Cambodia) Ltd.
P.O. Box 1147, 58C Sihanouk Blvd, Sangkat Tonle Bassac,
Khan Chamkarmon, Phnom Penh 120101
T: +855 (0)23/69 860 606

ឯករាជ្យ

យើងខ្ញុំមានឯករាជ្យពីក្រុមហ៊ុន ដែលអនុលោមទៅតាមតម្រូវការក្រមសីលធម៌ នៃក្រមសីលធម៌វិជ្ជាជីវៈ សម្រាប់គណនេយ្យករ និង សវនករកម្ពុជា (ហៅកាត់ថា ក្រមសីលធម៌ CPAA) រួមជាមួយនឹងវិធានឯករាជ្យរបស់និយ័តករ ធានារ៉ាប់រងកម្ពុជា (ហៅកាត់ថា នធក) ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មចំពោះរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពដែលមានការទទួលខុសត្រូវជាសាធារណៈ នៅក្នុងប្រទេសកម្ពុជា។ យើងខ្ញុំក៏បានបំពេញកាតព្វកិច្ចក្នុងការទទួលខុសត្រូវលើក្រមសីលធម៌ផ្សេងៗទៀត ដោយអនុលោមទៅតាមតម្រូវការនៃក្រមសីលធម៌ CPAA និង វិធានឯករាជ្យរបស់ នធក។

ព័ត៌មានផ្សេងៗ

គណៈគ្រប់គ្រងទទួលខុសត្រូវចំពោះព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗដែលយើងខ្ញុំបានទទួលនាកាលបរិច្ឆេទនៃរបាយការណ៍សវនករនេះ រួមមាន ព័ត៌មានអំពីក្រុមហ៊ុន របាយការណ៍ក្រុមប្រឹក្សាភិបាល និងសេចក្តីបញ្ជាក់របស់ក្រុមប្រឹក្សាភិបាល ប៉ុន្តែមិនរួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកររបស់យើងខ្ញុំទេ។

មតិយោបល់របស់យើងខ្ញុំចំពោះរបាយការណ៍ហិរញ្ញវត្ថុ ពុំបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗនោះទេ ហើយយើងខ្ញុំមិនធ្វើការធានាអះអាងចំពោះព័ត៌មានទាំងនោះទេ។

ទាក់ទងនឹងការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ យើងខ្ញុំទទួលខុសត្រូវក្នុងការអានព័ត៌មានផ្សេងៗ ដើម្បីពិចារណាថាតើព័ត៌មានផ្សេងៗទាំងនោះមានភាពផ្ទុយគ្នាជាសារវន្តពីរបាយការណ៍ហិរញ្ញវត្ថុ ឬផ្ទុយពីការយល់ដឹងរបស់យើងខ្ញុំផ្អែកលើលទ្ធផលនៃការធ្វើសវនកម្ម ឬមានការរាយការណ៍ពីកំហុសឆ្គងជាសារវន្តដែលបានកើតឡើងឬទេ។

ផ្អែកទៅលើការងារដែលយើងខ្ញុំបានបំពេញលើព័ត៌មានផ្សេងៗដែលយើងខ្ញុំបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនករនេះ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តដែលកើតចេញពីព័ត៌មានផ្សេងៗទាំងនេះ យើងខ្ញុំត្រូវរាយការណ៍ពីអង្គហេតុនៃកំហុសឆ្គងទាំងនោះ។ យើងខ្ញុំមិនមានអ្វីត្រូវរាយការណ៍ចំពោះបញ្ហានេះទេ។

**ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងអ្នកដែលទទួលបន្ទុកលើអភិបាលកិច្ចចំពោះរបាយការណ៍ហិរញ្ញវត្ថុ**

គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងបង្ហាញរបាយការណ៍ទាំងនោះឱ្យបានត្រឹមត្រូវ ដោយអនុលោមទៅតាម CIFRS និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យចៀសផុតពីការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការវាយតម្លៃអំពីលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ការលាតត្រដាងព័ត៌មានដែលពាក់ព័ន្ធ ក៏ដូចជាបញ្ហាផ្សេងៗដែលទាក់ទិនទៅនឹងនិរន្តរភាពអាជីវកម្ម ដោយប្រើមូលដ្ឋានគណនេយ្យសម្រាប់និរន្តរភាពអាជីវកម្ម លើកលែងតែគណៈគ្រប់គ្រងមានគម្រោងបិទអាជីវកម្មរបស់ក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬដោយមិនមានជម្រើសណាផ្សេងប្រកបដោយភាពប្រាកដប្រជាណាមួយ។

អ្នកដែលទទួលបន្ទុកលើអភិបាលកិច្ច ទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការនៃការរាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

**ការទទួលខុសត្រូវរបស់សវនករ ក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ**

គោលបំណងរបស់យើងខ្ញុំ គឺស្វែងរកអំណះអំណាងដែលសមហេតុផល ថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលពុំមានការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ និងចេញរបាយការណ៍សវនករដែលមានមតិយោបល់របស់យើងខ្ញុំ។ អំណះអំណាងដែលសមហេតុផលគឺជាការអះអាងក្នុងកម្រិតខ្ពស់ ប៉ុន្តែវាមិនមែនជាការធានាថាសវនកម្មដែលបានធ្វើឡើងដោយអនុលោមទៅតាមស្តង់ដាសវនកម្ម តែងតែរកឃើញជានិច្ចនូវការរាយការណ៍ខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការរាយការណ៍ខុសអាចកើតឡើងពីការក្លែងបន្លំ ឬកំហុសឆ្គង ហើយវាត្រូវបានចាត់ទុកថាមានលក្ខណៈជាសារវន្ត ប្រសិនបើការរាយការណ៍ខុសនីមួយៗ ឬការរាយការណ៍ខុសសរុប អាចត្រូវបានរំពឹងថាវាជះឥទ្ធិពលលើមូលដ្ឋាននៃការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

ផ្នែកមួយនៃការធ្វើសវនកម្មដែលអនុលោមទៅតាមស្តង់ដាសវនកម្ម តម្រូវឱ្យយើងខ្ញុំប្រើប្រាស់ការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈ និងរក្សាការសង្ស័យស្របតាមវិជ្ជាជីវៈ ក្នុងពេលបំពេញការងារសវនកម្មរបស់យើងខ្ញុំ។ យើងខ្ញុំ៖

- កំណត់ និងវាយតម្លៃហានិភ័យនៃភាពខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលអាចបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ ដោយតាក់តែងនីតិវិធីសវនកម្ម និងធ្វើសវនកម្មដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងស្វែងរកភស្តុតាងសវនកម្មគ្រប់គ្រាន់និងសមស្រប ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលបណ្តាលមកពីការរកមិនឃើញកំហុសឆ្គងជាសារវន្តពីការក្លែងបន្លំ វាមានទំហំធំជាងហានិភ័យដែលបណ្តាលមកពីកំហុសឆ្គងអចេតនា ដោយសារការក្លែងបន្លំរួមមាន ការសមគំនិត ការក្លែងបន្លំឯកសារ ការលុបបំបាត់ដោយចេតនា ការបង្ហាញខុស ឬការរំលងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធទៅនឹងសវនកម្ម ដើម្បីតាក់តែងនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនបញ្ចេញមតិយោបល់របស់យើងខ្ញុំ ទៅលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុនទេ។
- វាយតម្លៃអំពីភាពសមស្របនៃគោលការណ៍គណនេយ្យដែលបានប្រើប្រាស់ ភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការលាតត្រដាងពាក់ព័ន្ធ ដែលគណៈគ្រប់គ្រងបានធ្វើឡើង។
- សន្និដ្ឋានលើភាពសមស្រប នៃការប្រើប្រាស់មូលដ្ឋានគណនេយ្យនិរន្តរភាពអាជីវកម្មរបស់គណៈគ្រប់គ្រងអាស្រ័យទៅលើភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន ថាតើវាមានភាពមិនច្បាស់លាស់ជាសារវន្តដែលបានកើតឡើងកម្រិតណា ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានា ដែលអាចបណ្តាលឱ្យមានការសង្ស័យជាដុំកំភួនទៅលើលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្មរបស់ខ្លួនដែរឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា វាមានភាពមិនច្បាស់លាស់ជាសារវន្តបានកើតឡើង នោះយើងខ្ញុំត្រូវធ្វើការបង្ហាញនៅក្នុងរបាយការណ៍សវនករ ដើម្បីទាញចំណាប់អារម្មណ៍អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុចំពោះការលាតត្រដាងព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងនោះនៅមិនទាន់គ្រប់គ្រាន់ទៀត យើងខ្ញុំត្រូវធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ សេចក្តីសន្និដ្ឋានសរុបរបស់យើងខ្ញុំ អាស្រ័យទៅលើភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន រហូតដល់ថ្ងៃចុះហត្ថលេខាលើរបាយការណ៍សវនករនេះ។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានាក្នុងពេលអនាគត អាចបណ្តាលឱ្យក្រុមហ៊ុនឈប់បន្តនិរន្តរភាពអាជីវកម្ម។

- វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងខ្លឹមសារក្នុងរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងការលាតត្រដាងព័ត៌មានផ្សេងៗ និង កំណត់ថារបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ជាក់ស្តែង ដែលអាចធ្វើឱ្យមានការបង្ហាញត្រឹមត្រូវ។

យើងខ្ញុំបានរាយការណ៍ជូនអ្នកដែលទទួលបន្ទុកអភិបាលកិច្ចនូវបញ្ហាផ្សេងៗដូចជា ទំហំការងារតាមផែនការ និងពេលវេលាសវនកម្ម ព្រមទាំងបញ្ហាសវនកម្មសំខាន់ៗ រួមទាំងរាយការណ៍ពីភាពខ្វះខាតជាសារវន្តក្នុងការគ្រប់គ្រងផ្ទៃក្នុង ដែលយើងខ្ញុំបានរកឃើញក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំ។

ជ. ក្រុមហ៊ុន ប្រាយវ៉តធ័រហោវខូភើស៍ (ខេមបូឌា)

ហង្សស្រូផាត ម៉ូលីហ្សាណា

Partner

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៦

## តារា អ៊ិនស្ទីរិន ម.ក

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
# គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

| | កំណត់ | ២០២៥ | | ២០២៤ | |
|---|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | | |
| ប្រាក់តម្កល់ធានាអាជីវកម្ម | ៤ | ៧០០.០០០ | ២.៨០៩.១០០ | ៧០០.០០០ | ២.៨១៧.៥០០ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ៥ | ១០០.៧២០ | ៤០៤.១៨៩ | ៩៦.៤៨០ | ៣៨៨.៣៣២ |
| ទ្រព្យសកម្មអរូបី | ៦ | ៩៣.៨៨៦ | ៣៧៦.៧៦៥ | ៩១.០៩៧ | ៣៦៦.៦៦៥ |
| សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម | ៧(ក) | ៤៩៤.៤៣០ | ១.៩៨៤.១៤៨ | ៤៩២.៩៣៩ | ១.៩៨៤.០៧៩ |
| ទ្រព្យសកម្មធានារ៉ាប់រងបន្ត | ១២ | ៣.៨២៩.២៨៤ | ១៥.៣៦៦.៩១៧ | ២.២៤៨.២០៧ | ៩.០៤៩.០៣៣ |
| គណនីធានារ៉ាប់រងត្រូវទទួល និង<br>គណនីត្រូវទទួលផ្សេងៗ | ៨ | ២.៣០៣.៣៤៤ | ៩.២៤៣.៣១៩ | ៨៨៣.៩១៤ | ៣.៥៥៧.៧៥៤ |
| ការវិនិយោគផ្សេងៗ | ៩ | ៨.០៤៤.៣៣៨ | ៣២.២៨១.៩២៨ | ៧.៥២៦.៦៦៤ | ៣០.២៩៤.៨២៣ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១០ | ១.៨៦៥.៣០៦ | ៧.៤៨៥.៤៧៣ | ៩០២.៦៤៩ | ៣.៦៣៣.១៦២ |
| **ទ្រព្យសកម្មសរុប** | | ១៧.៤៣១.៣០៨ | ៦៩.៩៥១.៨៣៩ | ១២.៩៤១.៩៥០ | ៥២.០៩១.៣៤៨ |
| **មូលធន និងបំណុល** | | | | | |
| **មូលធន** | | | | | |
| ដើមទុន | ១១ | ៨.០០០.០០០ | ៣២.០០០.០០០ | ៨.០០០.០០០ | ៣២.០០០.០០០ |
| ប្រាក់ចំណេញរក្សាទុក | | ៦៥៧.២៤៤ | ២.៦៨៧.៥៥២ | ៣៩៨.៣៥៨ | ១.៦៤៩.១៦០ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | ៥៣.៩៦៨ | - | ១៥៤.២៣១ |
| **មូលធនសរុប** | | ៨.៦៥៧.២៤៤ | ៣៤.៧៤១.៥២០ | ៨.៣៩៨.៣៥៨ | ៣៣.៨០៣.៣៩១ |
| **បំណុល** | | | | | |
| បំណុលកិច្ចសន្យាធានារ៉ាប់រង | ១២ | ៤.៣២៤.០៤៥ | ១៧.៣៥២.៣៩៣ | ២.៧២២.៧៦០ | ១០.៩៥៩.១០៨ |
| គណនីធានារ៉ាប់រងត្រូវទូទាត់ និងគណនីត្រូវទូទាត់ផ្សេងៗ | ១៣ | ៣.៨១៧.១៩១ | ១៥.៣១៨.៣៨៧ | ១.២៤១.១៨៨ | ៤.៩៩៥.៧៨២ |
| បំណុលភតិសន្យា | ៧(ខ) | ៥៦១.០៤០ | ២.២៥១.៤៥៤ | ៥៤០.៤៣៤ | ២.១៧៥.២៤៧ |
| បំណុលពន្ធលើប្រាក់ចំណូល | ១៥(ខ) | ៧១.៧៨៨ | ២៨៨.០៨៥ | ៣៩.២១០ | ១៥៧.៨២០ |
| **បំណុលសរុប** | | ៨.៧៧៤.០៦៤ | ៣៥.២១០.៣១៩ | ៤.៥៤៣.៥៩២ | ១៨.២៨៧.៩៥៧ |
| **មូលធននិងបំណុលសរុប** | | ១៧.៤៣១.៣០៨ | ៦៩.៩៥១.៨៣៩ | ១២.៩៤១.៩៥០ | ៥២.០៩១.៣៤៨ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# ធនាគារ អ៊ិនស្ទែន ម.ក

## របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

| | កំណត់សម្គាល់ | ២០២៥ ដុល្លារអាមេរិក | ២០២៥ ពាន់រៀល | ២០២៤ ដុល្លារអាមេរិក | ២០២៤ ពាន់រៀល |
|---|---|---|---|---|---|
| ចំណូលបុព្វលាភធានារ៉ាប់រងដុល | | ៦.៦១៨.៦០១ | ២៦.៥៤៧.២០៩ | ៤.០៣៥.៩៣១ | ១៦.៤៣០.២៧៥ |
| បុព្វលាភធានារ៉ាប់រងបន្ត | | (៥.៧៩១.៥៤៣) | (២៣.២២៩.៨៧៩) | (៣.២៥៨.៥២២) | (១៣.២៦៥.៤៤៣) |
| ចំណូលបុព្វលាភធានារ៉ាប់រងសុទ្ធ | | ៨២៧.០៥៨ | ៣.៣១៧.៣៣០ | ៧៧៧.៤០៩ | ៣.១៦៤.៨៣២ |
| បម្រែបម្រួលលើប្រាក់បម្រុងបុព្វលាភធានារ៉ាប់រងមិនទាន់ចាត់ទុកជាចំណូល/ប្រាក់បម្រុងគណិតវិទ្យា | ១២ | (១.៥៥២.៤៧៩) | (៦.២២៦.៩៩៣) | ២៨៣.៥៣១ | ១.១៥៤.២៥៥ |
| បម្រែបម្រួលនៃចំណែកធានារ៉ាប់រងបន្តលើប្រាក់បម្រុងបុព្វលាភធានារ៉ាប់រងមិនទាន់ចាត់ទុកជាចំណូល/ ប្រាក់បម្រុងគណិតវិទ្យា | ១២ | ១.៥៣៧.៧៤៧ | ៦.១៦៧.៩០៣ | (៣០៩.៣៦៧) | (១.២៥៩.៤៣៣) |
| **ចំណូលបុព្វលាភធានារ៉ាប់រងសុទ្ធបានទទួលស្គាល់** | | ៨១២.៣២៦ | ៣.២៥៨.២៤០ | ៧៥១.៥៧៣ | ៣.០៥៩.៦៥៤ |
| ចំណូលកម្រៃជើងសាពីក្រុមហ៊ុនធានារ៉ាប់រងបន្ត | | ៩០០.៨៥៩ | ៣.៦១៣.៣៤៥ | ៨៥៦.២០៤ | ៣.៤៨៥.៦០៦ |
| ចំណូលធានារ៉ាប់រងផ្សេងៗ | | ៦.០៨៩ | ២៤.៤២៣ | ១.២០៨ | ៤.៩១៨ |
| **ចំណូលសុទ្ធពីអាជីវកម្មធានារ៉ាប់រង** | | ១.៧១៩.២៧៤ | ៦.៨៩៦.០០៨ | ១.៦០៨.៩៨៥ | ៦.៥៥០.១៧៨ |
| ចំណូលការប្រាក់ | | ៤៧៥.៧៥៥ | ១.៩០៨.២៥៣ | ៤៨៤.៥១២ | ១.៩៧២.៤៤៨ |
| ចំណូលផ្សេងៗ | | ៤.៣៣៤ | ១៧.៣៨៤ | ៥៩.៥៩៤ | ២៤២.៦០៧ |
| **ចំណូលប្រតិបត្តិការសរុប** | | ២.១៩៩.៣៦៣ | ៨.៨២១.៦៤៥ | ២.១៥៣.០៩១ | ៨.៧៦៥.២៣៣ |
| សំណងធានារ៉ាប់រងដុលបានទូទាត់ | | (១.៥៣៥.០២០) | (៦.១៥៦.៩៦៥) | (៥៧៤.៨៥៩) | (២.៣៤០.២៥១) |
| ចំណែកនៃសំណងធានារ៉ាប់រងដែលបានទូទាត់របស់ក្រុមហ៊ុនធានារ៉ាប់រងបន្ត | | ១.៣៧៩.៨៦៩ | ៥.៥៣៤.៦៥៥ | ៤៦៧.០៤១ | ១.៩០១.៣២៤ |
| បម្រែបម្រួលដុលនៃបំណុលកិច្ចសន្យាធានារ៉ាប់រង | ១២ | (៤៨.៨០៦) | (១៩៥.៧៦១) | (១០.១២៩) | (៤១.២៣៥) |
| បម្រែបម្រួលបំណុលកិច្ចសន្យាធានារ៉ាប់រងផ្ទេរឱ្យក្រុមហ៊ុនធានារ៉ាប់រងបន្ត | ១២ | ៤៣.៣៣០ | ១៧៣.៧៩៧ | ៦.៩៣៨ | ២៨.២៤៥ |
| **សំណងធានារ៉ាប់រងសុទ្ធបានកើតឡើង** | | (១៦០.៦២៧) | (៦៤៤.២៧៤) | (១១១.០០៩) | (៤៥១.៩១៧) |
| ចំណាយកម្រៃជើងសា | | (១៧៥.៥៥៩) | (៧០៤.១៦៧) | (១១៥.៩៧៥) | (៤៧២.១៣៤) |
| ចំណាយទាក់ទងនឹងសេវាធានារ៉ាប់រង | | (១០២.៨៩៣) | (៤១២.៧០៤) | (១១៧.៤៦៦) | (៤៧៨.២០៤) |
| ចំណាយប្រតិបត្តិការផ្សេងៗ | ១៤ | (១.៤០៩.៧៤២) | (៥.៦៥៤.៤៧៥) | (១.២៩២.១៧៨) | (៥.២៦០.៤៥៧) |
| ចំណាយហិរញ្ញវត្ថុ | ៧(ខ) | (៤៨.៧៧៨) | (១៩៥.៦៤៩) | (៥០.៣០៤) | (២០៤.៧៨៨) |
| **ចំណាយធានារ៉ាប់រង និងចំណាយពាក់ព័ន្ធ** | | (១.៧៣៦.៩៧២) | (៦.៩៦៦.៩៩៥) | (១.៥៧៥.៩២៣) | (៦.៤១៥.៥៨៣) |
| **ចំណេញមុនពន្ធលើប្រាក់ចំណូល** | | ៣០១.៧៦៤ | ១.២១០.៣៧៦ | ៤៦៦.១៥៩ | ១.៨៩៧.៧៣៣ |
| ចំណាយពន្ធលើប្រាក់ចំណូល | ១៥(គ) | (៤២.៨៧៨) | (១៧១.៩៨៤) | (៥០.៧៨៨) | (២០៦.៧៥៨) |
| **ចំណេញសុទ្ធក្នុងឆ្នាំ** | | ២៥៨.៨៨៦ | ១.០៣៨.៣៩២ | ៤១៥.៣៧១ | ១.៦៩០.៩៧៥ |
| **ចំណូលលម្អិតផ្សេងៗ** | | | | | |
| *ខ្ទង់ដែលមិនត្រូវចាត់ថ្នាក់ឡើងវិញក្នុងចំណេញ-ខាត* | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (១០០.២៦៣) | - | (៤៩៨.០៨៦) |
| **ចំណូលលម្អិតសរុបក្នុងឆ្នាំ** | | ២៥៨.៨៨៦ | ៩៣៨.១២៩ | ៤១៥.៣៧១ | ១.១៩២.៨៨៩ |
| **ចំណេញបែងចែកឱ្យម្ចាស់ក្រុមហ៊ុន** | | ២៥៨.៨៨៦ | ១.០៣៨.៣៩២ | ៤១៥.៣៧១ | ១.៦៩០.៩៧៥ |
| **ចំណូលលម្អិតសរុបបែងចែកឱ្យម្ចាស់ក្រុមហ៊ុន** | | ២៥៨.៨៨៦ | ៩៣៨.១២៩ | ៤១៥.៣៧១ | ១.១៩២.៨៨៩ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ធនាគារ អ៊ិនស្វើរិន ម.ក

## របាយការណ៍បម្រែបម្រួលមូលធន
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

| | ជារបស់ម្ចាស់ក្រុមហ៊ុន | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ដើមទុន | | ប្រាក់ចំណេញរក្សាទុក | | ប្រាក់បម្រុងសម្រាប់ការប្តូររូបិយប័ណ្ណ | | សរុប | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥** | | | | | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០២៥ | ៨.០០០.០០០ | ៣២.០០០.០០០ | ៣៩៨.៣៥៨ | ១.៦៤៩.១៦០ | - | ១៥៤.២៣១ | ៨.៣៩៨.៣៥៨ | ៣៣.៨០៣.៣៩១ |
| *ចំណូលលម្អិត៖* | | | | | | | | |
| ចំណេញសុទ្ធក្នុងឆ្នាំ | - | - | ២៥៨.៨៨៦ | ១.០៣៨.៣៩២ | - | - | ២៥៨.៨៨៦ | ១.០៣៨.៣៩២ |
| *ចំណូលលម្អិតផ្សេងៗ៖* | | | | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | (១០០.២៦៣) | - | (១០០.២៦៣) |
| ចំណូលលម្អិតសរុបក្នុងឆ្នាំ | - | - | ២៥៨.៨៨៦ | ១.០៣៨.៣៩២ | - | (១០០.២៦៣) | ២៥៨.៨៨៦ | ៩៣៨.១២៩ |
| សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ | ៨.០០០.០០០ | ៣២.០០០.០០០ | ៦៥៧.២៤៤ | ២.៦៨៧.៥៥២ | - | ៥៣.៩៦៨ | ៨.៦៥៧.២៤៤ | ៣៤.៧៤១.៥២០ |
| **សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤** | | | | | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤ | ៨.០០០.០០០ | ៣២.០០០.០០០ | (១៧.០១៣) | (៤១.៨១៥) | - | ៦៥២.៣១៧ | ៧.៩៨២.៩៨៧ | ៣២.៦១០.៥០២ |
| *ចំណូលលម្អិត៖* | | | | | | | | |
| ចំណេញសុទ្ធក្នុងឆ្នាំ | - | - | ៤១៥.៣៧១ | ១.៦៩០.៩៧៥ | - | - | ៤១៥.៣៧១ | ១.៦៩០.៩៧៥ |
| *ចំណូលលម្អិតផ្សេងៗ៖* | | | | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | (៤៩៨.០៨៦) | - | (៤៩៨.០៨៦) |
| ចំណូលលម្អិតសរុបក្នុងឆ្នាំ | - | - | ៤១៥.៣៧១ | ១.៦៩០.៩៧៥ | - | (៤៩៨.០៨៦) | ៤១៥.៣៧១ | ១.១៩២.៨៨៩ |
| សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | ៨.០០០.០០០ | ៣២.០០០.០០០ | ៣៩៨.៣៥៨ | ១.៦៤៩.១៦០ | - | ១៥៤.២៣១ | ៨.៣៩៨.៣៥៨ | ៣៣.៨០៣.៣៩១ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# តារា អ៊ិនស្ទួរិន ម.ក

## របាយការណ៍លំហូរសាច់ប្រាក់
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

| | កំណត់ | ២០២៥ | | ២០២៤ | |
|---|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ចំណេញសុទ្ធក្នុងឆ្នាំ | | ២៥៨.៨៨៦ | ១.០៣៨.៣៩២ | ៤១៥.៣៧១ | ១.៦៩០.៩៧៥ |
| *និយ័តកម្ម៖* | | | | | |
| រំលស់ទ្រព្យសម្បត្តិនិងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី | ១៤ | ១១៤.០៤៤ | ៤៥៧.៤៣០ | ១១៦.៧៩៨ | ៤៧៥.៤៨៥ |
| ចំណូលការប្រាក់ | | (៤៧៥.៧៥៥) | (១.៩០៨.២៥៣) | (៤៨៤.៥១២) | (១.៩៧២.៤៤៨) |
| ចំណាយការប្រាក់ – ភតិសន្យា | ៧(ខ) | ៤៨.៧៧៨ | ១៩៥.៦៤៩ | ៥០.៣០៤ | ២០៤.៧៨៨ |
| ចំណាយពន្ធលើប្រាក់ចំណូល | ១៥(គ) | ៤២.៨៧៨ | ១៧១.៩៨៤ | ៥០.៧៨៨ | ២០៦.៧៥៨ |
| (ខាត)/ចំណេញប្រតិបត្តិការមុនបម្រែបម្រួលដើមទុនបង្វិល | | (១១.១៦៩) | (៤៤.៧៩៨) | ១៤៨.៧៤៩ | ៦០៥.៥៥៨ |
| *បម្រែបម្រួលបម្រែបម្រួលដើមទុនបង្វិល៖* | | | | | |
| គណនីធានារ៉ាប់រងត្រូវទទួល និងគណនីត្រូវទទួលផ្សេងៗ | | (១.៤១៩.៤៣០) | (៥.៦៩៣.៣៣៤) | (២០៥.០៤៣) | (៨៣៤.៧៣០) |
| ទ្រព្យសកម្មធានារ៉ាប់រងបន្ត | | (១.៥៨១.០៧៧) | (៦.៣៤១.៧០០) | ៣០២.៤២៩ | ១.២៣១.១៨៨ |
| បំណុលកិច្ចសន្យាធានារ៉ាប់រង | | ១.៦០១.២៨៥ | ៦.៤២២.៧៥៤ | (២៧៣.៤០២) | (១.១១៣.០២០) |
| គណនីធានារ៉ាប់រងត្រូវទូទាត់ និងគណនីត្រូវទូទាត់ផ្សេងៗ | | ២.៥៧៦.០០៣ | ១០.៣៣២.៣៤៨ | ២៦៨.៦៣១ | ១.០៩៣.៥៩៧ |
| សាច់ប្រាក់ទទួលបានពីប្រតិបត្តិការ | | ១.១៦៥.៦១២ | ៤.៦៧៥.២៧០ | ២៤១.៣៦៤ | ៩៨២.៥៩៣ |
| ពន្ធលើប្រាក់ចំណូលបានបង់ | ១៥(ខ) | (២៩៩.២២២) | (១.២០០.១៧៩) | (១៨៥.៣០២) | (៧៥៤.៣៦៤) |
| ពន្ធលើប្រាក់ចំណូលបានទទួលពីក្រុមហ៊ុនធានារ៉ាប់រងបន្ត | ១៥(គ) | ២៨៨.៩២២ | ១.១៥៨.៨៦៦ | ១៦២.៩២៨ | ៦៦៣.២៧៨ |
| ការប្រាក់បានបង់ | | (៤៨.៧៧៨) | (១៩៥.៦៤៩) | (៥០.៣០៤) | (២០៤.៧៨៨) |
| សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពប្រតិបត្តិការ | | ១.១០៦.៥៣៤ | ៤.៤៣៨.៣០៨ | ១៦៨.៦៨៦ | ៦៨៦.៧១៩ |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | ៥ | (៣៤.២៧០) | (១៣៧.៤៥៧) | (៣៦.៣៨៣) | (១៤៨.១១៥) |
| ការទិញទ្រព្យសកម្មអរូបី | ៦ | (២៥.០០០) | (១០០.២៧៥) | - | - |
| ប្រាក់បញ្ញើមានកាលកំណត់នៅធនាគារ | | ១១២.៤១៥ | ៤៥០.៨៩៧ | ៤៨១.១៦៩ | ១.៩៥៨.៨៣៩ |
| ការវិនិយោគសញ្ញាប័ណ្ណសាជីវកម្ម | | (១.០០០.០០០) | (៤.០១១.០០០) | - | - |
| ការប្រាក់បានទទួល | | ៨៤៥.៦៦៧ | ៣.៣៩១.៩៧០ | ១១២.២២៣ | ៤៥៦.៨៦០ |
| សាច់ប្រាក់សុទ្ធ(ប្រើប្រាស់ក្នុង)/ទទួលបានពីសកម្មភាពវិនិយោគ | | (១០១.១៨៨) | (៤០៥.៨៦៥) | ៥៥៧.០០៩ | ២.២៦៧.៥៨៤ |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| ការទូទាត់ប្រាក់ដើមនៃបំណុលភតិសន្យា | ៧(ខ) | (៤២.៦៨៩) | (១៧១.២២៦) | (៣៣.៦៩៦) | (១៣៧.១៧៦) |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពហិរញ្ញប្បទាន | | (៤២.៦៨៩) | (១៧១.២២៦) | (៣៣.៦៩៦) | (១៣៧.១៧៦) |
| កំណើនសាច់ប្រាក់និងសាច់ប្រាក់សមមូលសុទ្ធ | | ៩៦២.៦៥៧ | ៣.៨៦១.២១៧ | ៦៩១.៩៩៩ | ២.៨១៧.១២៧ |
| សាច់ប្រាក់និងសាច់ប្រាក់សមមូលនាដើមឆ្នាំ | | ៩០២.៦៤៩ | ៣.៦៣៣.១៦២ | ២១០.៦៥០ | ៨៦០.៥០៥ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (៨.៩០៦) | - | (៤៤.៤៧០) |
| **សាច់ប្រាក់និងសាច់ប្រាក់សមមូលនាដំណាច់ឆ្នាំ** | ១០ | ១.៨៦៥.៣០៦ | ៧.៤៨៥.៤៧៣ | ៩០២.៦៤៩ | ៣.៦៣៣.១៦២ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

**តារា អ៊ិនស្វឺរិន ម.ក**

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

### ១. អំពីក្រុមហ៊ុន

តារា អ៊ិនស្វឺរិន ម.ក (ហៅកាត់ថា ក្រុមហ៊ុន) បានចុះបញ្ជីជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ក្នុងប្រទេសកម្ពុជា ដែលមានអត្តលេខចុះបញ្ជីលេខ ០០០៣៤៦៨៦ ចេញដោយក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨។

ក្រុមហ៊ុនបានចាប់ផ្តើមប្រតិបត្តិការអាជីវកម្ម នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៩ ក្រោមអាជ្ញាប័ណ្ណដែលផ្តល់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានសុពលភាព៥ឆ្នាំ ចាប់ពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ ដល់ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៣។ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណអចិន្ត្រៃយ៍ពីនិយ័តករធានារ៉ាប់រងកម្ពុជា។

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺធ្វើប្រតិបត្តិការអាជីវកម្មធានារ៉ាប់រងទូទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

អាសយដ្ឋានចុះបញ្ជីរបស់ក្រុមហ៊ុន មានទីតាំងស្ថិតនៅ ជាន់ទី៧ ជាន់ទី៨ ផ្ទះលេខ ២៦៣ ផ្លូវលេខ ១១០ (ផ្លូវព្រះអង្គឌួង) កែងនឹងផ្លូវលេខ ៦១ (បាសាក់) សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រុមប្រឹក្សាភិបាលបានអនុម័តឱ្យចេញផ្សាយរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៦។

### ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត

### ២.១ មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

### ក. របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងដោយអនុលោមតាម ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា (CIFRS) ដែលដាក់ឱ្យប្រើប្រាស់ដោយនិយ័តករគណនេយ្យ និងសវនកម្ម (ហៅកាត់ថា ACAR) សម្រាប់ក្រុមហ៊ុនធានារ៉ាប់រងក្នុងព្រះរាជាណាចក្រកម្ពុជា។

### ខ. មូលដ្ឋាននៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង តាមមូលដ្ឋានថ្លៃដើម លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

### គ. រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ

រូបិយវត្ថុជាតិនៃព្រះរាជាណាចក្រកម្ពុជាគឺ ប្រាក់រៀល។ ប៉ុន្តែ ដោយសារក្រុមហ៊ុនធ្វើប្រតិបត្តិការ និងរក្សាកំណត់ត្រាបញ្ជីគណនេយ្យរបស់ខ្លួនជាប្រាក់ដុល្លារអាមេរិក គណៈគ្រប់គ្រងបានកំណត់យកប្រាក់ដុល្លារអាមេរិកជា រូបិយប័ណ្ណគោលរបស់ក្រុមហ៊ុន ដោយសារប្រាក់ដុល្លារអាមេរិកឆ្លុះបញ្ចាំងពីព័ត៌មានសេដ្ឋកិច្ចនៃព្រឹត្តិការណ៍សំខាន់ៗ និងស្ថានភាពរបស់ក្រុមហ៊ុន។

របាយការណ៍ហិរញ្ញវត្ថុនេះត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណគោល និងរូបិយប័ណ្ណបង្ហាញរបស់ក្រុមហ៊ុន។

ចំនួនទឹកប្រាក់ទាំងអស់ត្រូវបានជាចំនួនគត់ ជាប្រាក់ដុល្លារអាមេរិក លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)
## ២.១ មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)
## ឃ. ការប្រើប្រាស់ការវិនិច្ឆ័យ និងការប៉ាន់ស្មាន

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ គណៈគ្រប់គ្រងបានធ្វើការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មត ដែលមានផលប៉ះពាល់ដល់ការអនុវត្តគោលការណ៍គណនេយ្យ និងចំនួនទ្រព្យសកម្ម បំណុល ចំណូល និងចំណាយដែលបានរាយការណ៍។ លទ្ធផលជាក់ស្តែងអាចខុសពីការប៉ាន់ស្មានទាំងនេះ។

ការប៉ាន់ស្មាន និងការសន្មតជាមូលដ្ឋានត្រូវបានត្រួតពិនិត្យជាប្រចាំ។ ការកែប្រែចំពោះការប៉ាន់ស្មានត្រូវបានទទួលស្គាល់តាមមូលដ្ឋានទៅពេលខាងមុខ។

ការប៉ាន់ស្មានសំខាន់ៗរួមមាន បំណុលកិច្ចសន្យាធានារ៉ាប់រង។ ការកំណត់បំណុលកិច្ចសន្យាធានារ៉ាប់រងគឺអាស្រ័យលើការសន្មតនានាដែលធ្វើឡើងដោយគណៈគ្រប់គ្រងរបស់ក្រុមហ៊ុន។ ការប៉ាន់ស្មានទាំងនេះត្រូវបានត្រួតពិនិត្យ និងកែតម្រូវ (ប្រសិនបើចាំបាច់) ជារៀងរាល់ឆ្នាំ ដើម្បីកត់ត្រាបំណុលកិច្ចសន្យា ដែលឆ្លុះបញ្ចាំងពីការប៉ាន់ស្មានដ៏សុក្រឹតបំផុត (កំណត់សម្គាល់ ៣)។

### ការវិនិច្ឆ័យ

ព័ត៌មានអំពីការវិនិច្ឆ័យដែលត្រូវបានធ្វើឡើង ក្នុងការអនុវត្តគោលការណ៍គណនេយ្យ ដែលមានផលប៉ះពាល់ជាសារវន្ត ចំពោះចំនួនទឹកប្រាក់ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរួមបញ្ចូលនៅក្នុងកំណត់សម្គាល់ខាងក្រោម៖

- កំណត់សម្គាល់ ១២ – បំណុលកិច្ចសន្យាធានារ៉ាប់រង ៖ ការកំណត់បំណុលកិច្ចសន្យាធានារ៉ាប់រង គឺផ្អែកទៅលើការសន្មតដែលគណៈគ្រប់គ្រងក្រុមហ៊ុនបានធ្វើឡើង។ ការប៉ាន់ស្មានទាំងនេះ ត្រូវបានត្រួតពិនិត្យ និងកែតម្រូវ (ប្រសិនបើចាំបាច់) ក្នុងការិយបរិច្ឆេទនីមួយៗ ដើម្បីកត់ត្រាបំណុលក្នុងកិច្ចសន្យាដែលឆ្លុះបញ្ចាំងនូវការសន្មតដ៏សុក្រឹត បំផុត។
- កំណត់សម្គាល់ ៧(ខ) – រយៈពេលភតិសន្យា ៖ ក្រុមហ៊ុនមានហេតុផលសមស្របដើម្បីអនុវត្តជម្រើសបន្តការជួល។

### ការវាស់វែងតម្លៃសមស្រប

គោលការណ៍គណនេយ្យ និងការលាតត្រដាងព័ត៌មានមួយចំនួនរបស់ក្រុមហ៊ុន តម្រូវឱ្យមានការវាស់វែងតាមតម្លៃសមស្របទាំងទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ និងទ្រព្យសកម្មនិងបំណុលមិនមែនហិរញ្ញវត្ថុ។

គណៈគ្រប់គ្រងត្រួតពិនិត្យជាប្រចាំ លើទិន្នន័យសំខាន់ៗដែលមិនអាចសង្កេតបាន និងធ្វើនិយ័តកម្មលើការវាស់វែងតម្លៃ។ ប្រសិនបើជាព័ត៌មានពីភាគីទីបី ដូចជា សម្រង់តម្លៃពីឈ្មួញកណ្តាល ឬសេវាកម្មផ្តល់តម្លៃត្រូវបានប្រើសម្រាប់ការវាស់វែងតម្លៃសមស្រប នោះគណៈគ្រប់គ្រងនឹងវាយតម្លៃលើភស្តុតាងដែលបានមកពីភាគីទីបី ដើម្បីផ្តល់អំណះអំណាងដល់ការសន្និដ្ឋាន ថាតើការវាយតម្លៃនោះត្រឹមត្រូវទៅតាមតម្រូវការរបស់ CIFRS ឬទេ រួមទាំងលំដាប់ខុសៗគ្នានៃតម្លៃសមស្របដែលការវាយតម្លៃនេះបានចាត់ថ្នាក់។

**២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)**

**២.១ មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)**

**ឃ. ការប្រើប្រាស់ការវិនិច្ឆ័យ និងការប៉ាន់ស្មាន (ត)**

**ការវាស់វែងតម្លៃសមស្រប (ត)**

ពេលវាស់វែងតម្លៃសមស្របនៃទ្រព្យសកម្ម ឬបំណុល ក្រុមហ៊ុនបានប្រើព័ត៌មានទីផ្សារដែលអាចសង្កេតបានភាគច្រើនតាមដែលអាចធ្វើបាន។ តម្លៃសមស្របត្រូវបានចាត់ថ្នាក់ក្នុងកម្រិតខុសៗគ្នានៃលំដាប់តម្លៃសមស្រប ដោយយោងទៅលើទិន្នន័យដែលប្រើប្រាស់ក្នុងវិធីសាស្រ្តវាយតម្លៃ ដូចខាងក្រោម៖

- កម្រិតទី១៖ តម្លៃដកស្រង់ (មិនទាន់មាននិយ័តកម្ម) នៅក្នុងទីផ្សារសកម្ម សម្រាប់ទ្រព្យសកម្ម ឬបំណុលប្រហាក់ប្រហែលគ្នា។
- កម្រិតទី២៖ ធាតុចូលដទៃទៀតក្រៅពីតម្លៃដកស្រង់ដែលមាននៅក្នុងកម្រិតទី១ ដែលអាចធ្វើការសង្កេតបានសម្រាប់ទ្រព្យសកម្ម ឬបំណុល ទោះបីដោយផ្ទាល់ (ឧទាហរណ៍ដូចជាតម្លៃ) ឬមិនផ្ទាល់ (ឧទាហរណ៍កើតចេញពីតម្លៃ)។
- កម្រិតទី៣៖ ធាតុចូលនៃទ្រព្យសកម្ម ឬបំណុល ដែលមិនអាស្រ័យលើទិន្នន័យទីផ្សារដែលអាចសង្កេតបាន (ធាតុចូលមិនអាចសង្កេតបាន)។

ប្រសិនបើធាតុចូលត្រូវបានប្រើប្រាស់ដើម្បីវាស់វែងតម្លៃសមស្របនៃទ្រព្យសកម្ម ឬបំណុល អាចត្រូវបានចាត់ថ្នាក់ក្នុងកម្រិតខុសៗគ្នានៃលំដាប់តម្លៃសមស្រប នោះការវាស់វែងតម្លៃសមស្របត្រូវបានចាត់ថ្នាក់ជារួមក្នុងកម្រិតលំដាប់តម្លៃសមស្របតែមួយ ជាធាតុចូលកម្រិតទាបបំផុតដែលមានលក្ខណៈជាសារវន្តសម្រាប់ការវាស់វែងទាំងមូល។

ក្រុមហ៊ុនទទួលស្គាល់ការផ្ទេរផ្សេងៗ រវាងកម្រិតនៃលំដាប់តម្លៃសមស្រប នាចុងការិយបរិច្ឆេទរាយការណ៍ ដែលមានប្រតិបត្តិការផ្លាស់ប្តូរនោះបានកើតឡើង។

ព័ត៌មានពីការសន្មតដែលបានធ្វើឡើងក្នុងការវាស់វែងតម្លៃសមស្រប ត្រូវបានរួមបញ្ចូលនៅក្នុងកំណត់សម្គាល់ ១៩ ស្តីពី ឧបករណ៍ហិរញ្ញវត្ថុ។

**ការវាយតម្លៃបំណុលកិច្ចសន្យាធានារ៉ាប់រង**

ការប៉ាន់ស្មានត្រូវបានធ្វើឡើងនាកាលបរិច្ឆេទរាយការណ៍ ដើម្បីកំណត់សំណងធានារ៉ាប់រងចុងក្រោយដែលរំពឹងទុក ទាំងសំណងធានារ៉ាប់រងដែលទទួលបានរបាយការណ៍ និងសំណងធានារ៉ាប់រងដែលកើតឡើង ប៉ុន្តែមិនទាន់ទទួលបានរបាយការណ៍ ។ វាអាចចំណាយពេលវេលាច្រើន មុនពេលអាចកំណត់តម្លៃសំណងធានារ៉ាប់រងរំពឹងទុកចុងក្រោយដោយភាពច្បាស់លាស់ ហើយប្រភេទកិច្ចសន្យាធានារ៉ាប់រងខ្លះ សំណងធានារ៉ាប់រងដែលកើតឡើង ប៉ុន្តែមិនទាន់ទទួលបានរបាយការណ៍ គឺជាផ្នែកដ៏ធំនៃសំវិធានធនលើសំណងធានារ៉ាប់រង។

គណៈគ្រប់គ្រងប៉ាន់ស្មានតម្លៃនៃសំណងធានារ៉ាប់រងដែលទទួលបានរបាយការណ៍ និងសំណងធានារ៉ាប់រងដែលកើតឡើង ប៉ុន្តែមិនទាន់ទទួលបានរបាយការណ៍ ដោយប្រើនិន្នាការការទូទាត់សំណងធានារ៉ាប់រងទៅតាមវិស័យអាជីវកម្មនីមួយក្នុងគ្រាកន្លងមក ដើម្បីព្យាករនិន្នាការការទូទាត់សំណងនាពេលអនាគត។ នាកាលបរិច្ឆេទរាយការណ៍នីមួយៗ ការប៉ាន់ស្មានសំណងធានារ៉ាប់រងក្នុងឆ្នាំមុន ត្រូវបានវាយតម្លៃរកភាពគ្រប់គ្រាន់ ហើយប្រសិនបើមានការ កែប្រែ ត្រូវកត់ត្រាចូលក្នុងសំវិធានធន។ បំណុលសំណងធានារ៉ាប់រង មិនត្រូវបានធ្វើអប្បហារសម្រាប់តម្លៃពេលវេលានៃទឹកប្រាក់ទេ។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥**

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)

## ២.២ ប្រតិបត្តិការរូបិយប័ណ្ណបរទេស

ក. រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ

គណនីទាំងអស់ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានវាស់វែងដោយប្រើរូបិយប័ណ្ណក្នុងបរិយាកាសសេដ្ឋកិច្ចចម្បងដែលក្រុមហ៊ុនធ្វើប្រតិបត្តិការ (ហៅកាត់ថា រូបិយប័ណ្ណគោល)។ ការកំណត់យកប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណគោល ដោយសារវាមានឥទ្ធិពលជាសារវន្តចំពោះប្រតិបត្តិការរបស់ក្រុមហ៊ុន។ របាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញរបស់ក្រុមហ៊ុន។

ខ. ប្រតិបត្តិការ និងសមតុល្យ

ប្រតិបត្តិការជារូបិយប័ណ្ណបរទេស ត្រូវបានកត់ត្រាប្តូរទៅជារូបិយប័ណ្ណគោល ដោយប្រើអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និងខាតពីការប្តូររូបិយប័ណ្ណ ដែលបណ្តាលមកពីការទូទាត់តាមប្រតិបត្តិការបែបនេះ និងពីការប្តូរទ្រព្យសកម្ម និងបំណុលរូបិយវត្ថុនានាជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់ដុល្លារអាមេរិក តាមអត្រាប្តូរនាចុងការិយបរិច្ឆេទ ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ-ខាត។

ចំណេញ និងខាតពីការប្តូររូបិយប័ណ្ណ ដែលពាក់ព័ន្ធនឹងប្រាក់កម្ចីត្រូវបានបង្ហាញនៅក្នុងចំណេញ-ខាត នៅក្នុងខ្ទង់ ចំណាយការប្រាក់។ ចំណេញនិងខាតពីការប្តូររូបិយប័ណ្ណផ្សេងៗទៀតទាំងអស់ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ តាមមូលដ្ឋានសុទ្ធក្នុងខ្ទង់ 'ចំណេញ/(ខាត)ផ្សេងៗ - សុទ្ធ'។

គ. ការបង្ហាញជាប្រាក់រៀល

អនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម របាយការណ៍ហិរញ្ញវត្ថុត្រូវបង្ហាញជាប្រាក់រៀល។ របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ និងរបាយការណ៍លំហូរសាច់ប្រាក់ ត្រូវបានប្តូរទៅជាប្រាក់រៀលដោយប្រើអត្រាមធ្យមប្រចាំឆ្នាំ។ ទ្រព្យសកម្មនិងបំណុល ដែលបានបង្ហាញក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនីមួយៗ ត្រូវបានប្តូរតាមអត្រាថ្ងៃបិទបញ្ជីនាកាលបរិច្ឆេទរាយការណ៍។ មូលធនភាគទុនិកនិងទុនបម្រុងត្រូវបានប្តូរតាមអត្រានាកាលបរិច្ឆេទប្រតិបត្តិការ។ ចំនួនលម្អៀងពីការប្តូរទាំងអស់ ត្រូវបានទទួលស្គាល់នៅក្នុងចំណូលលម្អិតផ្សេងៗ។

ក្រុមហ៊ុនបានប្រើអត្រាប្តូរប្រាក់ផ្លូវការដែលផ្សព្វផ្សាយដោយធនាគារជាតិ នៃ កម្ពុជា។ គិតត្រឹមកាលបរិច្ឆេទរាយការណ៍នេះ អត្រាមធ្យមគឺ ១ដុល្លារអាមេរិកស្មើនឹង ៤.០១១រៀល (២០២៤ ៖ ១ដុល្លារអាមេរិកស្មើនឹង ៤.០៧១រៀល) ហើយអត្រានាថ្ងៃបិទបញ្ជីគឺ ១ដុល្លារអាមេរិកស្មើនឹង ៤.០១៣រៀល (២០២៤ ៖ ៤.០២៥ រៀល)។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)

## ២.៣ ស្តង់ដាគណនេយ្យថ្មីដែលចូលជាធរមាន ប៉ុន្តែបានពន្យារពេលអនុវត្ត

ក្រុមហ៊ុនបានពន្យារពេលអនុវត្ត CIFRS 17 និង CIFRS 9 យោងតាមសេចក្តីជូនដំណឹងលេខ ០០១២/២៣ នគស/សជណ ចេញដោយនិយ័តករគណនេយ្យ និងសវនកម្ម (ACAR) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣។

បន្ទាប់មក ACAR បានចេញសេចក្តីជូនដំណឹងលេខ ០៦៣/២៤ នគស/សជណ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៤ ទាក់ទងនឹងការពន្យារពេលអនុវត្ត CIFRS 17 និង CIFRS 9 រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៧។

### (i) CIFRS 17 កិច្ចសន្យាធានារ៉ាប់រង

នៅខែឧសភា ឆ្នាំ២០១៧ IASB បានចេញផ្សាយ IFRS 17 កិច្ចសន្យាធានារ៉ាប់រង (ស្មើនឹង CIFRS 17 កិច្ចសន្យាធានារ៉ាប់រង) ដែលជាស្តង់ដាគណនេយ្យថ្មីដ៏លម្អិតមួយ សម្រាប់កិច្ចសន្យាធានារ៉ាប់រង ដោយគ្របដណ្តប់នូវការទទួលស្គាល់ និងការវាស់វែង ការបង្ហាញ និងការលាតត្រដាង ដែលជំនួស IFRS 4 កិច្ចសន្យាធានារ៉ាប់រង (ស្មើនឹង CIFRS 4 កិច្ចសន្យាធានារ៉ាប់រង)។

បើធៀបនឹងតម្រូវការក្នុង CIFRS 4 ដែលភាគច្រើនពឹងផ្អែកលើគោលការណ៍គណនេយ្យក្នុងស្រុកពីមុន សម្រាប់គោលបំណងនៃការវាស់វែង CIFRS 17 ផ្តល់នូវគំរូពេញលេញ (គំរូទូទៅ) សម្រាប់កិច្ចសន្យាធានារ៉ាប់រង និងបន្ថែមដោយវិធីសាស្រ្តកម្រែអថេរសម្រាប់កិច្ចសន្យា ដែលមានលក្ខណៈពិសេសចូលរួមដោយផ្ទាល់ ភាគច្រើនជាកិច្ចសន្យាសេវាទាក់ទងនឹងការវិនិយោគ និងវិធីសាស្រ្តនៃការបែងចែកបុព្វលាភរ៉ាប់រងដែលមានរយៈពេលខ្លី ដែលជាធម្មតាអនុវត្តចំពោះកិច្ចសន្យាធានារ៉ាប់រងមិនមែនអាយុជីវិត។

លក្ខណៈពិសេសៗនៃគំរូការកត់ត្រាគណនេយ្យថ្មី សម្រាប់កិច្ចសន្យាធានារ៉ាប់រង មានដូចខាងក្រោម៖

- ការវាស់វែងតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់នាពេលអនាគត ដោយរួមបញ្ចូលការកែតម្រូវហានិភ័យជាក់លាក់ និងត្រូវវាស់វែងឡើងវិញរៀងរាល់ការិយបរិច្ឆេទរាយការណ៍ (ការបំពេញលំហូរសាច់ប្រាក់)
- អត្រាចំណេញដុលលើសេវាកម្មកិច្ចសន្យា (CSM) ដែលមានចំនួនស្មើ និងផ្ទុយពីការចំណេញក្នុងថ្ងៃទីមួយនៃការបំពេញលំហូរសាច់ប្រាក់នៃក្រុមកិច្ចសន្យា។ CSM គឺជាចំណេញមិនទាន់ទទួលស្គាល់ នៃកិច្ចសន្យាធានារ៉ាប់រង ហើយត្រូវបានទទួលស្គាល់នៅក្នុងចំណេញ-ខាត ក្នុងសុពលភាពនៃកិច្ចសន្យាធានារ៉ាប់រង (ឧទាហរណ៍ រយៈពេលនៃការធានា)
- ការផ្លាស់ប្តូរជាក់លាក់ចំពោះតម្លៃបច្ចុប្បន្នរំពឹងទុក នៃលំហូរសាច់ប្រាក់នាពេលអនាគត ត្រូវបានកែសម្រួលដោយធៀបនឹង CSM ហេតុនេះត្រូវបានទទួលស្គាល់នៅក្នុងចំណេញ-ខាត ក្នុងរយៈពេលកិច្ចសន្យាដែលនៅសល់។
- ផលប៉ះពាល់នៃការប្រែប្រួលអត្រាអប្បហារ នឹងត្រូវបានរាយការណ៍នៅក្នុងចំណេញ-ខាត ឬចំណូលលម្អិតផ្សេងៗ ដែលកំណត់ដោយជម្រើសគោលការណ៍គណនេយ្យដែលបានអនុវត្ត។
- ការទទួលស្គាល់ចំណូលធានារ៉ាប់រង និងការចំណាយលើសេវាកម្មធានារ៉ាប់រង ក្នុងរបាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ គឺផ្អែកទៅតាមគោលការណ៍សេវាកម្មដែលបានផ្តល់ក្នុងការិយបរិច្ឆេទ។
- ចំនួនទឹកប្រាក់ដែលអ្នកទិញធានារ៉ាប់រងត្រូវទទួលបានជានិច្ច ដោយមិនគិតថាទោះបីជាមានព្រឹត្តិការណ៍ធានារ៉ាប់រងកើតឡើងក៏ដោយ (សមាសធាតុវិនិយោគមិនច្បាស់លាស់) មិនត្រូវបានបង្ហាញនៅក្នុងចំណេញ-ខាតទេ ប៉ុន្តែត្រូវបានទទួលស្គាល់ផ្ទាល់នៅក្នុងតារាងតុល្យការ។

## ២. **សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត** (ត)

### ២.៣ **ស្តង់ដាគណនេយ្យថ្មីដែលចូលជាធរមាន ប៉ុន្តែបានពន្យារពេលអនុវត្ត** (ត)

(i) CIFRS 17 **កិច្ចសន្យាធានារ៉ាប់រង** (ត)

- លទ្ធផលសេវាកម្មធានារ៉ាប់រង (ប្រាក់ចំណូលបានទទួលដកជាមួយនឹងសំណងបានកើតឡើង) ត្រូវបានបង្ហាញដាច់ដោយឡែកពីចំណូល ឬចំណាយហិរញ្ញវត្ថុធានារ៉ាប់រង
- ការលាតត្រដាងព័ត៌មានទូលំទូលាយគឺដើម្បីផ្តល់នូវព័ត៌មានចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ពីកិច្ចសន្យា។

នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣ និយ័តករគណនេយ្យនិងសវនកម្ម (ACAR) បានចេញសេចក្តីជូនដំណឹងលេខ ០០១២/២៣ នគស/សជណ ទាក់ទងនឹងការពន្យារពេលអនុវត្ត CIFRS 17 និង CIFRS 9 ដែលមានសេចក្តីដូចខាងក្រោម៖

- ពន្យារពេលអនុវត្ត CIFRS 17 និង CIFRS 9 សម្រាប់ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ នៅក្នុងប្រទេសកម្ពុជា រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។
- តម្រូវឱ្យក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ ផ្តល់នូវគម្រោងផែនការសម្រាប់ការអនុវត្ត ត្រឹមដំណាច់ខែកញ្ញា ឆ្នាំ២០២៣ និងរបាយការណ៍ប្រចាំត្រីមាស និងរបាយការណ៍ប្រចាំឆមាស ដោយចាប់ផ្តើមពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ តទៅ។

បន្ទាប់មក នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៤ ACAR បានចេញសេចក្តីជូនដំណឹងលេខ ០៦៣/២៤ នគស/សជណ ទាក់ទងនឹងការពន្យារពេលបន្ថែមទៅលើការអនុវត្ត CIFRS 17 និង CIFRS 9 ដែលមានសេចក្តីដូចខាងក្រោម៖

- ពន្យារពេលបន្ថែមសម្រាប់អនុវត្ត CIFRS 17 និង CIFRS 9 សម្រាប់ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ រហូតដល់ថ្ងៃទី០១ ខែមករា ឆ្នាំ២០២៨
- ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ ដែលបានទទួលយកសេចក្តីជូនដំណឹងអំពីការពន្យារពេលនេះ ត្រូវផ្តល់ជូន ACAR នូវរបាយការណ៍ប្រចាំឆមាស ដោយគិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៥ តទៅ និងត្រូវប្រគល់របាយការណ៍ប្រចាំឆមាសនោះ ក្នុងរយៈពេល១៥ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទបញ្ចប់ឆមាសនីមួយៗ។
- ក្នុងអំឡុងពេលនៃការពន្យារ ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ត្រូវបន្តអនុវត្ត CIFRS ទាំងអស់ដែលមានការពាក់ព័ន្ធជាធរមាន។

ក្រុមហ៊ុនជ្រើសរើសអនុវត្តតាមការជូនដំណឹងនេះ និងកំពុងបង្កើតផែនការអនុវត្ត ដើម្បីអនុវត្តស្តង់ដារទាំងនេះ។

CIFRS 17 មានសុពលភាពសម្រាប់ការិយបរិច្ឆេទរាយការណ៍ប្រចាំឆ្នាំ ដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២៨ ឬការិយបរិច្ឆេទបន្ទាប់ពីនេះ ដោយតម្រូវឱ្យមានតួលេខប្រៀបធៀប និងតម្រូវឱ្យមានការអនុវត្តត្រឡប់ថយក្រោយផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើការអនុវត្តត្រឡប់ថយក្រោយទាំងស្រុងឡើងវិញ សម្រាប់ក្រុមកិច្ចសន្យាធានារ៉ាប់រង មិនអាចអនុវត្តបានទេនោះ នោះក្រុមហ៊ុនត្រូវបានតម្រូវឱ្យជ្រើសរើសវិធីសាស្រ្តអនុវត្តត្រឡប់ថយក្រោយឡើងវិញដែលបានកែប្រែ ឬអនុវត្តវិធីសាស្រ្តតម្លៃសមស្រប។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)

## ២.៣ ស្តង់ដាគណនេយ្យថ្មីដែលចូលជាធរមាន ប៉ុន្តែបានពន្យារពេលអនុវត្ត (ត)

### (ii) CIFRS 9 ឧបករណ៍ហិរញ្ញវត្ថុ

CIFRS 9 កំណត់អំពីតម្រូវការក្នុងការទទួលស្គាល់ និងការវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុ បំណុលហិរញ្ញវត្ថុ និងកិច្ចសន្យាខ្លះសម្រាប់ការទិញ ឬលក់ ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ។ ស្តង់ដានេះបានជំនួសការណែនាំមុនរបស់ CIAS 39 ឧបករណ៍ហិរញ្ញវត្ថុ ៖ ការទទួលស្គាល់ និងការវាស់វែង។ ស្តង់ដានេះមានសុពលភាពសម្រាប់របាយការណ៍ប្រចាំឆ្នាំ ដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ ឬបន្ទាប់ពីនេះ ដែលការអនុវត្តមុនកាលកំណត់ ត្រូវបានអនុញ្ញាត និងត្រូវអនុវត្តគោលការណ៍សម្រាប់ការផ្លាស់ប្តូរនេះ។ ទោះជាយ៉ាងណាក៏ដោយ សម្រាប់ក្រុមហ៊ុនទាំងឡាយណាដែលមានប្រតិបត្តិការអាជីវកម្មផ្តោតលើសកម្មភាពធានារ៉ាប់រង អាចមានជម្រើសពន្យារពេលអនុវត្ត CIFRS 9 រហូតដល់កាលបរិច្ឆេទអនុវត្ត CIFRS 17។

CIFRS 9 រួមបញ្ចូលនូវចំណាត់ថ្នាក់ថ្មី និងវិធីសាស្ត្រវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុ ដែលឆ្លុះបញ្ចាំងពីទម្រង់អាជីវកម្ម ដែលគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និងលក្ខណៈនៃលំហូរសាច់ប្រាក់របស់វា។ CIFRS 9 រួមបញ្ចូលប្រភេទចំណាត់ថ្នាក់សំខាន់ៗចំនួនបីសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ៖ វាស់វែងតាមថ្លៃដើមដករំលស់ តម្លៃសមស្របក្នុងចំណូលលម្អិតផ្សេងៗ (FVOCI) និងតម្លៃសមស្របក្នុងចំណេញ-ខាត (FVTPL)។ ស្តង់ដានេះបានលុបបំបាត់ប្រភេទចំណាត់ថ្នាក់នៃទ្រព្យសកម្មដែលកាន់កាប់ដល់កាលកំណត់ ឥណទាន និងគណនីត្រូវទទួល និងទ្រព្យសកម្មសម្រាប់លក់ ដែលមានចែងក្នុង CIAS 39។

CIFRS 9 ជំនួសគំរូ 'ការខាតបង់ដែលបានកើតឡើង' ក្នុង CIAS 39 ជាមួយនឹងគំរូ 'ការខាតបង់ឥណទានរំពឹងទុក' (ECL) នាពេលអនាគត។ ស្តង់ដានេះតម្រូវឱ្យពិចារណាចំពោះការវិនិច្ឆ័យអំពីផលប៉ះពាល់នៃការកែប្រែកត្តាសេដ្ឋកិច្ចទៅលើ ECL ដែលត្រូវបានកំណត់តាមមូលដ្ឋានថ្លឹងប្រូបាប។

គំរូការថយចុះតម្លៃថ្មីត្រូវអនុវត្តចំពោះទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមថ្លៃដើមដករំលស់ ឬ FVOCI លើកលែងតែការវិនិយោគឧបករណ៍មូលធន និងទ្រព្យសកម្មក្នុងកិច្ចសន្យា។

ក្រោម CIFRS 9 សំវិធានធនសម្រាប់ការខាតបង់ ត្រូវវាស់វែងតាមមូលដ្ឋានដូចខាងក្រោម៖

- ECL ១២ខែ៖ ECL ទាំងនេះគឺជាលទ្ធផលបានមកពីព្រឹត្តិការណ៍នៃការខកខានសងប្រាក់ ក្នុងអំឡុងពេល១២ ខែបន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ និង
- ECL ពេញមួយអាយុកាល៖ ECL ទាំងនេះគឺជាលទ្ធផលបានមកពីព្រឹត្តិការណ៍នៃការខកខានសងប្រាក់ ក្នុងអំឡុងពេលនៃអាយុកាលរំពឹងទុករបស់ឧបករណ៍ហិរញ្ញវត្ថុ។

ECL ពេញមួយអាយុកាលត្រូវបានអនុវត្ត ប្រសិនបើមានកំណើនហានិភ័យឥណទានជាសារវន្តនៃទ្រព្យសកម្មហិរញ្ញវត្ថុនៅកាលបរិច្ឆេទរាយការណ៍ ចាប់តាំងពីការទទួលស្គាល់ដំបូង ហើយប្រសិនបើមិនដូច្នោះទេ ត្រូវអនុវត្តតាមការវាស់វែង ECL ១២ខែ។ ក្រុមហ៊ុនអាចកំណត់ថាហានិភ័យឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុ មិនបានកើនឡើងជាសារវន្ត ប្រសិនបើទ្រព្យសកម្មមានកម្រិតហានិភ័យឥណទានទាប នាកាលបរិច្ឆេទរាយការណ៍។ ទោះជាយ៉ាងណាក៏ដោយ ECL ពេញមួយអាយុកាល តែងតែអនុវត្តចំពោះគណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ ដោយមិនរួមបញ្ចូលសមាសធាតុហិរញ្ញវត្ថុសារវន្តទេ។

ក្រុមហ៊ុនមានសិទ្ធិអនុវត្ត និងជ្រើសរើសអនុវត្តជម្រើសក្នុងការពន្យារពេលកាលបរិច្ឆេទមានប្រសិទ្ធភាពនៃ CIFRS 9 និងអនុវត្តវារួមគ្នាជាមួយ CIFRS 17 ដោយចាប់ផ្តើមពីកាលបរិច្ឆេទមានប្រសិទ្ធភាព នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២៨។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)

## ២.៤ ស្តង់ដាគណនេយ្យថ្មី វិសោធនកម្មស្តង់ដាគណនេយ្យ ដែលក្រុមហ៊ុនបានអនុវត្ត

ក្រុមហ៊ុនបានអនុវត្តស្តង់ដាគណនេយ្យថ្មី និងវិសោធនកម្មស្តង់ដាគណនេយ្យដូចខាងក្រោមជាលើកដំបូងសម្រាប់ការិយបរិច្ឆេទរាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុន ដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២៥។

- កង្វះលទ្ធភាពក្នុងការផ្លោះប្តូរ – វិសោធនកម្ម CIAS 21

វិសោធនកម្មខាងលើនេះ មិនមានផលប៉ះពាល់ទៅលើចំនួនដែលបានទទួលស្គាល់ក្នុងការិយបរិច្ឆេទមុនៗទេ ហើយក្រុមហ៊ុនមិនរំពឹងថាវាមានផល ប៉ះពាល់ជាសារវន្តចំពោះការិយបរិច្ឆេទបច្ចុប្បន្ន ឬការិយបរិច្ឆេទអនាគតទេ។

## ២.៥ ស្តង់ដាគណនេយ្យថ្មី និងបំណកស្រាយដែលក្រុមហ៊ុនមិនទាន់បានអនុវត្ត

មានស្តង់ដាគណនេយ្យថ្មី និងវិសោធនកម្មស្តង់ដាគណនេយ្យមួយចំនួនដែលត្រូវបានចេញផ្សាយរួច ប៉ុន្តែមិនទាន់ចូលជាធរមានសម្រាប់ការិយបរិច្ឆេទរាយការណ៍ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ហើយក្រុមហ៊ុនមិនទាន់អនុវត្តមុនកាលកំណត់ទេ។

- វិសោធនកម្មចំពោះការចាត់ថ្នាក់ និងការវាស់វែងឧបករណ៍ហិរញ្ញវត្ថុ – វិសោធនកម្ម CIFRS 9 និង CIFRS 7 (ចូលជាធរមានសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំ ដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២៦ ឬបន្ទាប់ពីនេះ)

ស្តង់ដា និងវិសោធនកម្មទាំងនេះ មិនត្រូវបានរំពឹងថាមានផលប៉ះពាល់ជាសារវន្តចំពោះក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទរាយការណ៍បច្ចុប្បន្ន ឬការិយបរិច្ឆេទរាយការណ៍អនាគត និងចំពោះប្រតិបត្តិការនាពេលអនាគតដ៏ខ្លីខាងមុខនេះទេ លើកលែងតែស្តង់ដាខាងក្រោម៖

- CIFRS 18 ការបង្ហាញ និងការលាតត្រដាងឧបករណ៍ហិរញ្ញវត្ថុ (ចូលជាធរមានសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំ ដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២៧ ឬបន្ទាប់ពីនេះ)

CIFRS 18 នឹងជំនួស CIAS 1 ស្តីពី ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ ដែលណែនាំនូវតម្រូវការថ្មីដែលនឹងជួយឱ្យសម្រេចបាននូវការប្រៀបធៀបលទ្ធផលហិរញ្ញវត្ថុរបស់អង្គភាពស្រដៀងគ្នា និងផ្តល់ព័ត៌មានដែលពាក់ព័ន្ធ និងកាន់តែមានតម្លាភាពបន្ថែមទៀតដល់អ្នកប្រើប្រាស់។ ទោះបីជា CIFRS 18 មិនប៉ះពាល់ដល់ការទទួលស្គាល់ ឬការវាស់វែងខ្វង់ផ្សេងៗនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុក៏ដោយ ក៏ផលប៉ះពាល់របស់វាចំពោះការបង្ហាញ និងការលាតត្រដាង ត្រូវបានរំពឹងថានឹងមានការប៉ះពាល់ខ្លះៗ ជាពិសេសខ្វង់ដែលពាក់ព័ន្ធនឹងរបាយការណ៍លទ្ធផលហិរញ្ញវត្ថុ និងការផ្តល់នូវវិធានការអនុវត្តដែលកំណត់ដោយគណៈគ្រប់គ្រង នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

បច្ចុប្បន្ននេះ គណៈគ្រប់គ្រងកំពុងវាយតម្លៃផលប៉ះពាល់លម្អិត នៃការអនុវត្តស្តង់ដាថ្មីចំពោះរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

ក្រុមហ៊ុននឹងអនុវត្តស្តង់ដាថ្មីចាប់ពីកាលបរិច្ឆេទចូលជាធរមាននៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២៧។ ការអនុវត្តត្រលប់ថយក្រោយត្រូវបានតម្រូវ ដូច្នេះព័ត៌មានប្រៀបធៀបសម្រាប់ដំណាច់ឆ្នាំហិរញ្ញវត្ថុនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៦ នឹងត្រូវរាយការណ៍ឡើងវិញ អនុលោមតាម CIFRS 18 ។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)

## ២.៦ កិច្ចសន្យាធានារ៉ាប់រង

### (i) ចំណាត់ថ្នាក់

កិច្ចសន្យាធានារ៉ាប់រងគឺជាកិច្ចសន្យាទាំងឡាយណា ដែលក្រុមហ៊ុនទទួលយកនូវហានិភ័យធានារ៉ាប់រងជាសារវន្ត ពីម្ចាស់បណ្ណធានារ៉ាប់រង ដោយព្រមព្រៀងទូទាត់ឱ្យម្ចាស់បណ្ណធានារ៉ាប់រង ឬអ្នកទទួលផលផ្សេងទៀត ប្រសិនបើមានព្រឹត្តិការណ៍ជាក់លាក់មិនប្រាកដប្រជានាពេលអនាគតណាមួយ មានផលប៉ះពាល់អវិជ្ជមានចំពោះម្ចាស់បណ្ណធានារ៉ាប់រង ឬអ្នកទទួលផល។ នៅពេលដែលកិច្ចសន្យាមួយត្រូវបានចាត់ថ្នាក់ជាកិច្ចសន្យាធានារ៉ាប់រង កិច្ចសន្យានោះនឹងមានសុពលភាពជាកិច្ចសន្យាធានារ៉ាប់រងសម្រាប់រយៈពេលដែលនៅសល់ក្នុងកិច្ចសន្យា ទោះបីជាហានិភ័យធានារ៉ាប់រងត្រូវបានកាត់បន្ថយជាសារវន្តក្នុងអំឡុងឆ្នាំក៏ដោយ។

### (ii) ការទទួលស្គាល់ និងការវាស់វែង

#### ចំណូលបុព្វលាភធានារ៉ាប់រង

បុព្វលាភដែលបានមកពីការធានារ៉ាប់រង ត្រូវបានទទួលស្គាល់ជាចំណូល នៅពេលដែលកិច្ចសន្យាធានារ៉ាប់រងមានប្រសិទ្ធភាព និងត្រូវបានទទួលស្គាល់តាមសមាមាត្រនៃរយៈពេលធានារ៉ាប់រង។ បុព្វលាភពីកិច្ចសន្យាសហធានារ៉ាប់រងត្រូវបានទទួលស្គាល់ដោយផ្អែកទៅតាមចំណែកសមាមាត្របុព្វលាភធានារ៉ាប់រងរបស់ក្រុមហ៊ុន។

ក្រុមហ៊ុនធ្វើការធានារ៉ាប់រងបន្តនូវផ្នែកនៃហានិភ័យដែលបានទទួលយកសរុបរបស់ខ្លួន ជាមួយក្រុមហ៊ុនធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រងបន្តផ្សេងទៀត។ បុព្វលាភបានបង់ ឬចំណែកបុព្វលាភលើកិច្ចសន្យាធានារ៉ាប់រងបន្តនាពេលអនាគត ត្រូវបានទទួលស្គាល់ក្នុងរយៈពេលនៃកិច្ចសន្យាធានារ៉ាប់រងបន្ត ដោយផ្អែកលើរយៈពេលនៃការធានារ៉ាប់រងដែលបានចុះកិច្ចសន្យា។

ចំណូលបុព្វលាភធានារ៉ាប់រងសុទ្ធនៅក្នុងរបាយការណ៍ចំណេញ-ខាត គឺជាបុព្វលាភធានារ៉ាប់រងដុល បុព្វលាភធានារ៉ាប់រងបន្ត និងកំណើន/(តំហាយ)បុព្វលាភធានារ៉ាប់រងដែលមិនទាន់ចាត់ទុកជាចំណូល។ បុព្វលាភធានារ៉ាប់រងបន្តត្រូវបានបង្ហាញ ដោយការកាត់ចេញពីបុព្វលាភធានារ៉ាប់រងដុល។

#### ទ្រព្យសកម្មធានារ៉ាប់រងបន្ត

ទ្រព្យសកម្មធានារ៉ាប់រងបន្ត រួមមាន សមតុល្យដែលរំពឹងថានឹងអាចទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងបន្តសម្រាប់សំណងធានារ៉ាប់រងបន្តប៉ាន់ស្មានដែលបានផ្ទេរចេញ និងបុព្វលាភធានារ៉ាប់រងដែលមិនទាន់ចាត់ទុកជាចំណូលដែលបានផ្ទេរចេញ។ ចំនួនទឹកប្រាក់ដែលអាចទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងបន្ត ត្រូវបានប៉ាន់ស្មានក្នុងលក្ខណៈស្របជាមួយនឹងវិធីសាស្ត្រដែលបានប្រើដើម្បីកំណត់បំណុលដែលទាក់ទងនឹងគោលការណ៍ធានារ៉ាប់រងបន្ត។

ទ្រព្យសកម្មធានារ៉ាប់រងបន្ត ត្រូវបានរាយការណ៍តាមចំនួនសមតុល្យមិនទាន់ទូទាត់ ពីក្រុមហ៊ុនធានារ៉ាប់រងបន្ត និងចំណែកនៃបំណុលកិច្ចសន្យាធានារ៉ាប់រងរបស់ក្រុមហ៊ុនធានារ៉ាប់រងបន្ត ដកសំវិធានធនសម្រាប់ការខាតពីការថយចុះតម្លៃ ប្រសិនបើមាន។ ក្រុមហ៊ុនវាយតម្លៃការខាតពីការថយចុះតម្លៃ សម្រាប់ការខាតបង់ប៉ាន់ស្មានដែលអាចកើតឡើងដោយសារតែអសមត្ថភាពក្នុងការប្រមូលប្រាក់ ដោយផ្អែកតាមបទពិសោធន៍នៃការប្រមូលប្រាក់ ការរំពឹងទុកទៅពេលអនាគតចំពោះការទូទាត់ប្រាក់ក្រុមហ៊ុនធានារ៉ាប់រងបន្ត និងស្ថានភាពនៃការទទួលសំណងពីក្រុមហ៊ុនធានារ៉ាប់រងបន្តនាចុងការិយបរិច្ឆេទរាយការណ៍។

**២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)**

**២.៦ កិច្ចសន្យាធានារ៉ាប់រង (ត)**

(ii) **ការទទួលស្គាល់ និងការវាស់វែង (ត)**

**បំណុលកិច្ចសន្យាធានារ៉ាប់រង**

បំណុលសម្រាប់អត្ថប្រយោជន៍ក្នុងកិច្ចសន្យា គឺជាកាតព្វកិច្ចដែលបានចុះក្នុងកិច្ចសន្យា។ បំណុលកិច្ចសន្យាធានារ៉ាប់រង រួមមាន ១)បំណុលក្នុងកិច្ចសន្យាធានារ៉ាប់រងរយៈពេលខ្លី ២)បំណុលក្នុងកិច្ចសន្យាធានារ៉ាប់រងរយៈពេលវែង ដែលត្រូវបានកត់ត្រាដោយអនុលោមទៅតាមគោលការណ៍គណនាហានិភ័យដែលអាចទទួលយកបានជាទូទៅ។

*(១) បំណុលក្នុងកិច្ចសន្យាធានារ៉ាប់រងរយៈពេលខ្លី*

*សំណងធានារ៉ាប់រងមិនទាន់ទូទាត់*

ក្រុមហ៊ុនត្រូវបានតម្រូវឱ្យរក្សាទុកប្រាក់បម្រុងសម្រាប់ការទូទាត់សំណងធានារ៉ាប់រងដែលអាចកើតឡើង ដែលជាចំណាយរំពឹងទុកចុងក្រោយ ដើម្បីទូទាត់សំណងធានារ៉ាប់រងដែលបានកើតឡើងក្នុងគ្រាមុន ប៉ុន្តែនៅមិនទាន់បានទូទាត់នៅឡើយគិតត្រឹមកាលបរិច្ឆេទរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

*ប្រាក់បម្រុងបុព្វលាភធានារ៉ាប់រងមិនទាន់ចាត់ទុកជាចំណូល*

បុព្វលាភធានារ៉ាប់រងមិនទាន់ចាត់ទុកជាចំណូលគឺជាផ្នែកនៃបុព្វលាភធានារ៉ាប់រង ដែលពាក់ព័ន្ធនឹងការការពារក្នុងអំឡុងពេលដែលកិច្ចសន្យាធានារ៉ាប់រងមិនទាន់ផុតកំណត់។បុព្វលាភធានារ៉ាប់រងមិនទាន់ចាត់ទុកជាចំណូល គឺជាបុព្វលាភធានារ៉ាប់រងដែលទាក់ទងនឹងរយៈពេល ដែលនៅសល់ក្នុងកិច្ចសន្យាធានារ៉ាប់រង។ វាត្រូវបានធ្វើសមាមាត្រទៅតាមចំណែកដែលមិនទាន់ផុតកំណត់នៃការធានារ៉ាប់រង និងត្រូវបង្ហាញជាបំណុលនៅលើរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនធានារ៉ាប់រង ដោយសារក្រុមហ៊ុនត្រូវ ទូទាត់សងវិញ នៅពេលលុបចោលកិច្ចសន្យាធានារ៉ាប់រង។

បុព្វលាភធានារ៉ាប់រងមិនទាន់ចាត់ទុកជាចំណូល សម្រាប់កិច្ចសន្យារយៈពេលខ្លី ត្រូវបានកំណត់ទៅតាមប្រភេទអាជីវកម្មនីមួយៗ ហើយត្រូវបានគណនាតាមសមាមាត្រនៃចំនួនថ្ងៃ រហូតដល់ថ្ងៃផុតកំណត់នៃកិច្ចសន្យាធានារ៉ាប់រង (សមាមាត្រប្រចាំ ថ្ងៃ)។ កំណើន/តំហយនៃបុព្វលាភធានារ៉ាប់រងមិនទាន់ចាត់ទុកជាចំណូល គឺជាភាពខុសគ្នារវាងសមតុល្យបុព្វលាភធានារ៉ាប់រងមិនទាន់ចាត់ទុកជាចំណូលសម្រាប់ការិយបរិច្ឆេទបច្ចុប្បន្ន និងការិយបរិច្ឆេទមុន។

វិធីសាស្ត្រដែលត្រូវបានប្រើ ដើម្បីគណនាប្រាក់បម្រុងបុព្វលាភធានារ៉ាប់រងមិនទាន់ចាត់ទុកជាចំណូល គឺវិធីសាស្ត្រមូលដ្ឋានប្រចាំថ្ងៃ ១/៣៦៥។

ផ្នែកនៃទ្រព្យសកម្មធានារ៉ាប់រងបន្តនៃបុព្វលាភធានារ៉ាប់រងមិនទាន់ចាត់ទុកជាចំណូល ត្រូវបានទទួលស្គាល់ក្នុងពេលដំណាលគ្នានៅពេលដែលបុព្វលាភធានារ៉ាប់រងមិនទាន់ចាត់ទុកជាចំណូល បានកើតឡើង។ ផ្នែកនៃទ្រព្យសកម្មធានារ៉ាប់រងបន្តនៃបុព្វលាភធានារ៉ាប់រងមិនទាន់ចាត់ទុកជាចំណូល ត្រូវបានវាស់វែងដោយអនុលោមទៅតាមកិច្ចសន្យាធានារ៉ាប់រងបន្ត ដែលមានសង្គតិភាពជាមួយនឹងវិធីសាស្ត្រ បុព្វលាភធានារ៉ាប់រងមិនទាន់ចាត់ទុកជាចំណូល។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥**

**២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត** (ត)

**២.៦ កិច្ចសន្យាធានារ៉ាប់រង** (ត)

(ii) **ការទទួលស្គាល់ និងការវាស់វែង** (ត)
**បំណុលកិច្ចសន្យាធានារ៉ាប់រង** (ត)

*(១) បំណុលក្នុងកិច្ចសន្យាធានារ៉ាប់រងរយៈពេលខ្លី (ត)*
*ប្រាក់បម្រុងសម្រាប់សំណងធានារ៉ាប់រងដែលបានកើតឡើងប៉ុន្តែមិនទាន់ទទួលរបាយការណ៍*

ប្រាក់បម្រុងសម្រាប់សំណងធានារ៉ាប់រងដែលបានកើតឡើងប៉ុន្តែមិនទាន់ទទួលរបាយការណ៍ ត្រូវបានកត់ត្រាដោយអនុលោមទៅតាមគោលការណ៍គណនាបុព្វលាភធានារ៉ាប់រងដែលអាចទទួលយកបានជាទូទៅ។

(ក) ការធ្វើតេស្តភាពគ្រប់គ្រាន់នៃបំណុល

នាកាលបរិច្ឆេទរាយការណ៍ ក្រុមហ៊ុនវាយតម្លៃថាតើបំណុលកិច្ចសន្យាធានារ៉ាប់រងដែលបានទទួលស្គាល់ មានភាពគ្រប់គ្រាន់ដែរឬទេ ដោយប្រើការប៉ាន់ស្មាននាពេលបច្ចុប្បន្នទៅលើលំហូរសាច់ប្រាក់នាពេលអនាគត នៅក្នុងកិច្ចសន្យាធានារ៉ាប់រង។ ប្រសិនបើការវាយតម្លៃនោះបង្ហាញថា តម្លៃយោងនៃបំណុលធានារ៉ាប់រង កាត់កងជាមួយនឹងចំណាយលទ្ធកម្មពន្យារ មានភាពមិនគ្រប់គ្រាន់ ធៀបនឹងលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគត នោះក្រុមហ៊ុនទទួលស្គាល់ចំនួនខ្វះទាំងស្រុង នៅក្នុងចំណេញ-ខាត ក្នុងការិយបរិច្ឆេទនោះ។

(ខ) ចំណាយលទ្ធកម្ម

ចំណាយលទ្ធកម្មគឺជាចំណាយដែលបានកើតឡើង ដើម្បីទទួលបានចំណូលបុព្វលាភធានារ៉ាប់រង ដូចជា កម្រៃជើងសាបង់ឱ្យឈ្មួញជើងសាធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រងផ្សេងៗ។ ចំណាយលទ្ធកម្មត្រូវបានកត់ត្រាពន្យារ និងដករំលស់ក្នុងរយៈពេលនៃកិច្ចសន្យាធានារ៉ាប់រង ដោយផ្អែកទៅតាមវិធីសាស្ត្របុព្វលាភធានារ៉ាប់រងមិនទាន់ចាត់ទុកជាចំណូល។

(គ) ចំណាយសំណងធានារ៉ាប់រង

ចំណាយសំណងធានារ៉ាប់រងរួមមាន សំណងធានារ៉ាប់រងដែលបានទូទាត់ សំណងធានារ៉ាប់រងកំពុងដំណើរការ រួមទាំងសំណងធានារ៉ាប់រងដែលបានកើតឡើងប៉ុន្តែមិនទាន់ទទួលរបាយការណ៍ និងចំណាយលើការដោះស្រាយសំណងធានារ៉ាប់រង។ សំណងធានារ៉ាប់រងត្រូវបានទទួលស្គាល់ជាចំណាយនៅពេលដែលកាតព្វកិច្ចទូទាត់សំណងធានារ៉ាប់រងបានកើតឡើង។ ផ្នែកនៃសំណងធានារ៉ាប់រងដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងបន្ត ត្រូវបានកត់ត្រា និងត្រូវបានទទួលស្គាល់ ដោយកាត់ចេញពីចំណាយសំណងធានារ៉ាប់រង នៅក្នុងការិយបរិច្ឆេទតែមួយដែលចំណាយសំណងធានារ៉ាប់រងត្រូវបានទទួលស្គាល់។

សំណងធានារ៉ាប់រងកំពុងដំណើរការ (សំណងប៉ាន់ស្មានរក្សាទុកផ្ទាល់របស់ក្រុមហ៊ុន) ត្រូវបានគណនាផ្អែកតាមចំណែករក្សាទុកផ្ទាល់របស់ក្រុមហ៊ុន ចំពោះសំណងកំពុងទូទាត់ នាកាលបរិច្ឆេទរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ រួមទាំងសំណងធានារ៉ាប់រងដែលបានកើតឡើងប៉ុន្តែមិនទាន់ទទួលរបាយការណ៍ផងដែរ។ ការប្រែប្រួលនៃសំណងធានារ៉ាប់រងប៉ាន់ស្មានរក្សាទុកផ្ទាល់ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលលម្អិត នាពេលប្រែប្រួលនោះ។ កំណើនឬតំហយនៃសំណងប៉ាន់ស្មានរក្សាទុកផ្ទាល់ គឺជាភាពខុសគ្នារវាងសំណងប៉ាន់ស្មានរក្សាទុកផ្ទាល់សម្រាប់ការិយបរិច្ឆេទនេះ និងការិយបរិច្ឆេទមុន។

**២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត** (ត)

**២.៦ កិច្ចសន្យាធានារ៉ាប់រង** (ត)

(ii) **ការទទួលស្គាល់ និងការវាស់វែង** (ត)

**បំណុលកិច្ចសន្យាធានារ៉ាប់រង** (ត)

*(១) បំណុលក្នុងកិច្ចសន្យាធានារ៉ាប់រងរយៈពេលខ្លី (ត)*

*ប្រាក់បម្រុងសម្រាប់សំណងធានារ៉ាប់រងដែលបានកើតឡើងប៉ុន្តែមិនទាន់ទទួលរបាយការណ៍ (ត)*

(គ) ចំណាយសំណងធានារ៉ាប់រង (ត)

ការបង្ហាញចំណាយសំណងធានារ៉ាប់រងនៅក្នុងរបាយការណ៍ចំណេញ-ខាត គឺជាចំនួនសំណងធានារ៉ាប់រងដុល សំណងធានារ៉ាប់រងបន្ត និង កំណើន/តំហយនៃសំណងធានារ៉ាប់រងប៉ាន់ស្មានរក្សាទុកផ្ទាល់។ សំណងធានារ៉ាប់រងបន្តត្រូវបានបង្ហាញដោយកាត់ចេញពីសំណងធានារ៉ាប់រងដុល។

សំវិធានធនសម្រាប់សំណងធានារ៉ាប់រងដុលប៉ាន់ស្មាន ត្រូវបានកត់ត្រាតាមចំណាយសំណងធានារ៉ាប់រងប៉ាន់ស្មានទាំងស្រុង ដែលត្រូវបង់ ទាក់ទងនឹងសំណងធានារ៉ាប់រងដែលបានជូនដំណឹងមកក្រុមហ៊ុន រហូតដល់កាលបរិច្ឆេទនៃការិយបរិច្ឆេទរាយការណ៍។ ការប្រមូលបានពីក្រុមហ៊ុនធានារ៉ាប់រងបន្តនៃសំវិធានធនសម្រាប់សំណងធានារ៉ាប់រងប៉ាន់ស្មានដុល ត្រូវបានកត់ត្រាជាសំណងធានារ៉ាប់រងបន្តប៉ាន់ស្មាន នៅក្នុងទ្រព្យសកម្មធានារ៉ាប់រងបន្ត។

បម្រែបម្រួលចំនួនបំណុលសំណងធានារ៉ាប់រងប៉ាន់ស្មានសរុប ដែលជាលទ្ធផលនៃការត្រួតពិនិត្យបន្ថែម និងចំនួនលម្អៀងរវាងសំណងធានារ៉ាប់រងប៉ាន់ស្មាន និងសំណងធានារ៉ាប់រងបានទូទាត់ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ-ខាត ក្នុងការិយបរិច្ឆេទដែលមានបម្រែបម្រួលនោះកើតឡើង។

**កម្រៃជើងសាធានារ៉ាប់រងបន្ត**

កម្រៃជើងសាទទួលបានពីកិច្ចសន្យាធានារ៉ាប់រងបន្ត ត្រូវបានទទួលស្គាល់ជាចំណូល ក្នុងរយៈពេលនៃកិច្ចសន្យានោះ ដោយប្រើវិធីសាស្ត្រ ១/៣៦៥។ ចំណែកកម្រៃជើងសាដែលពាក់ព័ន្ធនឹងរយៈពេលដែលនៅសល់ក្នុងកិច្ចសន្យាធានារ៉ាប់រងមិនទាន់អស់សុពលភាព នាកាលបរិច្ឆេទរាយការណ៍ ត្រូវបានកត់ត្រាជាកម្រៃជើងសាធានារ៉ាប់រងបន្តពន្យារ។

កម្រៃជើងសាដែលក្រុមហ៊ុនធានារ៉ាប់រងបន្តជំពាក់ ត្រូវបានទទួលស្គាល់ជាគណនីធានារ៉ាប់រងបន្តត្រូវទទួល ក្នុងការិយបរិច្ឆេទដូចគ្នា និងត្រូវបានបង្ហាញក្រោមខ្ទង់ គណនីធានារ៉ាប់រងត្រូវទទួល និងគណនីត្រូវទទួលផ្សេងៗ។

*(២) បំណុលក្នុងកិច្ចសន្យាធានារ៉ាប់រងរយៈពេលវែង*

*ប្រាក់បម្រុងគណិតវិទ្យា*

ប្រាក់បម្រុងគណិតវិទ្យា ត្រូវបានគណនាដោយប្រើវិធីសាស្ត្រវាយតម្លៃបុព្វលាភធានារ៉ាប់រងដុល។ វិធីសាស្ត្រវាយតម្លៃបុព្វលាភធានារ៉ាប់រងដុល ត្រូវបានគណនាដោយប្រើវិធីសាស្ត្ររបស់អ្នកជំនាញគណនាបុព្វលាភធានារ៉ាប់រង ផ្អែកទៅតាមការសន្មតបច្ចុប្បន្ន ដែលឆ្លុះបញ្ចាំងនូវការប៉ាន់ស្មានដ៏សុក្រឹតនាពេលវាយតម្លៃ។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)

### ២.៧ ឧបករណ៍ហិរញ្ញវត្ថុ

ក្រុមហ៊ុនបែងចែកទ្រព្យសកម្មហិរញ្ញវត្ថុអនិស្សន្ទ ទៅជាប្រភេទ ឥណទាននិងគណនីត្រូវទទួល។

ក្រុមហ៊ុនបែងចែកបំណុលហិរញ្ញវត្ថុអនិស្សន្ទ ទៅជាប្រភេទ បំណុលហិរញ្ញវត្ថុផ្សេងៗ។

#### (i) ទ្រព្យសកម្មហិរញ្ញវត្ថុអនិស្សន្ទ និងបំណុលហិរញ្ញវត្ថុអនិស្សន្ទ - ការទទួលស្គាល់ និងការឈប់ទទួលស្គាល់

ក្រុមហ៊ុនទទួលស្គាល់ឥណទាននិងគណនីត្រូវទទួលលើកដំបូង នាកាលបរិច្ឆេទដែលប្រតិបត្តិការបានចាប់ផ្តើម។ ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុផ្សេងទៀតទាំងអស់ ត្រូវបានទទួលស្គាល់លើកដំបូង នៅកាលបរិច្ឆេទជួញដូរ នៅពេលដែលក្រុមហ៊ុនក្លាយជាភាគីមួយនៃកិច្ចសន្យារបស់ឧបករណ៍នោះ។

ក្រុមហ៊ុនឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិទទួលបានសាច់ប្រាក់តាមកិច្ចសន្យានៃទ្រព្យសកម្មនោះ ផុតកំណត់ ឬបានផ្ទេរសិទ្ធិក្នុងការទទួលបានសាច់ប្រាក់តាមកិច្ចសន្យាក្នុងប្រតិបត្តិការមួយដែលហានិភ័យនិងតម្លៃតបស្នងពីកម្មសិទ្ធិភាពជាសារវន្តនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានផ្ទេរចេញ ឬមិនបានផ្ទេរ ឬមិនរក្សានូវហានិភ័យនិងតម្លៃតបស្នងពីកម្មសិទ្ធិភាពជាសារវន្ត និងមិនរក្សានូវការគ្រប់គ្រងទ្រព្យសកម្មដែលបានផ្ទេរ។ អត្ថប្រយោជន៍ណាមួយនៃទ្រព្យសកម្មហិរញ្ញវត្ថុដែលបានផ្ទេរ ដែលត្រូវបានបង្កើតឡើង ឬរក្សាទុកដោយក្រុមហ៊ុន ត្រូវបានទទួលស្គាល់ជាទ្រព្យសកម្ម ឬបំណុលដាច់ដោយឡែក។

ក្រុមហ៊ុនឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលកាតព្វកិច្ចក្នុងកិច្ចសន្យាត្រូវបានរំលាយ លុបចោល ឬ ផុតកាលកំណត់។

ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កង ហើយចំនួននៅសល់សុទ្ធត្រូវបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ តែនៅពេលដែលក្រុមហ៊ុនមានសិទ្ធិតាមផ្លូវច្បាប់ដើម្បីទូទាត់ចំនួនទឹកប្រាក់ និងមានបំណងទូទាត់តាមមូលដ្ឋានបន្ទាប់ពីកាត់កង ឬទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

#### (ii) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុអនិស្សន្ទ - ការវាស់វែង គណនីធានារ៉ាប់រងត្រូវទទួល និងគណនីត្រូវទទួលផ្សេងៗ

គណនីធានារ៉ាប់រងត្រូវទទួល និងគណនីត្រូវទទួលផ្សេងៗ ត្រូវបានទទួលស្គាល់លើកដំបូងតាមតម្លៃសមស្រប បូកបន្ថែមចំណាយប្រតិបត្តិការពាក់ព័ន្ធផ្ទាល់។ បន្ទាប់ពីការទទួលស្គាល់លើកដំបូង វាត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ ដោយប្រើវិធីសាស្រ្តការប្រាក់មានប្រសិទ្ធភាព។

#### សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមាន សមតុល្យសាច់ប្រាក់ និងប្រាក់បញ្ញើតាមតម្រូវការ ដែលមានកាលកំណត់៣ខែ ឬតិចជាង គិតចាប់ពីកាលបរិច្ឆេទប្រតិបត្តិការ ដែលមានហានិភ័យនៃការផ្លាស់ប្តូរតម្លៃសមស្របតិចតួច ហើយក្រុមហ៊ុនប្រើប្រាស់សម្រាប់ការចាត់ចែងការបំពេញកាតព្វកិច្ចទូទាត់រយៈពេលខ្លីរបស់ខ្លួន។

**២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត** (ត)

**២.៧ ឧបករណ៍ហិរញ្ញវត្ថុ** (ត)

(ii) **ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុអនិស្សន្ទ - ការវាស់វែង** (ត)

**ការវិនិយោគផ្សេងៗ**

ការវិនិយោគផ្សេងៗ រួមមាន ប្រាក់បញ្ញើមានកាលកំណត់នៅគ្រឹះស្ថានហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា និងការវិនិយោគសញ្ញាប័ណ្ណសាជីវកម្ម ដែលមានរយៈពេលកំណត់លើសពី៣ខែ។ ការប្រាក់ពីការដាក់ប្រាក់នៅធនាគារ និងពីការវិនិយោគសញ្ញាប័ណ្ណសាជីវកម្ម ត្រូវបានទទួលស្គាល់តាមវិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាព។

**បំណុលហិរញ្ញវត្ថុផ្សេងៗ**

បំណុលហិរញ្ញវត្ថុផ្សេងៗ ត្រូវបានទទួលស្គាល់លើកដំបូងតាមតម្លៃសមស្រប ដកចំណាយប្រតិបត្តិការផ្ទាល់ផ្សេងៗ។ បន្ទាប់ពីការទទួលស្គាល់លើកដំបូង បំណុលនេះត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់មានប្រសិទ្ធភាព។

**២.៨ ទ្រព្យសម្បត្តិ និងបរិក្ខារ**

(i) **ការទទួលស្គាល់ និងការវាស់វែង**

ខ្ទង់នីមួយៗនៃទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានវាស់វែងតាមថ្លៃដើម ដករំលស់បង្គរ និងការថយចុះតម្លៃបង្គរប្រសិនបើមាន។

ថ្លៃដើមរួមបញ្ចូលនូវចំណាយផ្ទាល់ផ្សេងៗ ក្នុងការទិញទ្រព្យសកម្ម និងចំណាយពាក់ព័ន្ធផ្សេងៗទៀត ក្នុងការយកទ្រព្យសកម្មនោះទៅកាន់លក្ខខណ្ឌមុខងារ ដើម្បីប្រើប្រាស់តាមគោលបំណងដែលបានគ្រោងទុក និងចំណាយសម្រាប់ការរុះរើ និងយកទ្រព្យសកម្មចេញ និងការស្តារទីតាំងឱ្យដូចដើមវិញ។ កម្មវិធីកុំព្យូទ័រដែលបានទិញ ដែលជាផ្នែកធ្វើឱ្យបរិក្ខារពាក់ព័ន្ធអាចដំណើរការបាន ត្រូវបានធ្វើមូលធនកម្មជាផ្នែកនៃបរិក្ខារនោះ។

ប្រសិនបើផ្នែកផ្សេងៗនៃទ្រព្យសម្បត្តិ និងបរិក្ខារណាមួយ មានអាយុកាលប្រើប្រាស់ខុសៗគ្នា នោះវាត្រូវបានកត់ត្រាក្រោមខ្ទង់គណនីដាច់ដោយឡែក (សមាសធាតុចម្បង) នៃទ្រព្យសម្បត្តិ និងបរិក្ខារ។

ចំណេញឬខាតពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានទទួលស្គាល់ក្នុងចំណេញ-ខាត។

(ii) **ចំណាយបន្តបន្ទាប់**

ចំណាយបន្តបន្ទាប់ត្រូវបានធ្វើមូលធនកម្ម តែនៅពេលដែលមានភាពប្រាកដថាអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតនៃចំណាយនោះ នឹងហូរចូលមកក្នុងក្រុមហ៊ុនតែប៉ុណ្ណោះ។ ការជួសជុលនិងថែទាំជាបន្តបន្ទាប់ ត្រូវបានកត់ត្រាជាចំណាយនៅពេលដែលប្រតិបត្តិការនោះបានកើតឡើង។

**២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)**

**២.៨ ទ្រព្យសម្បត្តិ និងបរិក្ខារ (ត)**

**(iii) រំលស់**

រំលស់ត្រូវបានគណនាដើម្បីជម្រះចេញពីបញ្ជីនូវថ្លៃដើមនៃទ្រព្យសម្បត្តិ និងបរិក្ខារ ដកតម្លៃសំណល់ប៉ាន់ស្មាន ដោយប្រើវិធីសាស្ត្ររំលស់ថេរ អាស្រ័យទៅតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មាន ហើយជាទូទៅវាត្រូវបានទទួលស្គាល់នៅក្នុងចំណេញ-ខាត ដូចខាងក្រោម៖

| | |
|---|---|
| ការកែលម្អទ្រព្យជួល | ៥ឆ្នាំ ឬរយៈពេលជួល ប្រសិនបើវាខ្លីជាង |
| សង្ហារិម និងបរិក្ខារបំពាក់ | ៥ឆ្នាំ |
| កុំព្យូទ័រ | ៥ឆ្នាំ |
| យានយន្ត | ៥ឆ្នាំ |

វិធីសាស្ត្ររំលស់ អាយុកាលប្រើប្រាស់ និងតម្លៃសំណល់ ត្រូវបានត្រួតពិនិត្យ នៅរៀងរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ និងកែតម្រូវតាមភាពសមស្រប។

**២.៩ ទ្រព្យសកម្មអរូបី**

ទ្រព្យសកម្មអរូបីរួមមានកម្មវិធីកុំព្យូទ័រ ត្រូវបានរាយការណ៍តាមថ្លៃដើមដករំលស់បង្គរ និងខាតពីការថយចុះតម្លៃ ប្រសិនបើមាន។

រំលស់ត្រូវបានកត់ត្រាជាបន្ទុកក្នុងចំណេញ-ខាត តាមមូលដ្ឋានថេរ អាស្រ័យទៅតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មានរយៈពេល១០ឆ្នាំ។

ចំណាយបន្តបន្ទាប់ត្រូវបានធ្វើមូលធនកម្ម តែនៅពេលដែលវាបង្កើនអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត នៃទ្រព្យសកម្មជាក់លាក់ដែលមានការពាក់ព័ន្ធប៉ុណ្ណោះ។ ចំណាយផ្សេងៗទាំងអស់ ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ-ខាត នៅពេលដែលប្រតិបត្តិការនោះបានកើតឡើង។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)

## ២.១០ ការថយចុះតម្លៃ

### (i) ទ្រព្យសកម្មហិរញ្ញវត្ថុអនិស្សន្ទ

ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាយតម្លៃនាកាលបរិច្ឆេទរាយការណ៍នីមួយៗ ដើម្បីកំណត់ថាតើមានភ័ស្តុតាងជាក់ស្តែងនៃការថយចុះតម្លៃឬទេ។

ភ័ស្តុតាងជាក់ស្តែងដែលបង្ហាញថាទ្រព្យសកម្មហិរញ្ញវត្ថុ មានការថយចុះតម្លៃ មានដូចខាងក្រោម៖

- កូនបំណុលខកខានមិនបានសងប្រាក់ ឬសងប្រាក់យឺតយ៉ាវ
- ការរៀបចំឡើងវិញនូវចំនួនទឹកប្រាក់ជំពាក់ក្រុមហ៊ុន ក្នុងលក្ខខណ្ឌដែលមិនសូវមានអំណោយផលចំពោះក្រុមហ៊ុន
- សញ្ញាណបង្ហាញថាកូនបំណុល ឬក្រុមហ៊ុនបោះផ្សាយមូលបត្រ នឹងក្ស័យធន
- ការផ្លាស់ប្តូរអវិជ្ជមាននៃស្ថានភាពទូទាត់ប្រាក់របស់អ្នកខ្ចីប្រាក់ ឬក្រុមហ៊ុនបោះផ្សាយមូលបត្រ
- ការបាត់បង់ទីផ្សារមូលបត្រសកម្ម ឬ
- ទិន្នន័យដែលអាចសង្កេតបានចង្អុលបង្ហាញថា មានការថយចុះដែលអាចវាស់វែងបាន ចំពោះលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគតពីក្រុមទ្រព្យសកម្មហិរញ្ញវត្ថុ។

*ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមថ្លៃដើមដករំលស់*

ក្រុមហ៊ុនពិចារណាលើភ័ស្តុតាងនៃការចុះថយតម្លៃរបស់ទ្រព្យសកម្មទាំងនេះ ទាំងនៅកម្រិតទ្រព្យសកម្មដោយឡែក និងទ្រព្យសកម្មរួម។ ទ្រព្យសកម្មសំខាន់ៗដាច់ដោយឡែកទាំងអស់ ត្រូវបានវាយតម្លៃរកការថយចុះតម្លៃដាច់ដោយឡែក។ បន្ទាប់មក ទ្រព្យសកម្មដែលរកឃើញថាមិនមានការថយចុះតម្លៃ ត្រូវបានវាយតម្លៃជារួមរកការថយចុះតម្លៃដែលបានកើតឡើង ប៉ុន្តែមិនទាន់អាចកំណត់បានដាច់ដោយឡែក។ ការវាយតម្លៃជារួមត្រូវបានធ្វើឡើងដោយដាក់ជាក្រុមនូវទ្រព្យសកម្មដែលមានលក្ខណៈហានិភ័យស្រដៀងគ្នា។

ក្នុងការវាយតម្លៃជារួមដើម្បីរកការថយចុះតម្លៃ ក្រុមហ៊ុនប្រើព័ត៌មានក្នុងគ្រាកន្លងមក ចំពោះពេលវេលានៃការប្រមូលបានមកវិញ និងចំនួនខាតបង់ដែលបានកើតឡើង និងធ្វើការវិនិច្ឆ័យ ប្រសិនបើលក្ខខណ្ឌសេដ្ឋកិច្ចនិងឥណទាននាពេលបច្ចុប្បន្ន ទំនងជាបណ្តាលឱ្យមានការខាតបង់ច្រើនជាង ឬតិចជាងការខាតបង់ក្នុងគ្រាមុនៗ។

ការខាតពីការថយចុះតម្លៃត្រូវបានគណនា ដោយផ្អែកលើចំនួនលម្អៀងរវាងតម្លៃយោងរបស់ទ្រព្យសកម្ម និងតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគត ដែលធ្វើអប្បហារតាមអត្រាការប្រាក់មានប្រសិទ្ធភាពដំបូងរបស់ទ្រព្យសកម្មនោះ។ ការខាតបង់ត្រូវបានទទួលស្គាល់ក្នុងចំណេញ-ខាត និងត្រូវបានបង្ហាញនៅក្នុងគណនីសំវិធានធន។ នៅពេលក្រុមហ៊ុនយល់ឃើញថាមិនមានការរំពឹងថាទទួលបានទ្រព្យសកម្មមកវិញ នោះចំនួនទឹកប្រាក់នោះត្រូវបានជម្រះចេញពីបញ្ជី។ ប្រសិនបើនៅពេលបន្ទាប់មក ការខាតបង់ពីការថយចុះតម្លៃមានការថយចុះ ហើយការថយចុះអាចពាក់ព័ន្ធនឹងព្រឹត្តិការណ៍កើតឡើងបន្ទាប់ពីការទទួលស្គាល់ការថយចុះតម្លៃ នោះការខាតពីការថយចុះតម្លៃដែលបានទទួលស្គាល់ពីមុន ត្រូវបានធ្វើការកត់ត្រាត្រឡប់ចូលក្នុងចំណេញ-ខាតឡើងវិញ។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)

## ២.១០ ការថយចុះតម្លៃ (ត)

### (ii) ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

នាកាលបរិច្ឆេទរាយការណ៍នីមួយៗ ក្រុមហ៊ុនត្រួតពិនិត្យតម្លៃយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ (សន្និធិផ្សេងៗ និងពន្ធពន្យារជាទ្រព្យសកម្ម) ដើម្បីកំណត់រកសញ្ញាណដែលបង្ហាញពីការថយចុះតម្លៃ។ ក្នុងករណីដែលមានសញ្ញាណបង្ហាញពីការថយចុះតម្លៃ នោះគេប៉ាន់ស្មានរកតម្លៃដែលអាចប្រមូលបានមកវិញរបស់ទ្រព្យសកម្ម។

ចំពោះការធ្វើតេស្តរកការថយចុះតម្លៃ ទ្រព្យសកម្មត្រូវបានដាក់បញ្ចូលគ្នាជាក្រុមតូចៗបំផុត ដែលអាចបង្កើតលំហូរសាច់ប្រាក់ចូលពីការបន្តប្រើប្រាស់ ដោយមិនអាស្រ័យលើលំហូរសាច់ប្រាក់ចូលពីទ្រព្យសកម្មដទៃទៀត ឬ ឯកតាបង្កើតសាច់ប្រាក់ (CGUs)។

តម្លៃដែលអាចប្រមូលបានមកវិញរបស់ទ្រព្យសកម្ម ឬ CGUs គឺជាតម្លៃណាមួយដែលធំជាង រវាងតម្លៃប្រើប្រាស់ និងតម្លៃសមស្រប ដកចំណាយការលក់។ តម្លៃប្រើប្រាស់គឺផ្អែកទៅលើលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគត ធ្វើអប្បហារឱ្យនៅស្មើតម្លៃបច្ចុប្បន្ន ដោយប្រើអត្រាអប្បហារមុនដកពន្ធ ដែលឆ្លុះបញ្ចាំងពីការប៉ាន់ស្មានទីផ្សារបច្ចុប្បន្ន នៃតម្លៃពេលវេលានៃទឹកប្រាក់ និងហានិភ័យជាក់លាក់សម្រាប់ទ្រព្យសកម្មទាំងនោះ ឬ CGUs។

ការខាតពីការថយចុះតម្លៃត្រូវបានទទួលស្គាល់ ប្រសិនបើតម្លៃយោងរបស់ទ្រព្យសកម្មមួយ ឬ CGUs មានចំនួនលើសពីតម្លៃដែលអាចប្រមូលមកវិញបាន។

ការខាតពីការថយចុះតម្លៃត្រូវបានទទួលស្គាល់ក្នុងចំណេញ-ខាត។ ការខាតពីការថយចុះតម្លៃ ត្រូវបានបែងចែកដើម្បីកាត់បន្ថយតម្លៃយោងរបស់ទ្រព្យសកម្ម នៅក្នុង CGUs តាមមូលដ្ឋានសមាមាត្រ។

## ២.១១ អត្ថប្រយោជន៍បុគ្គលិក

*អត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លី*

កាតព្វកិច្ចអត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លី ទាក់ទងនឹងប្រាក់ឈ្នួល ប្រាក់បៀវត្សរ៍ ភាគទានសន្តិសុខសង្គម ប្រាក់រង្វាន់ប្រចាំឆ្នាំ ការឈប់សម្រាកមានប្រាក់ឈ្នួល ច្បាប់ឈប់សម្រាកពេលឈឺ អត្ថប្រយោជន៍មិនមែនសាច់ប្រាក់ ត្រូវបានទទួលស្គាល់ជាចំណាយក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុ ដែលបុគ្គលិកបានបំពេញការងារជូនក្រុមហ៊ុន។

*អត្ថប្រយោជន៍បុគ្គលិកផ្សេងៗ - កាតព្វកិច្ចទូទាត់ប្រាក់បំណាច់អតីតភាពការងារ*

នៅខែមិថុនា ឆ្នាំ២០១៨ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើវិសោធនកម្មលើច្បាប់ស្តីពីការងារ ដែលណែនាំពីគម្រោងការទូទាត់ប្រាក់បំណាច់អតីតភាពការងារ។ បន្ទាប់មកនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ប្រកាសលេខ ៤៤៣ ក.ប/ប្រ.ក.ខ.ល ត្រូវបានចេញផ្សាយ ដោយបានផ្តល់នូវគោលការណ៍ណែនាំស្តីពីការអនុវត្តច្បាប់នេះ។ អនុលោមទៅតាមច្បាប់/ប្រកាស តម្រូវឱ្យអង្គភាពនីមួយៗទូទាត់ប្រាក់បំណាច់អតីតភាពការងារឱ្យបុគ្គលិក ដែលមានកិច្ចសន្យាការងារមិនមានថិរវេលាកំណត់ នូវប្រាក់បំណាច់ការងារប្រចាំឆ្នាំ ដែលចូលជាធរមានក្នុងខែមករា ឆ្នាំ២០១៩ ដោយត្រូវទូទាត់ស្មើនឹង១៥ថ្ងៃនៃប្រាក់បៀវត្សរ៍ប្រចាំខែរបស់បុគ្គលិក និងអត្ថប្រយោជន៍ក្នុងឆ្នាំនីមួយៗគិតជាមធ្យម ដែលត្រូវទូទាត់រៀងរាល់៦ខែម្តង គឺនៅថ្ងៃទី៣០ ខែមិថុនា និងថ្ងៃទី៣១ ខែធ្នូ (៧,៥ ថ្ងៃ ក្នុងការទូទាត់ម្តងៗ)។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)

### ២.១១ អត្ថប្រយោជន៍បុគ្គលិក (ត)

*អត្ថប្រយោជន៍បុគ្គលិកផ្សេងៗ - កាតព្វកិច្ចទូទាត់ប្រាក់បំណាច់អតីតភាពការងារ (ត)*

ការទូទាត់ប្រាក់បំណាច់ការងារប្រចាំឆ្នាំ ត្រូវបានចាត់ទុកថាជាអត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លី ហើយត្រូវបានកត់ត្រាបង្ករក្នុងឆ្នាំដែលបុគ្គលិកបានបម្រើការងារឱ្យក្រុមហ៊ុន។

*ផ្នែករបបប្រាក់សោធន*

ក្រុមហ៊ុនបង់ភាគទានប្រចាំខែជាប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច ទៅបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ដែលជាផ្នែកសាធារណៈរដ្ឋបាលនៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនក្នុងប្រទេសកម្ពុជា។ ក្រុមហ៊ុនមិនមានកាតព្វកិច្ចបង់ប្រាក់បន្ថែមទៀតទេ នៅពេលដែលបានបង់ភាគទាននេះរួច។ ភាគទានត្រូវបានកត់ត្រាជាចំណាយអត្ថប្រយោជន៍បុគ្គលិក នៅក្នុងរបាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ នៅពេលដល់ថ្ងៃកំណត់។

### ២.១២ ប្រាក់តម្កល់ធានាអាជីវកម្ម

ប្រាក់តម្កល់ធានាអាជីវកម្ម ត្រូវបានរក្សាទុកនៅធនាគារជាតិ នៃ កម្ពុជា អនុលោមតាមមាត្រា ៥៣ នៃអនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការធានារ៉ាប់រង ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០១ មាត្រា១ នៃសារាចរលេខ ០០៩សហវ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមាត្រា១៥ នៃប្រកាសលេខ ០៦១ ស្តីពី កម្រិតសាធនភាពរបស់ក្រុមហ៊ុនធានារ៉ាប់រង ដែលចេញដោយអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២។

ប្រាក់តម្កល់នេះ មិនមានការប្រាក់ទេ ហើយអាចបង្វិលមកវិញបាន នៅពេលដែលក្រុមហ៊ុនបញ្ឈប់ប្រតិបត្តិការអាជីវកម្មនៅក្នុងប្រទេសកម្ពុជា។

ប្រាក់តម្កល់ធានាអាជីវកម្ម ត្រូវបានកត់ត្រាតាមថ្លៃដើម។

### ២.១៣ ដើមទុន

ដើមទុនត្រូវបានចាត់ថ្នាក់ជា 'មូលធន'។ ការចំណាយបន្ថែមដែលទាក់ទងផ្ទាល់នឹងការបោះផ្សាយភាគហ៊ុនធម្មតា ត្រូវបានទទួលស្គាល់ជាការកាត់កងពី គណនីមូលធនក្រោយកាត់កងពន្ធ។

### ២.១៤ សំវិធានធន

សំវិធានធនត្រូវបានទទួលស្គាល់ ប្រសិនបើក្រុមហ៊ុនមានកាតព្វកិច្ចតាមផ្លូវច្បាប់នាពេលបច្ចុប្បន្ន ឬកាតព្វកិច្ចប្រយោល ដែលជាលទ្ធផលនៃព្រឹត្តិការណ៍ក្នុងអតីតកាល ហើយចំនួនទឹកប្រាក់អាចប៉ាន់ស្មានគួរឱ្យទុកចិត្តបាន ដែលទំនងជាតម្រូវឱ្យមានលំហូរធនធានចេញ ដើម្បីទូទាត់កាតព្វកិច្ចនោះ។

សំវិធានធន ត្រូវបានកំណត់ដោយអប្បហារលំហូរសាច់ប្រាក់ដែលរំពឹងថានឹងទទួលបាននាពេលអនាគត ដោយប្រើអត្រាមុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងពីការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃទឹកប្រាក់នៃពេលវេលា និងហានិភ័យជាក់លាក់ចំពោះបំណុលទាំងនោះ។ ការកត់ត្រាឡើងវិញនូវតម្លៃដែលបានអប្បហាររួច ត្រូវបានទទួលស្គាល់ជាចំណាយហិរញ្ញវត្ថុ។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥**

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)

## ២.១៥ ភតិសន្យា

### ភតិសន្យាដែលក្រុមហ៊ុនជាភាគីអ្នកជួល

នាពេលចាប់ផ្តើមកិច្ចសន្យា ក្រុមហ៊ុនវាយតម្លៃថាតើកិច្ចសន្យានោះ ឬខ្លឹមសាររបស់វាជាភតិសន្យាដែរឬទេ។

កិច្ចសន្យាមួយ ឬ ខ្លឹមសារនៃកិច្ចសន្យាមួយ ត្រូវបានចាត់ទុកថាជាភតិសន្យា ប្រសិនបើកិច្ចសន្យានោះផ្តល់សិទ្ធិក្នុងការគ្រប់គ្រងការប្រើប្រាស់ទ្រព្យសកម្មដែលត្រូវបានកំណត់មួយក្នុងរយៈពេលណាមួយ ជាថ្នូរនឹងការបង់ប្រាក់។

នាពេលចាប់ផ្តើមកិច្ចសន្យា ឬពេលកែប្រែកិច្ចសន្យាមួយដែលមានធាតុភតិសន្យា ក្រុមហ៊ុនបែងចែកទឹកប្រាក់ក្នុងកិច្ចសន្យានោះទៅតាមសមាសធាតុភតិសន្យានីមួយៗ តាមមូលដ្ឋានតម្លៃដាច់ដោយឡែករបស់វានីមួយៗ។

ទោះជាយ៉ាងណាក៏ដោយ ចំពោះការជួលអចលនទ្រព្យ ក្រុមហ៊ុនបានជ្រើសរើសមិនបែងចែកសមាសធាតុមិនមែនភតិសន្យាដាច់ដោយឡែកទេ និងបានកត់ត្រាធាតុភតិសន្យា និងធាតុមិនមែនភតិសន្យា ជាធាតុភតិសន្យាតែមួយដូចគ្នា។

ក្រុមហ៊ុនទទួលស្គាល់ សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យានាថ្ងៃចាប់ផ្តើមជួល។សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានទទួលស្គាល់លើកដំបូងតាមថ្លៃដើមដករំលស់ ដែលរួមមាន ចំនួនបំណុលភតិសន្យាលើកដំបូង និងធ្វើនិយ័តកម្មទៅតាមការទូទាត់ភតិសន្យាដែលបានបង់មុនថ្ងៃចាប់ផ្តើម ឬបានបង់នៅថ្ងៃចាប់ផ្តើម បូកចំណាយផ្ទាល់លើកដំបូងផ្សេងៗដែលបានកើតឡើង និងចំណាយប៉ាន់ស្មានក្នុងការរុះរើ និងយកទ្រព្យសកម្មមូលដ្ឋាននោះចេញ ឬចំណាយក្នុងការស្តារទ្រព្យសកម្មមូលដ្ឋាននោះឡើងវិញ ឬចំណាយរៀបចំទីតាំងដាក់សកម្មនោះឱ្យដូចដើមវិញ ដកជាមួយនឹងសម្បទានពីការជួលផ្សេងៗដែលបានទទួល។

បន្ទាប់មក សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានដករំលស់ ដោយប្រើវិធីសាស្ត្ររំលស់ថេរ ចាប់ពីកាលបរិច្ឆេទចាប់ផ្តើមការជួល រហូតដល់ពេលមុនផុតកំណត់អាយុកាលប្រើប្រាស់នៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ឬមុនពេលបញ្ចប់កិច្ចសន្យាជួល។ ការប៉ាន់ស្មានអាយុកាលប្រើប្រាស់នៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានកំណត់តាមមូលដ្ឋានដូចទ្រព្យសម្បត្តិ និងបរិក្ខារដែរ។ លើសពីនេះ សិទ្ធិប្រើប្រាស់ទ្រព្យសកម្មត្រូវបានកាត់បន្ថយពីមួយគ្រាទៅមួយគ្រា ដោយការខាតពីការថយចុះតម្លៃ ប្រសិនបើមាន និងកែតម្រូវទៅតាមការវាស់វែងបំណុលភតិសន្យាឡើងវិញ។

បំណុលភតិសន្យាត្រូវបានវាស់វែងលើកដំបូងតាមតម្លៃបច្ចុប្បន្ននៃការទូទាត់ថ្លៃជួល ដែលមិនទាន់បានបង់នាថ្ងៃចាប់ផ្តើមជួល ដកអប្បហារដោយប្រើអត្រាការប្រាក់ដែលត្រូវបានកំណត់ក្នុងភតិសន្យា ឬ ប្រសិនបើអត្រានោះមិនអាចត្រូវបានកំណត់គួរឱ្យទុកចិត្តបាន នោះគេប្រើអត្រាប្រាក់កម្ចីកំណើនរបស់ក្រុមហ៊ុនជំនួសវិញ។ ជាទូទៅ ក្រុមហ៊ុនប្រើប្រាស់អត្រាប្រាក់កម្ចីកំណើនជាអត្រាអប្បហារ។

ក្រុមហ៊ុនកំណត់អត្រាប្រាក់កម្ចីកំណើនរបស់ក្រុមហ៊ុន ដោយយកតាមប្រភពពីផ្នែកហិរញ្ញវត្ថុខាងក្រៅផ្សេងៗ និងកែតម្រូវតាមភាពជាក់ស្តែង ដើម្បីឱ្យវាស្របតាមលក្ខខណ្ឌក្នុងភតិសន្យា និងប្រភេទនៃទ្រព្យសកម្មដែលបានជួល។

ការទូទាត់ភតិសន្យាដែលត្រូវ ដែលត្រូវបានរួមបញ្ចូលនៅក្នុងការវាស់វែងបំណុលភតិសន្យា មានដូចខាងក្រោម៖

- ការបង់ថ្លៃជួលថេរ រួមទាំងការទូទាត់ថេរផ្សេងៗ
- ការទូទាត់ថ្លៃជួលអថេរ ដែលអាស្រ័យទៅតាមសន្ទស្សន៍ ឬអត្រា ប្រសិនបើវាត្រូវបានវាស់វែងលើកដំបូងដោយប្រើសន្ទស្សន៍ ឬអត្រា នាកាលបរិច្ឆេទចាប់ផ្តើម
- ទឹកប្រាក់រំពឹងទុកថាត្រូវទូទាត់ ក្រោមការធានាតម្លៃសំណល់ និង

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)

### ២.១៥ ភតិសន្យា (ត)

**ក្រុមហ៊ុនជាភាគីអ្នកជួល (ត)**

- ការអនុវត្តតម្លៃទិញក្រោមជម្រើសនៃការទិញ ដែលក្រុមហ៊ុនមានហេតុផលជាក់លាក់ក្នុងការអនុវត្តការទូទាត់ភតិសន្យា នៅក្នុងអំឡុងពេលដែលមានជម្រើសក្នុងការបន្ត ប្រសិនបើក្រុមហ៊ុនមានហេតុផលជាក់លាក់ក្នុងការបន្ត និងការពិន័យចំពោះការបញ្ចប់ភតិសន្យាមុនកាលកំណត់ លើកលែងតែក្រុមហ៊ុនមានហេតុផលច្បាស់លាស់ថានឹងមិនបញ្ចប់ភតិសន្យាមុនកាលកំណត់។

បំណុលភតិសន្យាត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ ដោយប្រើវិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាព។ វាត្រូវបានវាស់វែងនៅពេលដែលការទូទាត់ថ្លៃជួលនាពេលអនាគតមានការផ្លាស់ប្តូរ ដែលកើតពីការប្រែប្រួលសន្ទស្សន៍ ឬអត្រា ប្រសិនបើមានការប្រែប្រួលលើការប៉ាន់ស្មានរបស់ក្រុមហ៊ុនចំពោះទឹកប្រាក់ប៉ាន់ស្មាន ដែលត្រូវបង់ក្រោមការធានាតម្លៃសំណល់ ហើយប្រសិនបើក្រុមហ៊ុនផ្លាស់ប្តូរការវាយតម្លៃរបស់ខ្លួន ថាក្រុមហ៊ុនត្រូវជ្រើសរើសជម្រើសក្នុងការទិញ ជួលបន្ត ឬបញ្ឈប់ការជួល ឬ ប្រសិនបើមានការកែប្រែខ្លឹមសារនៃការទូទាត់ភតិសន្យាថេរ។

នៅពេលដែលបំណុលភតិសន្យាត្រូវបានវាស់វែងឡើងវិញតាមវិធីនេះ នោះត្រូវមាននិយ័តកម្មលើតម្លៃយោងរបស់សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ឬត្រូវកត់ត្រាក្នុងចំណេញ-ខាត ប្រសិនបើតម្លៃយោងរបស់សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម នោះត្រូវបានកាត់បន្ថយឱ្យនៅស្មើសូន្យ។

ក្រុមហ៊ុនបង្ហាញសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យាដាច់ដោយឡែកពីគ្នា នៅក្នុង របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

**ភតិសន្យារយៈពេលខ្លី និងភតិសន្យាដែលមានទ្រព្យសកម្មតម្លៃទាប**

ក្រុមហ៊ុនបានជ្រើសរើសមិនទទួលស្គាល់សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យា ចំពោះភតិសន្យាដែលមានទ្រព្យសកម្មតម្លៃទាប និងភតិសន្យារយៈពេលខ្លីទេ ដែលរួមមាន ការជួលរថយន្ត។ ក្រុមហ៊ុន ទទួលស្គាល់ការទូទាត់ភតិសន្យា ដែលទាក់ទងនឹងការជួលទាំងនេះជាចំណាយ តាមមូលដ្ឋានថេរ អាស្រ័យទៅតាមចិរវេលានៃភតិសន្យានោះ។

### ២.១៦ ចំណូលការប្រាក់

ការប្រាក់ពីប្រាក់បញ្ញើនៅធនាគារ និងពីការវិនិយោគសញ្ញាប័ណ្ណសាជីវកម្ម ត្រូវបានទទួលស្គាល់ក្នុងចំណេញ-ខាត ដោយប្រើវិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាព។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)

### ២.១៧ ពន្ធលើប្រាក់ចំណូល

ចំណាយពន្ធលើប្រាក់ចំណូល រួមមាន ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ និងពន្ធពន្យារ។ ពន្ធលើប្រាក់ចំណូលត្រូវបានទទួលស្គាល់នៅក្នុងចំណេញ-ខាត លើកលែងតែធាតុដែលត្រូវទទួលស្គាល់ដោយផ្ទាល់ក្នុងមូលធន ឬក្នុងចំណូលលម្អិតផ្សេងៗ។

(i) **ពន្ធប្រចាំឆ្នាំ**

ពន្ធប្រចាំឆ្នាំ គឺជាពន្ធត្រូវបង់រំពឹងទុក លើប្រាក់ចំណូលជាប់ពន្ធក្នុងឆ្នាំ ដោយប្រើអត្រាពន្ធដែលបានអនុម័តរួចជាស្ថាពរ ឬបានអនុម័តរួចមួយផ្នែកធំនាកាលបរិច្ឆេទរាយការណ៍ និងនិយ័តកម្មចំពោះពន្ធត្រូវបង់ក្នុងការិយបរិច្ឆេទមុនៗ។

(ii) **ពន្ធពន្យារ**

ពន្ធពន្យារត្រូវបានទទួលស្គាល់ដោយផ្អែកលើចំនួនលម្អៀងបណ្តោះអាសន្ន រវាងតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុល នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ជាមួយនឹងតម្លៃយោងសម្រាប់ការគិតពន្ធ។

ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានទទួលស្គាល់ចំពោះការខាតជាប់ពន្ធមិនទាន់បានប្រើប្រាស់ និងចំនួនលម្អៀងបណ្តោះអាសន្នដែលអាចកាត់កងបាន ប្រសិនបើមានភាពប្រាកដថានឹងមានប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត ដែលអាចប្រើសម្រាប់កាត់កង។ ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ និងត្រូវបានកាត់បន្ថយ ប្រសិនបើមិនមានភាពប្រាកដថានឹងមានអត្ថប្រយោជន៍ពន្ធពាក់ព័ន្ធត្រូវបានទទួលស្គាល់។ ការកាត់បន្ថយនោះត្រូវកត់ត្រាត្រឡប់មកវិញ នៅពេលដែលប្រូបាបនៃប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត មានលក្ខណៈប្រសើរឡើង។

ពន្ធពន្យារត្រូវបានវាស់វែងដោយប្រើអត្រាពន្ធ ដែលរំពឹងថាត្រូវអនុវត្តចំពោះចំនួនលម្អៀងបណ្តោះអាសន្ន នៅពេលដែលកត់ត្រាត្រឡប់មកវិញ ដោយប្រើអត្រាពន្ធដែលបានអនុម័តរួចជាស្ថាពរ ឬអនុម័តរួចមួយផ្នែកធំនាកាលបរិច្ឆេទរាយការណ៍។

ការវាស់វែងពន្ធពន្យារ ឆ្លុះបញ្ចាំងពីលទ្ធផលពន្ធដែលអនុវត្តតាមបែបបទដែលក្រុមហ៊ុនរំពឹងថា នឹងបានទទួលមកវិញ ឬការកាត់កងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុល នាកាលបរិច្ឆេទរាយការណ៍។

ពន្ធពន្យារជាទ្រព្យសកម្ម និងបំណុល ត្រូវបានកាត់កងតែក្នុងករណីដែលលក្ខណៈវិនិច្ឆ័យមួយចំនួនត្រូវបានបំពេញតែប៉ុណ្ណោះ។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)

## ២.១៨ ការវាស់វែងតម្លៃសមស្រប

'តម្លៃសមស្រប' គឺជាតម្លៃដែលអាចទទួលបាន ពីការលក់ទ្រព្យសកម្ម ឬតម្លៃត្រូវបង់ដើម្បីផ្ទេរបំណុល ក្នុងប្រតិបត្តិការតាមលំដាប់លំដោយមួយ រវាងការចូលរួមក្នុងទីផ្សារនាកាលបរិច្ឆេទវាស់វែងប្រាក់ដើម ឬ ទីផ្សារដែលមានផលប្រយោជន៍ខ្ពស់បំផុត ដែលក្រុមហ៊ុនអាចទទួលព័ត៌មានបាន នាកាលបរិច្ឆេទនោះ ក្នុងករណីដែលមិនមានទីផ្សារចូលរួម។

គោលការណ៍គណនេយ្យ និងការលាតត្រដាងមួយចំនួនរបស់ក្រុមហ៊ុន តម្រូវឱ្យមានការវាស់វែងតម្លៃសមស្របរបស់ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ (សូមមើលកំណត់សម្គាល់ ២.៧)។

ក្រុមហ៊ុនវាស់វែងតម្លៃសមស្របរបស់ឧបករណ៍មួយ ដោយប្រើតម្លៃដាក់លក់លើទីផ្សារសកម្មនៃឧបករណ៍នោះនៅពេលមានតម្លៃលើទីផ្សារ។ ទីផ្សារមួយដែលចាត់ទុកជាទីផ្សារ 'សកម្ម' ប្រសិនបើប្រតិបត្តិការសម្រាប់ទ្រព្យសកម្មនិងបំណុល កើតឡើងញឹកញាប់គ្រប់គ្រាន់ ហើយទំហំនៃការផ្តល់ព័ត៌មានគឺត្រូវបានធ្វើឡើងជាប្រចាំ។

ប្រសិនបើមិនមានតម្លៃដាក់លក់លើទីផ្សារសកម្ម នោះក្រុមហ៊ុនប្រើវិធីសាស្រ្តវាយតម្លៃដែលប្រើប្រាស់ជាអតិបរមានូវធាតុចូលពាក់ព័ន្ធដែលអាចសង្កេតបាន និងប្រើប្រាស់ធាតុចូលដែលមិនអាចសង្កេតបានជាអប្បបរមា។ វិធីសាស្រ្តវាយតម្លៃដែលបានជ្រើសរើស រួមបញ្ចូលនូវកត្តាដែលទាំងអស់ដែលត្រូវពិចារណានៅពេលចូលរួមក្នុងទីផ្សារ ក្នុងការកំណត់តម្លៃនៃប្រតិបត្តិការមួយ។

ភស្តុតាងល្អបំផុតក្នុងការកំណត់តម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុ នាពេលទទួលស្គាល់លើកដំបូងជាទូទៅ គឺជាតម្លៃប្រតិបត្តិការ ឧទាហរណ៍ដូចជា តម្លៃសមស្របនៃទឹកប្រាក់បានផ្តល់ ឬទឹកប្រាក់បានទទួល។ ប្រសិនបើក្រុមហ៊ុនកំណត់ថាតម្លៃសមស្របនាពេលទទួលស្គាល់លើកដំបូង ខុសពីតម្លៃប្រតិបត្តិការ ហើយតម្លៃសមស្របនោះមិនអាចរកភស្តុតាងបានទាំងតាមតម្លៃដាក់លក់លើទីផ្សារសកម្មសម្រាប់ទ្រព្យសកម្មឬបំណុលដូចគ្នា និងតម្លៃដែលផ្អែកតាមវិធីសាស្រ្តវាយតម្លៃចំពោះធាតុចូលមិនអាចសង្កេតបានណាមួយ ដែលត្រូវបានវិនិច្ឆ័យថាមានចំនួនតិចតួចក្នុងការវាស់វែងនោះឧបករណ៍ហិរញ្ញវត្ថុត្រូវបានវាស់វែងលើកដំបូងតាមតម្លៃសមស្រប និងធ្វើនិយ័តកម្មដើម្បីពន្យារចំនួនលម្អៀងរវាងតម្លៃសមស្របនាពេលទទួលស្គាល់លើកដំបូង ជាមួយនឹងតម្លៃប្រតិបត្តិការ។ បន្ទាប់មក ចំនួនលម្អៀងនេះត្រូវបានទទួលស្គាល់នៅក្នុងចំណេញ-ខាត តាមមូលដ្ឋានសមស្របមួយ ក្នុងអំឡុងពេលនៃអាយុកាលរបស់ឧបករណ៍នោះ ប៉ុន្តែមិនលើសពីរយៈពេលដែលការកំណត់តម្លៃនោះ ត្រូវបានគាំទ្រពេញលេញដោយទិន្នន័យទីផ្សារដែលអាចសង្កេតបាន ឬ រយៈពេលដែលប្រតិបត្តិការត្រូវបានបិទបញ្ចប់ទេ។

## ២.១៩ ការបង្គត់តួលេខ

រាល់ទឹកប្រាក់ជាដុល្លារអាមេរិកដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងកំណត់សម្គាល់គឺស្ថិតនៅក្នុងឯកតារូបិយប័ណ្ណដុល្លារអាមេរិកទាំងមូល។ ចំនួនទឹកប្រាក់ជាប្រាក់រៀល ដែលត្រូវបានលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និង កំណត់សម្គាល់ត្រូវបានបង្គត់ត្រឹមខ្ទង់ពាន់រៀល លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

## ៣. ការប៉ាន់ស្មានគណនេយ្យ និងការវិនិច្ឆ័យសំខាន់ៗ

ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យត្រូវបានវាយតម្លៃជាបន្តបន្ទាប់ និងផ្អែកទៅលើបទពិសោធន៍កន្លងមក និងកត្តាផ្សេងៗទៀត រួមមាន ការរំពឹងទុកអំពីព្រឹត្តិការណ៍នាពេលអនាគត ដែលក្រុមហ៊ុនជឿជាក់ថាមានភាពសមហេតុផលទៅតាមកាលៈទេសៈផ្សេងៗ។ ក្រុមហ៊ុនធ្វើការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យដោយគិតពីអនាគតកាល។ តាមនិយមន័យ លទ្ធផលនៃការប៉ាន់ស្មានគណនេយ្យ កម្រដូចគ្នានឹងលទ្ធផលពិតជាក់ស្តែងណាស់។ ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យដែលអាចបណ្តាលឱ្យមាននិយ័តកម្មធំដុំលើតម្លៃយោងនៃទ្រព្យសកម្មនិងបំណុល មានបង្ហាញដូចខាងក្រោម។

*បំណុលកិច្ចសន្យាធានារ៉ាប់រង*

បំណុលកិច្ចសន្យាធានារ៉ាប់រងទូទៅរបស់ក្រុមហ៊ុន រួមមាន បំណុលរយៈពេលខ្លី និងបំណុលរយៈពេលវែង។

បំណុលកិច្ចសន្យាធានារ៉ាប់រងរយៈពេលខ្លី គ្របដណ្តប់នូវកិច្ចសន្យាធានារ៉ាប់រងដែលមានរយៈពេលមួយឆ្នាំ ឬខ្លីជាង និងរួមមានសមាសធាតុបីដូចខាងក្រោម៖

- ប្រាក់បម្រុងបុព្វលាភធានារ៉ាប់រងមិនទាន់ចាត់ទុកជាចំណូល)៖ ត្រូវបានគណនាដោយប្រើវិធីសាស្ត្រ ១/៣៦៥ ដោយទទួលស្គាល់បុព្វលាភធានារ៉ាប់រងក្នុងចំនួនស្មើគ្នា ក្នុងរយៈពេលនៃកិច្ចសន្យា
- ប្រាក់បម្រុងសម្រាប់សំណងធានារ៉ាប់រងដែលទទួលបានរបាយការណ៍ប៉ុន្តែមិនទាន់ទូទាត់៖ គ្របដណ្តប់នូវសំណងដែលបានកើតឡើង ប៉ុន្តែមិនទាន់ទូទាត់
- ប្រាក់បម្រុងសម្រាប់សំណងធានារ៉ាប់រងដែលកើតឡើងប៉ុន្តែមិនទាន់ទទួលរបាយការណ៍៖ ជាទូទៅត្រូវគណនាដោយប្រើប្រាស់ វិធីសាស្ត្រត្រីកោណ ដែលតម្រូវឱ្យមាន ទិន្នន័យសំណងធានារ៉ាប់រង យ៉ាងតិច 12 ត្រីមាស។ ប្រសិនបើមិនមានទិន្នន័យគ្រប់គ្រាន់ គេអាចអនុវត្តវិធីសាស្ត្រផ្សេងបាន ដោយប្រាកដថា ប្រាក់បម្រុងនេះ មិនត្រូវតិចជាង ៥% នៃបុព្វលាភធានារ៉ាប់រងដុល។

ចំពោះបំណុលកិច្ចសន្យាធានារ៉ាប់រងរយៈពេលវែង (លើស១ឆ្នាំ) បំណុលត្រូវបានគណនាដោយប្រើវិធីសាស្ត្រ វិធីសាស្ត្រវាយតម្លៃបុព្វលាភធានារ៉ាប់រងដុល ។ វិធីសាស្ត្រនេះពាក់ព័ន្ធនឹងការកំណត់តម្លៃបច្ចុប្បន្ននៃអត្ថប្រយោជន៍ និងចំណាយនាពេលអនាគត ដកតម្លៃបច្ចុប្បន្ននៃបុព្វលាភធានារ៉ាប់រងនាពេលអនាគត។ វិធីសាស្ត្រនេះប្រើការសន្មតដ៏សុក្រឹតបំផុត ដោយធ្វើនិយ័តកម្មចំពោះចំនួនលម្អៀងអវិជ្ជមាន។

និយ័តកម្មដែលបានធ្វើឡើងក្នុងការកំណត់តម្លៃបំណុលទាំងនេះ មានផលប៉ះពាល់ទាំងចំពោះអត្ថប្រយោជន៍កិច្ចសន្យាធានារ៉ាប់រង ក្នុងរបាយការណ៍ចំណេញខាត និងបំណុលកិច្ចសន្យាធានារ៉ាប់រង ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

## ៤. ប្រាក់តម្កល់ធានាអាជីវកម្ម

ប្រាក់តម្កល់ធានាអាជីវកម្ម ត្រូវបានរក្សាទុកនៅធនាគារជាតិ នៃ កម្ពុជា អនុលោមតាមមាត្រា ៥៣ នៃអនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការធានារ៉ាប់រង ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០១ មាត្រា១ នៃសារាចរលេខ ០០៩សហវ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមាត្រា១៥ នៃប្រកាសលេខ០៦១ ស្តីពី កម្រិតសាធនភាពរបស់ក្រុមហ៊ុនធានារ៉ាប់រង ដែលចេញដោយអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២។

ប្រាក់តម្កល់ចំនួន ៧០០.០០០ដុល្លារអាមេរិក (២០២៤ ៖ ៧០០.០០០ដុល្លារអាមេរិក) មិនមានការប្រាក់ទេ ហើយក្រុមហ៊ុនអាចបង្វិលមកវិញបាននៅពេលដែលក្រុមហ៊ុនបញ្ឈប់ប្រតិបត្តិការអាជីវកម្មរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា។

## ៩. ទ្រព្យសម្បត្តិ និងបរិក្ខារ

| | ការកែលម្អទ្រព្យជួល | សង្ហារិម និងបរិក្ខារចំពាក់ | កុំព្យូទ័រ | យានយន្ត | សរុប | |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល |
| **២០២៥** | | | | | | |
| **ថ្លៃដើម** | | | | | | |
| នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២៥ | ៣៧.១៧៤ | ៦៦.២៥៧ | ២២៧.៩៣៥ | ១០១.២៤៨ | ៤៣២.៦១៤ | ១.៤១០.៧៦៩ |
| បន្ថែម | ១.១៤០ | ១.៩១៣ | ៣១.២១៧ | - | ៣៤.២៧០ | ១៣៧.៤៥៧ |
| ជម្រះចេញពីបញ្ជី | - | (៨៩) | (១.៤០៩) | - | (១.៤៩៨) | (៦.០០៨) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | ៣២៥.៣៧៦ |
| នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ | ៣៨.៣១៤ | ៦៨.០៨១ | ២៥៧.៧៤៣ | ១០១.២៤៨ | ៤៦៥.៣៨៦ | ១.៨៦៧.៥៩៤ |
| **ដកៈ រំលស់បង្គរ** | | | | | | |
| នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២៥ | ៨.០២៦ | ៣៨.៣៤០ | ១៨៨.៥២០ | ១០១.២៤៨ | ៣៣៦.១៣៤ | ១.៣៥២.៩៣៩ |
| រំលស់ក្នុងឆ្នាំ | ៧.៥៧៧ | ៧.៦៥៥ | ១៤.៧៩៨ | - | ៣០.០៣០ | ១២០.៤៥០ |
| ជម្រះចេញពីបញ្ជី | - | (៨៩) | (១.៤០៩) | - | (១.៤៩៨) | (៦.០០៨) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | (៣.៩៧៦) |
| នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ | ១៥.៦០៣ | ៤៥.៩០៦ | ២០១.៩០៩ | ១០១.២៤៨ | ៣៦៤.៦៦៦ | ១.៤៦៣.៤០៥ |
| **តម្លៃយោង** | | | | | | |
| នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ | ២២.៧១១ | ២២.១៧៥ | ៥៥.៨៣៤ | - | ១០០.៧២០ | ៤០៤.១៨៩ |

## ៥. ទ្រព្យសម្បត្តិ និងបរិក្ខារ (ត)

| | ការកែលម្អទ្រព្យជួល | សង្ហារិម និងបរិក្ខារចំពាក់ | កុំព្យូទ័រ | យានយន្ត | សរុប | |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល |
| **២០២៤** | | | | | | |
| **ថ្លៃដើម** | | | | | | |
| នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤ | ៣២.៨៥៦ | ៦១.២០៩ | ២០២.១៣២ | ១០៧.០៥៣ | ៤០៣.២៥០ | ១.៦១០.៧៦៩ |
| បន្ថែម | ៤.៣១៨ | ៥.៩១៩ | ២៦.១៤៦ | - | ៣៦.៣៨៣ | ១៤៨.១១៥ |
| ជម្រះចេញពីបញ្ជី | - | (៨៧១) | (៣៤៣) | (៥.៨០៥) | (៧.០១៩) | (២៨.៥៧៤) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | ២១០.៩៦១ |
| នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | ៣៧.១៧៤ | ៦៦.២៥៧ | ២២៧.៩៣៥ | ១០១.២៤៨ | ៤៣២.៦១៤ | ១.៧៤១.២៧១ |
| **ដកៈ រំលស់បង្គរ** | | | | | | |
| នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤ | ៦២១ | ៣១.៥៩០ | ១៦៨.៨៧៧ | ១០១.១១១ | ៣០២.១៩៩ | ១.២៣៤.៤៨៣ |
| រំលស់ក្នុងឆ្នាំ | ៧.៤០៥ | ៧.៦២១ | ១៩.៩៨៦ | ៥.៩៤២ | ៤០.៩៥៤ | ១៦៦.៧២៤ |
| ជម្រះចេញពីបញ្ជី | - | (៨៧១) | (៣៤៣) | (៥.៨០៥) | (៧.០១៩) | (២៨.៥៧៤) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | (១៩.៦៩៤) |
| នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | ៨.០២៦ | ៣៨.៣៤០ | ១៨៨.៥២០ | ១០១.២៤៨ | ៣៣៦.១៣៤ | ១.៣៥២.៩៣៩ |
| **តម្លៃយោង** | | | | | | |
| នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | ២៩.១៤៨ | ២៧.៩១៧ | ៣៩.៤១៥ | - | ៩៦.៤៨០ | ៣៨៨.៣៣២ |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

## ៦. ទ្រព្យសកម្មអរូបី

| | ២០២៥ | | ២០២៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ថ្លៃដើម** | | | | |
| នៅថ្ងៃទី០១ ខែមករា | ២១០.២៦៩ | ៨៤៦.៣៣៣ | ២១០.២៦៩ | ៨៥៦.៦៣៦ |
| បន្ថែម | ២៥.០០០ | ១០០.២៧៥ | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (២.៤៧៤) | - | (១០.៣០៣) |
| នៅថ្ងៃទី៣១ ខែធ្នូ | ២៣៥.២៦៩ | ៩៤៤.១៣៤ | ២១០.២៦៩ | ៨៤៦.៣៣៣ |
| **ដកៈ រំលស់បង្គរ** | | | | |
| នៅថ្ងៃទី០១ ខែមករា | ១១៩.១៧២ | ៤៧៩.៦៦៨ | ៩៨.០៩៩ | ២២៨.៤២១ |
| រំលស់ក្នុងឆ្នាំ | ២២.២១១ | ៨៩.០៨៨ | ២១.០៧៣ | ៨៥.៧៨៨ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (១.៣៨៧) | - | ១៦៥.៤៥៩ |
| នៅថ្ងៃទី៣១ ខែធ្នូ | ១៤១.៣៨៣ | ៥៦៧.៣៦៩ | ១១៩.១៧២ | ៤៧៩.៦៦៨ |
| **តម្លៃយោង** | | | | |
| នៅថ្ងៃទី៣១ ខែធ្នូ | ៩៣.៨៨៦ | ៣៧៦.៧៦៥ | ៩១.០៩៧ | ៣៦៦.៦៦៥ |

## ៧. ភតិសន្យា

ក្រុមហ៊ុនបានចុះកិច្ចសន្យាភតិសន្យាជាមួយ ធនាគារ កាណាឌីយ៉ា ក.អ សម្រាប់ការជួលបរិវេណការិយាល័យ ដែលមានសុពលភាពចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០៣៣ ដោយមិនគិតថ្លៃជួលក្នុងរយៈពេលកែលម្អការិយាល័យ ចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។ ក្នុងអំឡុងឆ្នាំ ក្រុមហ៊ុនបានចុះកិច្ចសន្យាភតិសន្យាថ្មីជាមួយក្រុមហ៊ុន Cambodia Airport Investment Co., Ltd. ដើម្បីជួលទីតាំងនៅអាកាសយានដ្ឋានអន្តរជាតិ តេជោ សម្រាប់រយៈពេលចាប់ពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២៥ ដល់ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២៧ ដោយគណៈគ្រប់គ្រងរំពឹងថានឹងមានការបន្តកិច្ចសន្យារយៈពេលមួយឆ្នាំទៀត ចាប់ពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២៧ ដល់ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២៨។

### (i) សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម

| | ២០២៥ | | ២០២៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ថ្លៃដើម** | | | | |
| នៅថ្ងៃទី០១ ខែមករា | ៥៦១.៤០៣ | ២.២៥៩.៦៤៧ | ៥៦១.៤០៣ | ២.២៩៣.៣៣១ |
| ការជួលបន្ថែម | ៦៣.២៩៤ | ២៥៣.៨៧២ | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (៦.៦១០) | - | (៣៣.៦៨៤) |
| នៅថ្ងៃទី៣១ ខែធ្នូ | ៦២៤.៦៩៧ | ២.៥០៦.៩០៩ | ៥៦១.៤០៣ | ២.២៥៩.៦៤៧ |
| **ដកៈ រំលស់បង្គរ** | | | | |
| នៅថ្ងៃទី០១ ខែមករា | (៦៨.៤៦៤) | (២៧៥.៥៦៨) | (១៣.៦៩៣) | (៥៥.៩៣៦) |
| រំលស់ក្នុងឆ្នាំ | (៦១.៨០៣) | (២៤៧.៨៩២) | (៥៤.៧៧១) | (២២២.៩៧៣) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ៦៩៩ | - | ៣.៣៤១ |
| នៅថ្ងៃទី៣១ ខែធ្នូ | (១៣០.២៦៧) | (៥២២.៧៦១) | (៦៨.៤៦៤) | (២៧៥.៥៦៨) |
| **តម្លៃយោង** | | | | |
| នៅថ្ងៃទី៣១ ខែធ្នូ | ៤៩៤.៤៣០ | ១.៩៨៤.១៤៨ | ៤៩២.៩៣៩ | ១.៩៨៤.០៧៩ |

## ៧. ភតិសន្យា (ត)

### (ii) បំណុលភតិសន្យា

| | ២០២៥ | | ២០២៤ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| រយៈពេលវែង | ៥០០.៥៩៥ | ២.០០៨.៨៨៨ | ៥០៣.៥៧៧ | ២.០២៦.៨៩៨ |
| រយៈពេលខ្លី | ៦០.៤៤៥ | ២៤២.៥៦៦ | ៣៦.៨៥៧ | ១៤៨.៣៤៩ |
| | ៥៦១.០៤០ | ២.២៥១.៤៥៤ | ៥៤០.៤៣៤ | ២.១៧៥.២៤៧ |

ខាងក្រោមនេះគឺជាប្រតិបត្តិការដែលទាក់ទងនឹងភតិសន្យា៖

| | ២០២៥ | | ២០២៤ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| *(i) ចំនួនទទួលស្គាល់ក្នុងចំណេញ-ខាត* | | | | |
| ចំណាយការប្រាក់លើបំណុលភតិសន្យា | ៤៨.៧៧៨ | ១៩៥.៦៤៩ | ៥០.៣០៤ | ២០៤.៧៨៨ |
| ចំណាយពាក់ព័ន្ធនឹងភតិសន្យាដែលមានតម្លៃ ទ្រព្យសកម្មទាប | ២.១០៥ | ៨.៤៤៣ | ២.៦៥០ | ១០.៧៨៨ |
| | ៥០.៨៨៣ | ២០៤.០៩២ | ៥២.៩៥៤ | ២១៥.៥៧៦ |
| *(ii) ចំនួនទទួលស្គាល់ក្នុងរបាយការណ៍លំហូរសាច់ប្រាក់* | | | | |
| ការទូទាត់សាច់ប្រាក់សម្រាប់ចំណែកការប្រាក់នៃ បំណុលភតិសន្យា | ៤២.៦៨៩ | ១៧១.២២៦ | ៣៣.៦៩៦ | ១៣៧.១៧៦ |
| ការទូទាត់សាច់ប្រាក់សម្រាប់ចំណែកប្រាក់ដើមនៃ បំណុលភតិសន្យា | ៤៨.៧៧៨ | ១៩៥.៦៤៩ | ៥០.៣០៤ | ២០៤.៧៨៨ |
| | ៩១.៤៦៧ | ៣៦៦.៨៧៥ | ៨៤.០០០ | ៣៤១.៩៦៤ |
| *(iii) ការវិភាគតាមកាលកំណត់ - លំហូរសាច់ប្រាក់ក្នុងកិច្ចសន្យាមិនធ្វើអប្បហារ* | | | | |
| ក្រោម១ឆ្នាំ | ១០៨.០០០ | ៤៣៣.៤០៤ | ៨៤.០០០ | ៣៣៨.១០០ |
| ១ឆ្នាំទៅ១០ឆ្នាំ | ៦៧០.០០០ | ២.៦៨៨.៧១០ | ៧១៤.០០០ | ២.៨៧៣.៨៥០ |
| លំហូរសាច់ប្រាក់មិនធ្វើអប្បហារសរុប | ៧៧៨.០០០ | ៣.១២២.១១៤ | ៧៩៨.០០០ | ៣.២១១.៩៥០ |

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

## ៨. គណនីធានារ៉ាប់រងត្រូវទទួល និងគណនីត្រូវទទួលផ្សេងៗ

| | ២០២៥ | | ២០២៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **គណនីធានារ៉ាប់រងត្រូវទទួល៖** | | | | |
| បុព្វលាភធានារ៉ាប់រងដុលត្រូវទទួល | ៨៦៨.៩១៧ | ៣.៤៨៦.៩៦៤ | ១២៥.៤៤៥ | ៥០៤.៩១៦ |
| បុព្វលាភធានារ៉ាប់រងដុលត្រូវទទួលពីភាគីពាក់ព័ន្ធ (កំណត់សម្គាល់ ១៦(ខ)) | ៣៦៣.៥៦៦ | ១.៤៥៨.៩៩០ | ៣៧២.០៩៣ | ១.៤៩៧.៦៧៤ |
| គណនីត្រូវទទួលពីធានារ៉ាប់រងបន្ត | ៧៥៣.០៩១ | ៣.០២២.១៥៤ | ២២១.៤៤២ | ៨៩១.៣០៤ |
| ចំណាយកម្រៃជើងសាពន្យារ | ២៣៩.៣៨៧ | ៩៦០.៦៦០ | ៧៧.៣៦១ | ៣១១.៣៧៨ |
| | ២.២២៤.៩៦១ | ៨.៩២៨.៧៦៨ | ៧៩៦.៣៤១ | ៣.២០៥.២៧២ |
| **គណនីត្រូវទទួលផ្សេងៗ៖** | | | | |
| ចំណាយបង់មុន | ៤៣.៩៧៤ | ១៧៦.៤៦៨ | ១៨.០២៣ | ៧២.៥៤៣ |
| ប្រាក់កក់ | ៣៣.៩១០ | ១៣៦.០៨១ | ៣៩.២៧០ | ១៥៨.០៦២ |
| ការទូទាត់បានបង់មុន | ៤៩៩ | ២.០០២ | ៣០.២៨០ | ១២១.៨៧៧ |
| | ៧៨.៣៨៣ | ៣១៤.៥៥១ | ៨៧.៥៧៣ | ៣៥២.៤៨២ |
| | ២.៣០៣.៣៤៤ | ៩.២៤៣.៣១៩ | ៨៨៣.៩១៤ | ៣.៥៥៧.៧៥៤ |

## ៩. ការវិនិយោគផ្សេងៗ

| | ២០២៥ | | ២០២៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ការដាក់ប្រាក់នៅធនាគារដែលមានកាលកំណត់ដំបូងលើសពី៣ខែ ប៉ុន្តែតិចជាង១ឆ្នាំ | ៧៧៤.១៤៨ | ៣.១០៦.៦៥៦ | ៧៩៩.៨៥៤ | ៣.២១៩.៤១២ |
| ការដាក់ប្រាក់នៅធនាគារដែលមានកាលកំណត់ដំបូងលើស១ឆ្នាំ | ៦.២២៧.២៥០ | ២៤.៩៩៨.៩៥៤ | ៦.៧២៦.៨១០ | ២៧.០៧៥.៤១១ |
| ការវិនិយោគសញ្ញាប័ណ្ណអាជីវកម្ម (i) | ១.០៤២.៩៤០ | ៤.១៨៥.៣១៨ | - | - |
| | ៨.០៤៤.៣៣៨ | ៣២.២៨១.៩២៨ | ៧.៥២៦.៦៦៤ | ៣០.២៩៤.៨២៣ |

ការដាក់ប្រាក់នៅធនាគារក្នុងប្រទេស មានការប្រាក់ក្នុងចន្លោះពី ៤,២៥% ទៅ ៧,២៥% ក្នុងមួយឆ្នាំ (២០២៤ ៖ ៤,៧៥% ទៅ ៨,០០%)។

## ៩. ការវិនិយោគផ្សេងៗ (ត)

(i) ការវិនិយោគសញ្ញាប័ណ្ណសាជីវកម្មត្រូវបានចាត់ថ្នាក់ជាការវិនិយោគផ្សេងៗ។ គិតត្រឹមកាលបរិច្ឆេទរាយការណ៍ ក្រុមហ៊ុនបានវិនិយោគសញ្ញាប័ណ្ណសាជីវកម្មដែលមានការធានារបស់ក្រុមហ៊ុន Cambodia Airport Investment Co., Ltd.។ សញ្ញាប័ណ្ណសាជីវកម្មនេះមានរយៈពេលកំណត់ ៣ ឆ្នាំ ដែលមានកាលបរិច្ឆេទកំណត់នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៨ និងទទួលបានការប្រាក់ ៦,២៥% ក្នុងមួយឆ្នាំ។

## ១០. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

| | ២០២៥ | | ២០២៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| សាច់ប្រាក់ក្នុងដៃ | ១.៧៥៥ | ៧.០៤៣ | ៤.១២៤ | ១៦.៥៩៩ |
| សាច់ប្រាក់នៅធនាគារ | ១.៨៦៣.៥៥១ | ៧.៤៧៨.៤៣០ | ៨៩៨.៥២៥ | ៣.៦១៦.៥៦៣ |
| | ១.៨៦៥.៣០៦ | ៧.៤៨៥.៤៧៣ | ៩០២.៦៤៩ | ៣.៦៣៣.១៦២ |

សាច់ប្រាក់នៅធនាគាររួមមាន ប្រាក់បញ្ញើមានកាលកំណត់នៅគ្រឹះស្ថានហិរញ្ញវត្ថុ ក្នុងប្រទេសកម្ពុជា ដែលមានរយៈពេលកំណត់តិចជាង ឬស្មើនឹង៣ខែ ដែលមានការប្រាក់ក្នុងចន្លោះពី ៣,៥៥% ទៅ ៤,៧៥% (២០២៤ ៖ ៤,២៥% ទៅ ៥,៧៥%) និងគណនីសន្សំ និងគណនីចរន្ត ដែលមានការប្រាក់ក្នុងចន្លោះពី 0% ទៅ ១,00% ក្នុងមួយឆ្នាំ (២០២៤ ៖ 0% ទៅ ១,0៥% ក្នុងមួយឆ្នាំ)។

## ១១. ដើមទុន

| | ២០២៥ | | ២០២៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ដើមទុនចុះបញ្ជី បោះផ្សាយ និងបង់ប្រាក់រួច ៨.000.000ភាគហ៊ុន មានតម្លៃ១ដុល្លារអាមេរិក ក្នុងមួយភាគហ៊ុន | ៨.000.000 | ៣២.000.000 | ៨.000.000 | ៣២.000.000 |

**តារា អ៊ិនសួរិន ម.ក**

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
